**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Universite Royale de Droit et des Sciences Economiques**
**Royal University of Law and Economic**

# សារណាបញ្ចប់ការសិក្សា

# ស្ថានភាពជម្លោះសមុទ្រចិនខាងត្បូងក្នុង ទំនាក់ទំនងអន្តរជាតិ

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០១៤ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៤

តាក់តែងឡើងដោយ
និស្សិតឈ្មោះ: **ល. តាន់ ប៊ុនឆាយ**
**ក. មុំ សុផាន្នី**

សាស្ត្រាចារ្យណែនាំ
**លោក ជុំ ចាន់វិត្ថា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ
ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០
ឆ្នាំសរសេរសារណា ២០១៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **មុំ សុផានី** សូមគោរពប្រណិបត្តិ និងថ្លែងអំណរគុណយ៉ាង ជ្រាលជ្រៅបំផុតរកអ្វីប្រៀបផ្ទឹមមិនបានចំពោះលោកឪពុក **មុំ ឃាណ** និងអ្នកម្តាយ **ភោគ សាឡី** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីចាច់ ថែរក្សាប្រកបដោយព្រហ្មវិហារធម៌ និងការសណ្តោសប្រោសប្រណី ព្រមទាំងលើកទឹកចិត្តចំពោះរូបកូន តាំងពីនៅតូចរហូតដល់ធំពេញវ័យ ដោយផ្គត់ផ្គង់ទាំងសំភារៈរស់នៅប្រចាំថ្ងៃ និងការសិក្សា។ និង ខ្ញុំបាទឈ្មោះ **តាន់ ប៊ុនឆាយ** សូមគោរពប្រណិបត្តិ និងថ្លែងអំណរគុណយ៉ាង ជ្រាលជ្រៅបំផុតរកអ្វីប្រៀបផ្ទឹមមិនបានចំពោះអ្នកមានគុណយើងតាំងពីរ លោកឪពុក **តាន់ ថៃសាត** និងអ្នកម្តាយ **អ៊ីវ ស៊ីជូ** ដែលបានផ្តល់កំណើត និងចិញ្ចឹមបីចាច់ថែរក្សាប្រកបដោយព្រហ្មវិហារធម៌ និងការ សណ្តោសប្រោសប្រណី ព្រមទាំងលើកទឹកចិត្តចំពោះរូបកូន តាំងពីនៅតូចរហូតដល់ធំពេញវ័យ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណ លោកអ៊ំ លោកពូ អ្នកមីងគ្រប់រូប បងប្អូនព្រមទាំងមិត្តភក្តិ និងញាតិមិត្តទាំងឡាយដែលជានិច្ចកាលផ្តល់នូវកម្លាំងចិត្ត ការជួយជ្រោមជ្រែងភាពកក់ក្តៅ ភាពសប្បាយរីករាយ និងផ្តល់នូវសាមគ្គីភាពនៅក្នុងការសិក្សា និងជីវភាពប្រចាំថ្ងៃរបស់នាងខ្ញុំនិងខ្ញុំបាទ។ លើសពីនេះទៀត យើងខ្ញុំសូមគោរព និងធ្វើការថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ៖

ឯកឧត្តម **លុយ ចណ្ណា** សកលវិទ្យាធិការ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច លោកសកលវិទ្យាធិការរង លោកស្រីព្រឹទ្ធបុរស លោក លោកស្រីសាស្ត្រាចារ្យដទៃទៀត ដែលបានបង្កើតកម្មវិធីសិក្សាល្អៗសម្រាប់ផ្តល់ការអប់រំដល់សិស្សនិស្សិត និងជួយជ្រោមជ្រែងគ្រប់បែបយ៉ាងក្នុងការផ្តល់ភាពងាយស្រួលដល់យើងខ្ញុំក្នុងការសិក្សា។ ជាពិសេស លោកសាស្ត្រាចារ្យ **ជុំ ចាន់វិត្ថា** ដែលបានខិតខំប្រឹងប្រែងចំណាយអស់កម្លាំងកាយចិត្ត ចំណាយពេល វេលាមានតម្លៃមិនខ្លាចនឿយហត់ក្នុងការបណ្តុះបណ្តាល និងណែនាំព្រមទាំងផ្តល់នូវគំនិតល្អៗដល់រូបនាងខ្ញុំ និងខ្ញុំបាទក្នុងការរៀបរៀងសារណានេះឡើង។ ជាទីបញ្ចាប់យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីមង្គលមហាបវរប្រសើរ ជូនដល់បុគ្គលដូចដែលបានរៀបរាប់ខាងលើឲ្យជួបតែពុទ្ធិពរទាំង ៤ប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

យើងខ្ញុំមានសេចក្តីសោមនស្សរីករាយ និងកិត្តិយសជាខ្លាំងដែលអាចឆក់យកឱកាសដើម្បីសរសេរសារណាបញ្ចប់ការសិក្សាឆ្នាំទី ៤ ផ្នែកនីតិសាស្ត្រ នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទស្តីពី **ជម្លោះដែនសមុទ្រចិនខាងត្បូងនៅក្នុងទំនាក់ទំនងអន្តរជាតិ** ដើម្បីទុកជាស្នាដៃមួយរបស់និស្សិតកម្ពុជាក្នុងការស្វែងយល់ពីជម្លោះអន្តរជាតិដែលពាក់ពន្ធ័យ៉ាងជិតស្និទជាមួយសមាជិកអាស៊ាន និងសាធារណៈរដ្ឋប្រជាមានិតចិន។ ការរំពឹងរបស់យើងខ្ញុំ គឺឯកសារមួយនេះ នឹងក្លាយទៅជាឯកសារពិគ្រោះសម្រាប់និស្សិតជំនាន់ក្រោយ សាស្ត្រាចារ្យ និងមហាជនទូទៅក្នុងស្វែងយល់ពីទំនាក់ទំនងអន្តរជាតិ និងជម្លោះដែលជាប់គាំងដោយសារបញ្ហាស្មុគស្មាញមួយចំនួន។ មុននឹងធ្វើការស្រាវជ្រាវលើប្រធានបទនេះ ពួកយើងដឹងថាវាមានការលំបាកដើម្បីរកការប្រឹក្សាយោបល់ និងស្វែងរកពត៌មានដែលទាក់ទងនឹងប្រធានបទ ប៉ុន្តែដោយសារការខិតខំរបស់ពួកយើង ជាពិសេសមានការណែនាំពីលោកសាស្ត្រាចារ្យ **ជុំ ចាន់វុត្ថា** ដែលមានជំនាញផ្នែកនីតិអន្តរជាតិសាធារណៈ យើងក៏អាចបញ្ចប់សារណាមួយនេះដោយជោគជ័យ។ ក្នុងការស្រាវជ្រាវឯកសារយើងប្រើវិធីជាច្រើនតាមរយៈស្រាវជ្រាវឯកសារបរទេស សៀវភៅជាភាសាខ្មែរ សារណាស្នាដៃរបស់សិស្សច្បងជំនាន់មុន និង ការវិភាគរបស់បញ្ញាវន្តជាតិ និងអន្តរជាតិមួយចំនួនទៀត។ រាល់ពត៌មានដែលយើងទទួលបាន យើងត្រូវក្តាប់ឲ្យជាប់ ថាតើវាមានប្រភពពិតប្រាកដ និងអាចទទួលបានដែរឬទេ ដូច្នេះក្នុងអំឡុងពេលធ្វើសារណានេះ យើងទាំងពីរនាក់មានការប្រុងប្រយត្ន័ខ្ពស់បំផុតជៀសវាងការដកស្រង់ពត៌មាន ដែលគ្មានប្រភពច្បាស់លាស់។ យើងខ្ញុំបាននឹងកំពុងផ្សារភ្ជាប់ខ្លួនទៅនឹងកិច្ចការអន្តរជាតិតាមរយៈការធ្វើសារណានេះ ហើយឲ្យកាន់តែយល់ច្បាស់ថាតើគោលនយោបាយការបរទេសរបស់ប្រទេសនីមួយៗ រួមទាំងប្រទេសកម្ពុជាយើងមានសារៈសំខាន់ប៉ុណ្ណា ហើយថាតើមានឥទ្ធិពលប៉ុណ្ណាប្រសិនបើរដ្ឋមួយសម្រេចចិត្តមិនបានត្រឹមត្រូវទៅលើបញ្ហាទាំងនោះ។ ការចងក្រងសារណានេះ យើងខ្ញុំសូមអភ័យទោសទុកជាមុនពីសំណាក់សាស្ត្រាចារ្យ មិត្តនិស្សិត និងអ្នកស្រាវជ្រាវដទៃទៀត ប្រសិនបើលោកអ្នកស្វែងរកឃើញកំហុសកន្លែងណាមួយ ដែលជាកំហុសអចេនតារបស់យើងខ្ញុំ។ យើងខ្ញុំរង់ចាំ និងស្វាគមន៍ជាខ្លាំងរាល់ការរិះគន់ស្ថាបនាយ៉ាងខ្ពង់ខ្ពស់ពីសំណាក់មិត្តនិស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ ដទៃទៀតដើម្បីធ្វើឲ្យប្រសើរឡើងនូវសារណារបស់យើងខ្ញុំ។ ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់មិត្តនិស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវនានាឲ្យជួបតែសេចក្តីសុខ និងជោគជ័យគ្រប់ឧបសគ្គទាំងឡាយ។

# មាតិកា

**សេចក្តីថ្លែងអំណរគុណ**

**អារម្ភកថា**

**តារាងសម្គាល់អក្សរកាត់** **ទំព័រ**

**សេចក្តីផ្តើម** ..... ១

**ជំពូកទី ១៖ កត្តាភូមិសាស្ត្រ ប្រវត្តិសាស្ត្រនៃជម្លោះសមុទ្រចិនខាងត្បូង** ..... ៣

១. លក្ខណៈភូមិសាស្ត្រ និង ធនធានធម្មជាតិរបស់សមុទ្រចិនខាងត្បូង ..... ៣

២. ប្រវត្តិជម្លោះសមុទ្រចិនខាងត្បូង ..... ៤

កថាខណ្ឌទី ១៖ ករណីប្រទេសចិន ..... ៥

១. ប្រវត្តិសាស្ត្រ ..... ៥

២. លក្ខណៈភូមិសាស្ត្រ ..... ៧

កថាខណ្ឌទី ២៖ ករណីប្រទេសប្រ៊ុយណេដារុស្សាឡឹម ..... ៨

១. ប្រវត្តិសាស្ត្រ ..... ៨

២. លក្ខណៈភូមិសាស្ត្រ ..... ៨

កថាខណ្ឌទី ៣៖ ករណីប្រទេសវៀតណាម ..... ៩

១. ប្រវត្តិសាស្ត្រ ..... ៩

២. លក្ខណៈភូមិសាស្ត្រ ..... ១០

កថាខណ្ឌទី ៤៖ ករណីប្រទេសម៉ាឡេស៊ី ..... ១១

១. ប្រវត្តិសាស្ត្រ ..... ១១

២. លក្ខណៈភូមិសាស្ត្រ ..... ១១

កថាខណ្ឌទី ៥៖ ករណីប្រទេសហ្វីលីពីន ..... ១២

១. ប្រវត្តិសាស្ត្រ ..... ១២

២. លក្ខណៈភូមិសាស្ត្រ ..... ១៣

**ជំពូកទី ២៖ ស្ថានភាពជម្លោះសមុទ្រចិនខាងត្បូង** ............ ១៤
កថាខណ្ឌទី ១៖ ឥទ្ធិពលនៃជម្លោះក្នុងទំនាក់ទំនងអន្តរជាតិ............ ១៤
១.មហិច្ឆិតានិងយុទ្ធសាស្ត្ររបស់ចិនលើសមុទ្រចិនខាងត្បូង............ ១៥
២.ដំណើរការជម្លោះរវាងចិន និង បណ្ដាប្រទេសសមាជិកអាស៊ាន ............ ១៧
២.១ ជម្លោះចិន និង ហ្វីលីពីន ............ ១៧
២.២ ជម្លោះចិន និង វៀតណាម ............ ១៩
២.៣ ជម្លោះចិន និង ម៉ាឡេស៊ី............ ២៥
២.៤ ជម្លោះចិន និង ប្រ៊ុយណេ............ ២៦
កថាខណ្ឌទី ២៖ ការលូកដៃចូលជ្រៀតជ្រែករបស់មហាអំណាច ............ ២៧
១.វត្តមានរបស់អាមេរិចក្នុងជម្លោះសមុទ្រចិនខាងត្បូង............ ២៧
២.ការប្រឈមមុខគ្នារវាងចិន និង អាមេរិក............ ២៩
២.១. ចិន និងអាមេរិក ក្រោមអាណត្តិប្រធានាធិបតី លោកប៊ូស (Bush)............ ៣១
២.២. ចិន និងអាមេរិក ក្រោមអាណត្តិប្រធានាធិបតី លោកអូបាម៉ា (Obama)... ៣២
៣.ជំហររបស់ឥណ្ឌាក្នុងបញ្ហាសមុទ្រចិនខាងត្បូង ............ ៣៤
៤.ជំហររបស់អូស្ត្រាលីក្នុងបញ្ហាសមុទ្រចិនខាងត្បូង............ ៣៥
កថាខណ្ឌទី ៣៖ ទិដ្ឋភាពច្បាប់អន្តរជាតិនៃជម្លោះសមុទ្រចិនខាងត្បូង ............ ៣៦
១.នីតិសមុទ្រអន្តរជាតិ ............ ៣៦
២.សេចក្ដីថ្លែងការស្ដីពីការប្រតិបត្តិក្នុងសមុទ្រចិនខាងត្បូងរបស់អាស៊ាន............ ៤១
៣.ដំណើរការនៃការអនុម័តទទួលស្គាល់ក្រមប្រតិបត្តិសមុទ្រចិនខាងត្បូង............ ៤៣
**ជំពូកទី៣៖ យន្តការ និង ការវិវត្តន៍នៃដំណោះស្រាយជម្លោះ សមុទ្រចិនខាងត្បូង** ............ ៤៥
កថាខណ្ឌទី ១៖ យន្តការដោះស្រាយលើវេទិកាអាស៊ាន និងលើឆាកអន្តរជាតិ............ ៤៥
១.ប្រតិកម្មក្រោយកិច្ចប្រជុំកំពូលលើកទី២ រវាងអាមេរិក និងអាស៊ាន(US-ASEAN)............ ៤៥
កថាខណ្ឌទី ២៖ យន្តការដោះស្រាយនិងពិភាក្សានៅក្នុងអង្គការសហប្រជាជាតិ............ ៥០

កថាខណ្ឌទី ៣៖ ការប្រមើលមើលឧបសគ្គ និងដំណោះស្រាយនៃជម្លោះ
នៅសមុទ្រចិនខាងត្បូង......................................................................៥០
១.គំនិតផ្តួចផ្តើមប្រាំមួយយ៉ាងទាក់ទងដល់ការសម្របសម្រួល បន្ធូរ បន្ថយ នូវភាពតានតឹងលើសមុទ្រចិនខាងត្បូង......................................................................៥០
២.ប្រការសំខាន់ ៧ ចំណុចពាក់ពន្ធ័បញ្ហាគន្លឹះមិនអាចដំណោះស្រាយ
សមុទ្រចិនខាងត្បូង......................................................................៥១
៣.ដំណោះស្រាយសន្តិភាពក្នុងជម្លោះសមុទ្រចិនខាងត្បូង..........................................៥៤
**សេចក្តីសន្និដ្ឋាន**......................................................................៥៨
**អនុសាសន៍**......................................................................៥៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

បណ្តាប្រទេសទាំងអស់មិនថា សម័យកាលណាក៏ដោយតែងតែស្វែងរកសន្តិភាពសំរាប់ពិភពលោក ទោះបីជាមេដឹកនាំមួយចំនួន និងប្រទេសទាំងអស់នោះមិនអាចធានាបាននូវការទទួលបានសុខសន្តិភាព ១០០%ក៏ដោយ។ សន្តិភាព និងជម្លោះក្លាយជាប្រធានបទមួយដល់សំខាន់សំរាប់មនុស្ស ជាតិ ហើយតំបន់ជម្លោះ និងអស្ថេរភាពត្រូវបានផ្លាស់ប្តូរតាមសម័យកាលតាមទិន្នាកាលរបស់មហាអំណាច ថាតើពួកគេផ្តោតទៅលើអ្វី។

យើងឃើញថា នៅសតវត្សទី ២១ យើងនេះមហាយក្សចិនបានពង្រីកនយោបាយរបស់ខ្លួនទាំងសេដ្ឋកិច្ច និងនយោបាយដែលធ្វើឲ្យប្រទេសមួយនេះលែងខ្លាចរអាប្រទេសណាមួយទល់តែសោះដែលជាដើមហេតុធ្វើឲ្យជម្លោះសមុទ្រចិនខាងត្បូងមានកំដៅក្តៅគគុករវាងចិន និងប្រទេសពាក់ពន្ធ័ដូចជា ហ្វីលីពីន វៀតណាម ព្រុយណេ និង ម៉ាឡេស៊ី ក្នុងការដណ្តើមគ្នាក្តោបក្តាប់ទីប្រជុំកោះ ប៉ារ៉ាសែល (Paracel) និង ស្ព្រែតលី (Spratly) ស្របពេលដែលបណ្តាប្រទេសអាស៊ីអាគ្នេយ៍ បានចាកចេញរួចពីភាពប្រេះឆា និងបានមកដល់ទីដៅនៃឯកភាពដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចក្រោមដំបូលតែមួយរបស់អាស៊ាន ស្រាប់តែអង្គការតំបន់មួយនេះ ហាក់ដូចជាដើរមកដល់របត់មួយប្រកបទៅដោយគ្រោះថ្នាក់ទៅវិញ ដោយហេតុតែត្រូវប្រឈមមុខនឹងបញ្ហាស្មុគស្មាញមួយចំនួន។ គ្រង់នេះ មហិច្ចតាកាន់តែធំ និងការស្រេកឃ្លានទឹកដីកាន់តែច្បាស់របស់ ចិនក្នុងសមុទ្រចិនខាងត្បូងបាននិងកំពុងបណ្តាលឲ្យភាពតានតឹងកើតឡើងជារឿយៗ នៅក្នុងជំនួបកំពូលអាស៊ាន និងនៅក្នុងជំនួបកំពូលអាស៊ីបូព៌ា។ ការមើលមុខគ្នាមិនចំជាពិសេសរវាងចិន វៀតណាម និងហ្វីលីពីន។ ធ្ងន់ធ្ងរជាងនេះទៅទៀត គឺស្ថានភាពទូទៅនៅអាស៊ីអាគ្នេយ៍សព្វថ្ងៃ។ ពិតមែនតែសង្គ្រាមត្រជាក់ បានរលត់រលាយបាត់ទៅអស់រយៈពេលជាង ២០ឆ្នាំកន្លងមកហើយក្តី ក៏ចម្បាំងត្រជាក់មួយហាក់ដូចជាកំពុងផ្តើមកើតឡើងសារជាថ្មី នៅក្នុងភូមិភាគនេះ រវាងអាមេរិក និងចិន។

បញ្ហានៅក្នុងសមុទ្រចិនខាងត្បូងរវាងបណ្តាប្រទេសចំនួន និងចិនជាឱកាសមួយដ៏ល្អសម្រាប់ទីក្រុងវ៉ាស៊ីតោន ក្នុងការលូកដៃចូលមកក្នុងអាស៊ីអាគ្នេយ៍។ គឺនៅក្នុងបរិបទបែបនេះហើយដែលតាំងពីឆ្នាំ២០០៩ មក អាមេរិក និងអាស៊ានបានងាកមករកគ្នា តាមរយៈជំនួបកំពូលអាស៊ាន អាមេរិកមួយឆ្នាំម្តង ហើយនៅឆ្នាំ២០០១ អាមេរិកបានក្លាយជាសមាជិកផ្លូវការនៃជំនួបកំពូលអាស៊ីបូព៌ា។ ច្បាប់អន្តរជាតិ ជាពិសេសច្បាប់សមុទ្រត្រូវបានគេលើកឡើងជាដំណោះស្រាយចំបងក្នុងជម្លោះនេះទោះបីជាគេឃើញថា ច្បាប់ទាំងនោះមិនមានឥទ្ធិពលចាប់បង្ខំទៅដល់រដ្ឋណាមួយឡើយ ហើយវានៅតែមានស្មុគស្មាញមួយចំនួនចំពោះការទទួលស្គាល់តំបន់ ឬដែនទឹកត្រួតស៊ីគ្នាជាជាងការអះអាងជាដែន

អធិតេយ្យរបស់រដ្ឋមួយជាក់លាក់។ ដូច្នេះយើងអាចមើលឃើញប្រវត្តិសាស្ត្រនៃជម្លោះ យន្តការដោះស្រាយជាទ្វេភាគី ពហុភាគី និងលើឆាកអន្តរជាតិ និងឥរិយាបថរបស់រដ្ឋនីមួយៗ និងការលូកជ្រែកជ្រែងរបស់ភាគីទីបី ដែលមានខ្លឹមសារដូចខាងក្រោម។

# ជំពូកទី១ កត្តាភូមិសាស្ត្រ ប្រវត្តិសាស្ត្រនៃជម្លោះសមុទ្រចិនខាងត្បូង

## ១. លក្ខណៈភូមិសាស្ត្រ និង ធនធានធម្មជាតិរបស់សមុទ្រចិនខាងត្បូង

សមុទ្រចិនខាងត្បូង ស្ថិតនៅក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ដែលមានទំហំសរុបប្រមាណ ៣.៥០០.០០០គីឡូម៉ែតការ៉េ ហើយមានប្រជុំកោះចំនួន៤នៅទីនោះដែលកោះ២កំពុងស្ថិតនៅក្នុងជម្លោះ និងកោះ២ទៀតគឺប្រជុំកោះផារ៉ាស្សែល (Paracels) និង ស្ព្រែតលី (Spratlys)។ មិនតែប៉ុណ្ណោះ [1] វាមានកោះ តូចៗចំនួន ២៥០ ផ្កាថ្ម ជីវចម្រុះ ថ្មប៉ប្រះទឹក ដីនៅជាប់កោះ និង មាត់សមុទ្រ និង កូនកោះតូចៗជាច្រើនទៀត។ ទីនោះត្រូវបានចាត់ទុកជាតំបន់ដឹកជញ្ជូនតាមផ្លូវទឹកដ៏សំខាន់ ដែលស្មើរនឹងមួយភាគបីនៃការដឹកជញ្ជូនតាមផ្លូវទឹករបស់ពិភពលោក និងជាកូនសោរមួយដ៏សំខាន់ ក្នុងការបើកទ្វារចេញទៅកាន់តំបន់សមុទ្រឥណ្ឌា និង ប៉ាស៊ីហ្វិក។ កោះ ប្រជុំកោះ និង ជួរកោះទាំងនេះ មួយភាគធំគ្មានមនុស្សរស់នៅ ហើយបានក្លាយទៅជាគោលដៅនៃការដណ្តើមអធិបតេយ្យភាព ក្នុងការទន្ទ្រានកាន់កាប់លើកោះទាំងនេះរបស់ប្រទេសជាច្រើនដែលមានព្រំដែនសមុទ្រជាប់ទៅនឹងតំបន់សមុទ្រចិនខាងត្បូងនេះ។

សមុទ្រចិនខាងត្បូងត្រូវបានកំណត់ទីតាំងយ៉ាងពិតប្រាកដនៅលើផែនទីពិភពលោកដែលៈ

- ខាងត្បូងជាប់នឹងសាធារណៈរដ្ឋប្រជាមានិតចិន និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម
- ខាងលិចជាប់នឹងសាធារណៈរដ្ឋហ្វីលីពីន
- ខាងកើតជាប់នឹងឧបទ្វីបម៉ាឡេ(Malay peninsula) និង កោះស្វម៉ាត្រា(Sumatra) រហូតដល់ច្រកសមុទ្រម៉ាឡាកា(Straits of Malacca)នៅផ្នែកខាងលិច និងជាប់កោះតៃវ៉ាន់នៃសាធារណៈរដ្ឋប្រជាមានិតចិន
- ខាងជើងជាប់នឹងកោះ Bangka-Belitung ដែលជាខេត្តរបស់សាធារណៈរដ្ឋឥណ្ឌូនេស៊ី និងកោះ Borneo ជារបស់ឥណ្ឌូនេស៊ីផងដែរ ដែលគេដឹងថាជាកោះធំបំផុតនៅក្នុងទ្វីបអាស៊ី និងជាកោះធំបំផុតទីបីនៅលើពិភពលោក។
- ខាងទិសនិរតីជាប់នឹងសាធារណៈរដ្ឋសិង្ហបុរី។

ដោយសារសមុទ្រចិនខាងត្បូងមានព្រំប្រទល់ជាប់ជាមួយប្រទេសជាច្រើន ដូនេះហើយទើបសមុទ្រមួយនេះក្លាយជាប្រធានបទដ៏រសើបសំរាប់ពិភពលោកនាពេលបច្ចុប្បន្ន ជាពិសេសរដ្ឋដែលទាក់ទងនឹងជម្លោះព្រំដែនទឹកដូចបានរៀបរាប់ខាងលើ។ តើកត្តាអ្វីខ្លះទើបអាចរដ្ឋទាំងអស់នោះហ៊ានអះ

[1] *mygola.* n.d. http://www.mygola.com/south-china-sea-p99543 (accessed May 05, 2014).

អាងលើដែនសមុទ្រមួយនេះ? យើងនឹងឃើញច្បាស់អំពីកត្តាជាច្រើនដែលបណ្ដាឲ្យរដ្ឋមានសិទ្ធិអះអាងដែនអធិបតេយ្យភាពរបស់ខ្លួនដោយផ្អែកតាមប្រវត្តិសាស្ត្រ និងភូមិសាស្ត្រដូចខាងក្រោម។

**ផែនទីសមុទ្រចិនខាងត្បូង**




## ២. ប្រវត្តិជម្លោះសមុទ្រចិនខាងត្បូង

ជម្លោះដែនអធិបតេយ្យភាពរវាងសាធារណៈរដ្ឋប្រជាមានិតចិន និង ប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដូចបានរៀបរាប់ខាងលើជុំវិញបញ្ហា នៃការអះអាងដើម្បីកាន់កាប់កោះទាំងនោះ នៅក្នុងសមុទ្រចិនខាងត្បូងបានកើតមាន និងកំពុងបន្តជាច្រើនទសវត្សមកហើយ។ ជម្លោះសមុទ្រចិនខាងត្បូងជាបញ្ហារសើបមួយរបស់ពិភពលោកដែលប្រទេសចិន វៀតណាម ហ្វីលីពីន ម៉ាលេស៊ី និងព្រុយណេប្រកួតប្រជែងដើម្បីទាញយកប្រយោជន៍រៀងៗខ្លួន ដើម្បីទទួលបានសិទ្ធិស្របច្បាប់ក្នុងការរុករកប្រេង ឧស្ម័ន និង សេរីភាពក្នុងការធ្វើនាវាចរណ៍នៅក្នុងដែនសមុទ្រនោះ។ កោះផារ៉ាសែ្សល (Paracels)ស្ថិតនៅផ្នែកខាងជើងនៃសមុទ្រចិនខាងត្បូង ដែលមានចម្ងាយស្មើគ្នាពីឆ្នេរសមុទ្រសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងសាធារណៈរដ្ឋប្រជាមានិតចិន។[2]នៅក្នុងឆ្នាំ១៩៧៤ ចិនបានប្រើកំលាំងយោធាបណ្ដេញកងទ័ពវៀតណាមចេញពីកោះផារ៉ាសែ្សល (Paracels) ដើម្បីធ្វើការកាន់កាប់ទាំងស្រុង ប៉ុន្តែប្រទេសវៀតណាមក៏បានអះអាងក្នុងការកាន់កាប់កោះនេះដែរ។ ចំណែកឯកោះស្ពែ្រតលី (Spratlys) មានកោះតូចៗច្រើនជាងមួយរយ និងជីវះចម្រុះជាច្រើន

[2] Beckman, Robert C. "The South China Sea Dispute: An International lawyer's View." *ASEAN AND THE SOUTH CHINA SEA DISPUTE*, 2011: 02.

ផងដែរ ហើយមានទំហំប្រហែល ៤១០.០០០ គីឡូម៉ែតការ៉េ ស្ថិតនៅចំកណ្តាលសមុទ្រចិនខាងត្បូង។ កោះស្ព្រែតលី (Spratlys) ត្រូវបានទាមទារដោយសាធារណៈរដ្ឋប្រជាមានិតចិន តៃវ៉ាន់ សាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្របពេលដែលប្រទេសហ្វីលីពីន ម៉ាឡេស៊ីនិង ព្រុយណេ បានបង្កើតតំបន់នេសាទនិងគ្រប់គ្រងថ្មប៉ប្រះទឹក ទោះបីជាខ្លួនមិនបានទាមទារជាផ្លូវការក៏ដោយ។

[3]ប្រជុំកោះទាំងនោះមិនត្រូវបានគេយកចិត្តទុកដាក់រហូតដល់ទសវត្សទី៧០ ប៉ុន្តែចាប់ពីពេលដែលប្រទេសពាក់ព័ន្ធទាំងនោះ យល់ព្រមទទួលស្គាល់សន្និសីទនៃអង្គការសហប្រជាជាតិលើកទីបីស្តីពី ច្បាប់សមុទ្រ ដែលអនុញ្ញាតឲ្យរដ្ឋទាំងអស់ធ្វើការអះអាងកាន់កាប់តំបន់សេដ្ឋកិច្ចផ្តាច់មុខ ប្រវែង ២០០ ម៉ាយ(Nautical Miles) ពីកោះ។ ការរំពឹងទុកចំពោះការកាន់កាប់ផ្ទៃសមុទ្រប្រវែង ២០០ម៉ាយ(Nautical Miles) ពីកោះបានចាប់ផ្តើមធ្វើឲ្យមានការចាប់អារម្មណ៍ការទាញផលប្រយោជន៍ពីសមុទ្រដែលមានសក្តានុពល ប្រេង ឧស្ម័ន និងការនេសាទត្រី។ យោងតាមសេចក្តីប្រកាសជាសកលឆ្នាំ១៩៩២ របស់សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថាអាស៊ាន (Association Southeast Asia Nations) ស្តីពីសមុទ្រចិនខាងត្បូង បានធ្វើឲ្យមានការតវ៉ាជាបន្តបន្ទាប់ទៅលើកោះមួយចំនួននៅក្នុងសមុទ្រចិនខាងត្បូង។ នៅក្នុងឆ្នាំ ១៩៩៥ ប្រទេសហ្វីលីពីនបានអះអាងដើម្បីកាន់កាប់មួយភាគទៅលើកោះស្ព្រែតលី (Spratlys) ត្រឹមតែ១០០ម៉ាយប៉ុណ្ណោះ បន្ទាប់ពីប្រទេសចិនធ្វើការកាន់កាប់តំបន់នេះទាំងស្រុង។

## កថាខណ្ឌទី១ ករណីប្រទេសចិន

### ១.ប្រវត្តិសាស្ត្រ

សាធារណៈប្រជាមានិតចិនត្រូវបានគេដឹងថា ជាប្រទេសមួយដែលមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចយ៉ាងឆាប់រហ័សបន្ទាប់ពីខ្លួនងាកមកចាប់យកសេដ្ឋកិច្ចទីផ្សារសេរីក្នុងឆ្នាំ ១៩៧៨។ ទាំងនេះជាលក្ខណៈមួយដែលធ្វើឲ្យផ្លាស់ប្តូរឥរិយាបថរបស់ខ្លួនកាន់តែខ្លាំងឡើងនៅក្នុងឆាកអន្តរជាតិ ជាពិសេសមហាយក្សមួយនេះបានតំឡើងសាច់ដុំរបស់ខ្លួនដាក់ប្រទេសសមាជិកអាស៊ានមួយចំនួនដែលពាក់ពន្ធ័ដោយផ្ទាល់ទៅនឹងជម្លោះដែនកោះនិងដែនសមុទ្រនេះ។

ជុំវិញជម្លោះសមុទ្រចិនខាងត្បូង ប្រទេសមួយនេះបានដើរតួរនាទីសំខាន់ជាងគេបង្អស់ទាំងដំណើរការជម្លោះនិងយន្តការដោះស្រាយ ពីព្រោះប្រទេសនេះត្រូវបានគេចោទប្រកាន់ដោយបណ្តាប្រទេសដទៃទៀតជាច្រើនដែលពាក់ព័ន្ធអំពីការចូលកាន់កាប់ខុសច្បាប់ទៅលើដីកោះ និង ដែន

[3] Beckman, Robert C. *National University of Singapore.* Feb 18, 2011. http://cil.nus.edu.sg/wp/wp-content/uploads/2009/09/Beckman-Paper-on-SCS-Dispute-ISEAS-ASC-18-Feb-2011-final.pdf (accessed May 06, 2014).

សមុទ្រចិនខាងត្បូងដែលមិនគោរពតាមការព្រមព្រៀងស្តីពី ការកំណត់ដែនសមុទ្ររបស់សិទ្ធិសីទអង្គការសហប្រជាជាតិ។ មហាយក្សមួយនេះតែងតែព្យាយាមពង្រឹងតំរូវការរបស់ខ្លួនដើម្បីបំពេញគុណភាពនៃការរស់នៅរបស់ប្រជាជន ដើម្បីពង្រឹងគំនិតជាតិនិយមរបស់ខ្លួននិងប្រកួតប្រជែងសេដ្ឋកិច្ចពិភពលោកជាមួយសហរដ្ឋអាមេរិចនិងមហាអំណាចដទៃទៀតនៅលើពិភពលោក។ [4]ការចូលកាន់កាប់ និង ការអះអាងរបស់ប្រទេសចិនគឺផ្អែកទៅលើការចូលរុករក និង ការកាន់កាប់ជាប្រវត្តិសាស្ត្រយូរជាងប្រទេសជិតខាងដទៃទៀតដែលបានអះអាងពីការដែលមានសិទ្ធិកាន់កាប់កោះទាំងនោះ។ បញ្ញាវន្ត និង ប្រជាជនចិនជាច្រើនបានអះអាងថាប្រទេសរបស់ខ្លួនបានរកឃើញកោះស្ព្រែតលី (Spratlys) ច្រើនជាង ២១០០ឆ្នាំមុន ក្នុងរាជកាលស្តេចហាន ហើយវត្តមានរបស់ប្រជាជនចិននៅទីនោះតាំងពីសតវត្សទី ១៩ បន្ទាប់ពីការចូលជ្រែតជ្រែកកាន់កាប់ដោយកងទ័ពរបស់ចក្រភពអង់គ្លេសនៅសតវត្សទី១៨។ លើសពីនេះទៀត ប្រទេសចិនបានអន្ទោម័តបង្កើតដែនទីផ្លូវការជាឯកតោភាគី ហើយធ្វើការប្រកាសជាអន្តរជាតិដើម្បីឲ្យរដ្ឋដទៃទទួលស្គាល់ថា សមុទ្រចិនខាងត្បូងជាកម្មសិទ្ធិរបស់ខ្លួន ទោះបីជាពេលខ្លះឥរិយាបថនេះត្រូវបានថ្កោលទោសពីបណ្តាលប្រទេសមួយចំនួន ជាពិសេសភាគីជម្លោះ និង មហាអំណាចសហរដ្ឋអាមេរិច។ [5]ទោះបីជាយ៉ាងណាក៏ ចិនក៏ចេះបន្ទន់ឥរិយាបថរបស់ខ្លួន ដោយអះអាងថានឹងស្វែងរកមធ្យោបាយទាំងឡាយដោយសន្តិវិធី និងរក្សាសន្តិភាពក្នុងតំបន់ជាមួយបណ្តាប្រទេសជុំវិញដើម្បីអភិវឌ្ឍន៍ និងវឌ្ឍនភាព។ សមុទ្រចិនខាងត្បូងបានក្លាយដក់ជាប់គំនិតជាតិនិយមរបស់កងទ័ព និងប្រជាជានចិនព្រោះពួកគេបានចាត់ទុកសមុទ្រចិនខាងត្បូងនេះ ជាតំបន់ស្លាប់រស់ ហើយកងទ័ពចិនបាននឹងកំពុងបង្កើនឲ្យអស់នូវសមត្ថភាពកងទ័ពជើងទឹកចិន ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការធានា ការពារអធិបតេយ្យភាពនៅលើសមុទ្រចិនខាងត្បូងនេះឲ្យបានសុក្រឹត ព្រមទាំងបានធ្វើគ្រប់បែបយ៉ាង ក្នុងការកំហិត ដល់រាល់ការជ្រៀតចូល ទោះបីអានុភាពណាមួយ រួមទាំងសហរដ្ឋអាមេរិក នៅក្នុងតំបន់សមុទ្រជុំវិញ និងតំបន់សមុទ្រសំខាន់ៗរបស់ចិនទៀតផង។

---

[4]Gjetnes, Marius. "THE LEGAL REGIME OF ISLANDS IN THE SOUTH CHINA SEA ." *Master Thesis of Law*, 2000: 13.

[5] ដកស្រង់ចេញពីសៀវភៅសមុទ្រចិនខាងត្បូងក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ ទំព័រទី ០៦ និពន្ធដោយ ហើស សិរីធន បោះពុម្ពផ្សាយខែឧសភា ឆ្នាំ ២០១៣

## ២.លក្ខណៈភូមិសាស្ត្រ




សាធារណៈរដ្ឋប្រជាមានិតចិន មានទីតាំងស្ថិតនៅតាមខ្សែបណ្តោយនៃឆ្នេរមហាសមុទ្រប៉ាស៊ីហ្វិក។ ហើយដីគោករបស់វាមានចំណាត់ថ្នាក់ធំលេខ៣ បន្ទាប់ពីប្រទេសរុស្ស៊ី និងប្រទេសកាណាដាហើយ ជាពិសេសប្រទេសអាមេរិចមានទំហំប្រហាក់ប្រហែលគ្នាទៅនឹងប្រទេសចិនផងដែរ។ ប្រទេសចិនលាតសន្ធឹងប្រវែង 5.026 គីឡូម៉ែត្រ ទូទាំងដីអាស៊ីបូព៌ា។ ប្រទេសនេះត្រូវបានគេកំណត់ព្រំដែនសមុទ្រឆ្ពោះទៅខាងកើតដោយមាន សមុទ្រចិនខាងកើត ឈូងសមុទ្រកូរ៉េ សមុទ្រលឿង ច្រកសមុទ្រតៃវ៉ាន់ និង សមុទ្រចិនខាងត្បូងដែលមានជម្លោះជាមួយបណ្តាលប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ និង មានព្រំប្រទល់ដីគោកជាប់នឹងរដ្ឋផ្សេងទៀតរបស់ខ្លួន ៣ផ្នែកពីកូរ៉េខាងជើងទៅកាន់ប្រទេសវៀតណាម។ ប្រទេសចិនត្រូវបានគេ ចែកចេញជាផ្លូវការនិងងាយស្រួលចូលទៅក្នុងតំបន់ម៉ាក្រូ៥ដូចគ្នាគឺ : ចិនខាងកើតស៊ីនជាំង ម៉ុងហ្គោលី និង ទីបេ តំបន់ខ្ពង់រាប ។ ពាក់កណ្តាល ភាគខាងកើត និងភាគខាងត្បូង នៃប្រទេសនេះ ឆ្នេរសមុទ្ររបស់ប្រទេសនេះ អមជាមួយនឹងកោះ នៅឈូងសមុទ្រគឺជា តំបន់មានជីជាតិ។ តំបន់ទំនាប និងជាមួយភ្នំតូចៗទាបនៅជើងភ្នំធំភាគច្រើនបំផុតជួយដល់ទិន្នផលផ្នែកកសិកម្មនិងប្រជាជន ។ ពាក់កណ្តាលភាគខាងលិច និងភាគខាងជើងនៃប្រទេសចិនគឺជាតំបន់នៃអាងស្តុក និងជាខ្ពង់រាបដែលរមៀលពីលើចុះក្រោមពីកំពូលភ្នំរហូតជើងភ្នំ ត្រូវបានគេហៅថាខ្ពង់រាបទីបេដែលមានលទ្ធភាពទាបក្នុងការទទួលផលកសិកម្ម ជាហេតុមិនសូវមានប្រជាជនរស់នៅទីនេះប៉ុន្មានទេ។

## កថាខណ្ឌទី២ ករណីប្រទេសព្រុយណេដារូយសាឡឹម

### ១.ប្រវត្តិសាស្ត្រ

ប្រទេសព្រុយណេបានប្រកាសថាថ្មប៉ប្រះទឹក (Louisa Reef) គឺស្ថិតនៅក្នុងដែនអធិបតេយ្យនៃសមុទ្រចិនខាងត្បូងគឺជាផ្នែកមួយនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខ ដោយយោងតាមសេចក្តីសម្រេចនៃអនុសញ្ញាស្តីពីច្បាប់សមុទ្ររបស់អង្គការសហប្រជាជាតិនៅក្នុងឆ្នាំ ១៩៨៩។ [6]ព្រុយណេត្រូវបានគេដឹងថា មិនត្រឹមតែអះអាងកាន់កាប់កោះស្ព្រែតលី (Spratlys) ប៉ុណ្ណោះទេ ថែមទាំងចង់ទាញយកថ្មនៅបាតសមុទ្រជុំវិញតំបន់នោះ ក្នុងខណៈពេលរដ្ឋដទៃទៀតគិតថាព្រុយណេមិនបានអះអាងកាន់កាប់អ្វីទាំងអស់ គ្រាន់តែសុំធ្វើគមនាគមន៍នៅតំបន់សេដ្ឋកិច្ចផ្តាច់មុខក្នុងសមុទ្រចិនខាងត្បូង។ ការអះអាងរបស់ព្រុយណេនៃការកាន់កាប់ថ្មនៅបាតសមុទ្រលាតសន្ធឹងប្រវែង ២០០ម៉ាយ (Nautical Miles) ហាក់បីដូចជាមិនសមស្របទៅនឹងអនុសញ្ញាស្តីពីច្បាប់សមុទ្រ។ តែបើត្រឹមតែអះអាងដូចឆ្នាំ ១៩៨២ ដែលសុំតំបន់ ២០០ម៉ាយ (Nautical Miles) ជាតំបន់នេសាទ និងផ្លូវពាណិជ្ជកម្ម វាបានចង្អុលបង្ហាញពីការទទួលស្គាល់យ៉ាងពិតប្រាកដរបស់ព្រុយណេទៅលើអនុសញ្ញាស្តីពី ច្បាប់សមុទ្រ ហើយអាចជាឧទាហរណ៍ដ៏ល្អសម្រាប់ភាគីដែលពាក់ព័ន្ធនឹងសមុទ្រចិនខាងត្បូងដទៃទៀត។

### ២.លក្ខណៈភូមិសាស្ត្រ




ប្រទេសព្រុយណេដារូសាឡឹមស្ថិតនៅលើឆ្នេរភាគពាយព្យនៃកោះកាលីម៉ាន់តាន់នេះ។ រាជធានី Bandar Series Begawan ស្ថិតនៅឆ្ងាយពីមាត់សមុទ្រនៅលើទន្លេប្រ៊ុយណេ។ ព្រុយណេមានទំហំ 5.765 គីឡូម៉ែត្រការ៉េនិងត្រូវបានបែងចែកជាពីរផ្នែក ដែលត្រូវបានហ៊ុំព័ទ្ធដោយរដ្ឋសារ៉ាវ៉ាក់របស់ម៉ាឡេស៊ី។ [7]ដីតិចតួចរបស់ប្រ៊ុយណេត្រូវបានគេបង្កបង្កើនផលហើយមានចំនួនប្រមាណជា

[6] Gjetnes, Marius. "THE LEGAL REGIME OF ISLANDS IN THE SOUTH CHINA SEA ." *Master Thesis of Law*, 2000: 13.
[7]AQUASTAT. "Irrigation in Southern and Eastern Asia in figures." Brunei Darussalam, 2011.

13 000 ហិចតាដែលមានប្រមាណជា 2,5 ភាគរយនៃផ្ទៃដីសរុប និងប្រហែល 60 ភាគរយគ្របដណ្តប់ដោយព្រៃ។ ឆ្នេរព្រុយណេរបស់លាតសន្ធឹងប្រមាណ 161 គីឡូម៉ែត្រតាមបណ្តោយសមុទ្រចិនខាងត្បូង។ ព្រុយណេនៅជិតផ្លូវសមុទ្រ ដ៏សំខាន់មួយ ដែលបណ្តោយតាមសមុទ្រចិនខាងត្បូងជាប់នឹងមហាសមុទ្រឥណ្ឌា និងប៉ាស៊ីហ្វិក។

## កថាខណ្ឌទី៣ ករណីប្រទេសវៀតណាម

### ១.ប្រវត្តិសាស្ត្រ

ការអះអាងរបស់ប្រទេសវៀតណាមជុំវិញអធិបតេយ្យភាព ទៅលើកោះនៅក្នុងសមុទ្រចិនខាងត្បូងផ្អែកសកម្មភាពប្រវត្តិសាស្ត្ររបស់ខ្លួនចាប់ពីសតវត្សទី១៧ដល់១៩។ ទោះបីជាឯកសារប្រវត្តិសាស្ត្ររបស់ស្តេច Le Thanh Tong នៅសតវត្សទី ១៥ បានបង្ហាញភស្តុតាងថាកោះស្ពែតលី (Spratlys) ជាដែនដីរបស់វៀតណាមយ៉ាងពិតប្រាកដ។ រដ្ឋាភិបាលនៃប្រទេសវៀតណាមបានលើកឡើងនូវបញ្ហានៅក្នុងឆ្នាំ ១៩៧៩ និង ១៩៨២ នៅលើក្រដាសសពីរសន្លឹកដែលនិយាយអំពីអធិបតេយ្យភាពជុំវិញកោះស្ពែតលី (Spratlys) និងកោះផារ៉ាស៊ែល (Paracels) ដែលជាភស្តុតាងប្រវត្តិសាស្ត្របានចងក្រងទុក។ [8]ទោះបីជាយ៉ាងណាក៏ដោយភស្តុតាងរបស់វៀតណាមនៅមានភាពទន់ខ្សោយនៅឡើយពីព្រោះលក្ខណៈនៃការបញ្ជាក់ និងការចែងចែករវាងកោះស្ពែតលី (Spratlys) និងកោះផារ៉ាស៊ែល (Paracels) មានលក្ខណៈទូទៅពេក។ វាដូចទៅនឹងការអះអាងរបស់ចិនដែលពឹងផ្អែកទៅលើប្រវត្តិសាស្ត្រទាំងស្រុង។

ការអះអាងរបស់ប្រទេសវៀតណាមទៅលើកោះស្ពែតលី (Spratlys) ផ្អែកទៅលើការអះអាងរបស់បារាំងក្នុងសម័យអាណានិគមឆ្នាំ ១៩៣៣។ ទោះបីជាយ៉ាងណាក៏ដោយបារាំងមិនដែលសម្រេចបានការអះអាងនេះទេ ហើយវាត្រូវបានគេយល់ថាគ្មានលក្ខណៈស្របច្បាប់ទេ។ ដូច្នោះហើយវៀតណាមមិនគួរធ្វើការអះអាង ដោយយកការអះអាងរបស់បារាំងជាមូលដ្ឋាននោះទេ។ វៀតណាមមិនបានអះអាងទៅលើតំបន់សមុទ្រចិនខាងត្បូងនោះទេ ប៉ុន្តែប្រទេសនេះបានគូសបន្ទាត់មូលដ្ឋានតាមខ្សែបណ្តោយដែលត្រូតទៅនឹងការអះអាងរបស់រដ្ឋដទៃទៀត។ សំខាន់លើសពីនេះទៅទៀត បញ្ហានេះត្រូវបានគេដឹងថាជាការពិតដែលវៀតណាមមានភាពយឺតយ៉ាវក្នុងការសុំកាន់កាប់ថ្មនៅក្នុងទឹកនៅក្នុងជុំវិញកោះស្ពែតលី (Spratlys) ដែលជាបញ្ហាមួយគួរយកមកពិចារណា

[8]Valero, M.C. "Spartly Archipelago Dispute: Is the Question of Soverignty Still Relevant?" Marine Policy 314, 1994, 314.

នៅពេលដែលសមុទ្រចិនខាងត្បូងត្រូវបានកំណត់យ៉ាងត្រឹមត្រូវតាមច្បាប់ ដែលមិនអាចផ្អែកលើការអះអាងរបស់រដ្ឋដែលផ្អែកទៅលើប្រវត្តិសាស្ត្រទាំងស្រុងនោះទេ។

## ២.លក្ខណៈភូមិសាស្ត្រ




ប្រទេសវៀតណាម មានទីតាំងស្ថិតនៅលើឧបទ្វីបឥណ្ឌូចិននៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ វាមានព្រំដែនគោកដ៏វែងគឺ 4.550 គីឡូម៉ែតជាប់ព្រំដែនប្រទេសចិន ព្រំដែនខាងជើងជាប់ប្រទេសឡាវ និងខាងលិចជាប់ប្រទេសកម្ពុជា និងខាងកើតជាប់សមុទ្រចិនខាងត្បូង នៃមហាសមុទ្រប៉ាស៊ីហ្វិក។ នៅលើផែនទីនេះប្រទេសវៀតណាមគឺជាបន្ទះរាងអក្សរ S ជាដីដែលលាតសន្ធឹងពី 23 ° 23 ' ទៅ 8 ° 27 ' ខ្សែរយៈទទឹងខាងជើង។ ប្រវែងសរុបរបស់ប្រទេសនេះគឺ 1.650 គីឡូម៉ែត្រពីចំណុចភាគខាងជើងទៅចំណុចខាងត្បូង។ ប្រវែងទទឹងរបស់វាគិតពីឆ្នេរសមុទ្រភាគខាងកើតទៅព្រំដែនខាងលិចនោះគឺប្រវែងប្រហែល 500គីឡូម៉ែត្រនៅក្នុងផ្នែកមួយធំបំផុត និងប្រវែងប្រមាណ50គីឡូម៉ែត្រនៅផ្នែកដែលចង្អៀតបំផុត។ ទីតាំងភូមិសាស្ត្រចម្រុះរបស់ប្រទេសនេះមាន កូនភ្នំ ភ្នំ ដីសណ្ត ច្រាំងសមុទ្រ ឆ្លុះបញ្ចាំងពីប្រវត្តិដ៏យូរលង់នៃ ភូគព្ភវិទ្យា ។ ទីតាំងភូមិសាស្ត្រ គឺទាបពីភូមិភាគពាយ័ព្យទៅអាគ្នេយ៍ដែលអាចត្រូវបានអង្កេតឃើញយ៉ាងច្បាស់នៅក្នុងលំហូរនៃទន្លេដ៏ធំមួយនេះ។

# កថាខណ្ឌទី៤ ករណីប្រទេសម៉ាឡេស៊ី

## ១.ប្រវត្តិសាស្ត្រ

ប្រទេសម៉ាឡេស៊ីបានអះអាងថាកោះចំនួន១២ និងចំណុចពិសេសនៅក្នុងតំបន់ប្រជុំកោះស្ព្រែតលី (Spratlys) និងការបង្ហាញហេតុផលត្រឹមត្រូវក្នុងការទាមទារតំបន់ខ្ពង់រាបបាតសមុទ្រ (continental shelf) និង ការរកឃើញនិងការកាន់កាប់នេះ។ តំបន់ខ្ពង់រាបបាតសមុទ្ររបស់ប្រទេសម៉ាឡេស៊ីនេះមានជម្លោះនៅក្នុងឆ្នាំ១៩៦៦ និង ១៩៦៩។ ទោះបីជាយ៉ាងណាក៏ដោយការអះអាងរបស់ប្រទេសម៉ាឡេស៊ីដោយផ្អែកលើផែនទីថ្មីរបស់ខ្លួនដែលបានកំណត់ពីព្រំដែនទឹកនិងកោះដែលបង្កើតក្នុងឆ្នាំ១៩៧៩។ ការអះអាងរបស់ប្រទេសម៉ាឡេស៊ីដើម្បីសុំកាន់កាប់កោះមួយចំនួនក្នុងប្រជុំកោះស្ព្រែតលី (Spratlys) ដូចទៅនឹងការអះអាងរបស់ប្រទេសហ្វីលីពីនផងដែរ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះគ្មានច្បាប់អន្តរជាតិណាមួយគាំទ្រទៅលើការអះអាងនេះទេ។ ការសន្មត់របស់ម៉ាឡេស៊ីគឺជាភាពទន់ខ្សោយមួយដ៏សម្បូងដែលធ្វើឲ្យរដ្ឋដទៃទៀតមិនអាចទទួលយកបាន ទោះបីជាឆ្នាំ១៩៨០ ម៉ាឡេស៊ីបានប្រកាសកាន់កាប់តំបន់សេដ្ឋកិច្ចផ្តាច់មុខមានចម្ងាយ២០០ ម៉ាយ(Nautical Miles) ជាផ្លូវការក្នុងរដ្ឋរបស់ខ្លួនក៏ដោយ។

## ២.លក្ខណៈភូមិសាស្ត្រ




ប្រទេសម៉ាឡេស៊ីមានរដ្ឋសហព័ន្ធចំនួនដប់បី នៅក្នុងតំបន់អាស៊ីអាគ្នេយ៍នៅលើឧបទ្វីបម៉ាឡេ និងមានតំបន់ភូមិសាស្ត្រពីរបានបែងចែកជាសមុទ្រចិនខាងត្បូង និងឧបទ្វីបម៉ាឡេស៊ី ឬម៉ាឡេស៊ីខាងលិច កោះកាលីម៉ាន់តាន់ប្រទេសម៉ាឡេស៊ីនិងប្រទេសម៉ាឡេស៊ីឬប្រទេសម៉ាឡេស៊ីខាងកើត។ ប្រទេសម៉ាឡេស៊ីស្ថិតនៅក្នុងតំបន់អាស៊ីខាងត្បូងភាគខាងកើត-ជាមួយប្រទេសថៃនិងមួយភាគបីនៃកោះកាលីម៉ាន់តាន់ជាប់ព្រំដែនភាគខាងជើងនៃឧបទ្វីបនិងព័ទ្ធជុំវិញ ដោយប្រទេសឥណ្ឌូនេស៊ី

ប្រ៊ុយណេ និងសមុទ្រចិនខាងត្បូងនិងភាគខាងត្បូងនៃប្រទេសវៀតណាម។ ប្រទេសនេះក៏រួមបញ្ចូលទាំងការសាបានិងសារ៉ាវ៉ាក់នៅលើកោះកាលីម៉ាន់តាន់ខាងកើតនេះ។ វាជាទីតាំងភូមិសាស្ត្រ 2'30 ° N ហើយ 112'30 ° E។

ព្រំប្រទល់សរុប 2.669 គីឡូម៉ែត្រដីមួយជាមួយប្រ៊ុយណេគ្របដណ្តប់ 381 គីឡូម៉ែត្រប្រទេសម៉ាឡេស៊ីឥណ្ឌូនេស៊ី 1.782 គីឡូម៉ែត្រ និងប្រទេសថៃ 506 គីឡូម៉ែត្រ ។ ច្រាំងសមុទ្រគ្របដណ្តប់សរុប 4.675 គីឡូម៉ែត្រដែលមានឧបទ្វីបម៉ាឡេស៊ីជាប់ព្រំដែន 2.068 គីឡូម៉ែត្រនៅភាគខាងត្បូងនៃប្រទេសថៃភាគខាងជើងនៃប្រទេសសិង្ហបុរីនិងភាគខាងកើតនៃកោះស៊ូម៉ាត្រាឥណ្ឌូនេស៊ីនិងម៉ាឡេស៊ីខាងកើតដោយមាន 2.607 គីឡូម៉ែត្រដែលមានទីតាំងស្ថិតនៅលើកោះកាលីម៉ាន់តាន់និងការចែករំលែកព្រំដែនជាមួយប្រ៊ុយណេនិងឥណ្ឌូនេស៊ីមួយ ។

## កថាខណ្ឌទី៥ ករណីប្រទេសហ្វីលីពីន

### ១.ប្រវត្តិសាស្ត្រ

ការអះអាងរបស់ប្រទេសហ្វីលីពីនមុនការអះអាងរបស់ប្រទេសចិន និងប្រទេសវៀតណាម ហើយផ្អែកទៅលើការរកឃើញ"discovery"នៃកោះមួយចំនួនដោយពាណិជ្ជករហ្វីលីពីនមានឈ្មោះថា Thomas Cloma នៅក្នុងឆ្នាំ ១៩៤៧។ [9]លោក Cloma បានប្រកាសការបង្កើតនៃរដ្ឋថ្មីមួយដែលលោកបានហៅថា "Kalayaan" ហៅថាដែនដីសេរីភាព (Freedom-land) ក្នុងឆ្នាំ 1957 ហើយទោះជាយ៉ាងណាក៏ដោយគ្មានរដ្ឋាភិបាលណាមួយប្រកាសទទួលស្គាល់រដ្ឋថ្មីមួយនេះ ដែលបានអះអាងដោយគាត់នោះទេ។ លើសពីនេះទៅទៀតវាជាការសំខាន់ណាស់សម្រាប់ប្រទេសហ្វីលីពីនដែលកោះនេះបានក្លាយទៅជាកម្មសិទ្ធិរបស់ខ្លួន (nullius res) បន្ទាប់ពីការចាកចោលរបស់ជប៉ុនក្រោយសង្គ្រាមលោកលើកទី២។ ជាហេតុផលតែមួយគត់របស់លោក Cloma មានសិទ្ធិស្របច្បាប់ដើម្បីអះអាងលើតំបន់នោះ ។

[9] Gjetnes, Marius. "THE LEGAL REGIME OF ISLANDS IN THE SOUTH CHINA SEA." Masters Thesis of Law, Norway, 2000.

## ២.លក្ខណៈភូមិសាស្ត្រ




ប្រទេសហ្វីលីពីនជាប្រទេសកោះមួយដែលមានទីតាំងស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រវាងសមុទ្រហ្វីលីពីននិងសមុទ្រចិនខាងត្បូងភាគខាងកើតនៃប្រទេសវៀតណាម។ នេះបើយោងតាមភូមិសាស្ត្ររបស់ប្រទេសហ្វីលីពីនប្រទេសនេះត្រូវបានបង្កើតឡើង 7.107 កោះដោយមានផ្ទៃដីសរុប 300.000 គីឡូម៉ែត្រក្រឡា។ តំបន់ដីរបស់ប្រទេសនេះមានទំហំ 298.170 គីឡូម៉ែត្រក្រឡាខណៈពេលដែលតំបន់ទឹកមានទំហំត្រឹមតែ 1.830 គីឡូម៉ែត្រក្រឡានៃផ្ទៃដីទាំងមូលនិងមានជួរសមុទ្រ 36.289 គីឡូម៉ែត្រ។ លក្ខណៈពិសេសមួយដ៏សំខាន់នៃភូមិសាស្ត្រនៃប្រទេសហ្វីលីពីនគឺថាប្រទេសនេះគឺជាផ្នែកមួយនៃប្រព័ន្ធធ្លលោកខាងលិចនៅតំបន់ប៉ាស៊ីហ្វិក ដែលត្រូវបានកំណត់ដោយភ្នំភ្លើងសកម្ម។ កោះទាំងអស់របស់ប្រទេសគឺងាយនឹងការរញ្ជួយដី។ ប្រទេសជិតខាងជិតបំផុតរបស់ប្រទេសនេះគឺ តៃវ៉ាន់នៅភាគខាងជើង និងប្រទេសម៉ាឡេស៊ីនិងឥណ្ឌូនេស៊ីនៅភាគខាងត្បូង។ រាជធានីរបស់ប្រទេសនេះត្រូវបានទីក្រុងម៉ានីលដែលមានទីតាំងស្ថិតនៅលើកោះតំបន់ Luzon ។

# ជំពូកទី ២៖ ស្ថានភាពជម្លោះសមុទ្រចិនខាងត្បូង

ស្ថានភាពជម្លោះសមុទ្រចិនខាងត្បូងរហូតមកទល់ពេលនេះ នៅតែមានភាពតានតឹងដែលមិនដឹងច្បាស់ថារដ្ឋណាមួយមានសិទ្ធិស្របច្បាប់កាន់កាប់ទៅលើកោះជម្លោះនោះទេ។ ការធ្វើសមយុទ្ធយោធាក៏អាចក្លាយជាសញ្ញានៃការកើនឡើងកំដៅនៃជម្លោះ។ ការលូកដៃចូលរបស់មហាអំណាចដទៃទៀតជាពិសេសសហរដ្ឋអាមេរិចជាបញ្ហារសើបរបស់នយោបាយពិភពលោក។ ក្នុងរដ្ឋការរបស់លោកអូបាម៉ាបានបង្វែរគោលនយោបាយការបរទេសរបស់ខ្លួនមកក្នុងតំបន់អាស៊ី ជាពិសេសបញ្ហាសមុទ្រចិនខាងត្បូងដោយជាក់ស្តែង គឺការធ្វើសមយុទ្ធយោធាជាមួយសាធារណៈរដ្ឋហ្វីលីពីន។ បញ្ហាសមុទ្រចិនខាងត្បូងត្រូវបានគេចាត់ទុកថាជាបញ្ហារសើបរបស់ពិភពលោកក្នុងសតវត្សទី ២១។ ពេលខ្លះ វាក៏ក្លាយជាមេរោគរាំងស្ទះដំណើរការសេដ្ឋកិច្ចពិភពលោក និងក្នុងតំបន់ផងដែរ ឧទាហរណ៍ភាពតានតឹងរវាងហ្វីលីពីននិងចិន។ ទោះបីជាយ៉ាងណាក៏ដោយ ភាគីទាំងអស់តែងតែខិតខំស្វែងរកដំណោះស្រាយ ដោយសន្តិវិធី តាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ឬកិច្ចប្រជុំអន្តរជាតិដូចជាកិច្ចប្រជុំអាស៊ានជាដើម តាមរយៈដំណើរនៃការចេញសេចក្តីថ្លែងការណ៍នានា និងក្រមប្រតិបត្តិសមុទ្រចិនខាងត្បូងជាដើម។

## កថាខណ្ឌទី ១៖ ឥទ្ធិពលនៃជម្លោះក្នុងទំនាក់ទំនងអន្តរជាតិ

នៅក្នុងអតីតកាល ជាពិសេសនៅចន្លោះទសវត្សទី ៦០ និង ៧០ បណ្តាប្រទេសអាស៊ីអាគ្នេយ៍តែងតែចាត់ទុកចិនថាជាគ្រោះថ្នាក់មួយដ៏ធំ។ កាលជំនាន់នោះចិនជាគ្រោះកុម្មុយនិស្តសម្រាប់ឥណ្ឌូនេស៊ី ថៃ ហ្វីលីពិន សិង្ហបុរី និង ភូមា។ ប្រទេសទាំងនេះខ្លាចចិនខ្លាំង និងព្រួយបារម្ភជាពិសេសនៅក្នុងឆ្នាំ ១៩៧៥ នាពេលដែលឥណ្ឌូចិនក្លាយជាកុម្មុនិស្ត។ ក្រោយមកទៀតនៅក្នុងឆ្នាំ ១៩៧៩ បណ្តាប្រទេសអាស៊ីអាគ្នេយ៍ភាគច្រើននាំគ្នាចាត់ទុកចិនថាជាគ្រោះថ្នាក់យោធាពីព្រោះកាលមុននោះកងទ័ពចិនបានវាយប្រហារទៅលើប្រទេសវៀតណាម ដែលហ៊ានវាយរំលំរបបខ្មែរក្រហមនិងហ៊ានចូលកាន់កាប់ប្រទេសកម្ពុជា។

[10]ផ្ទុយទៅវិញសព្វថ្ងៃនេះ ជាទូទៅបណ្តាប្រទេសទាំង ១០ របស់អាស៊ានមានទំនាក់ទំនងល្អជាមួយចិនល្អជាសម័យសង្គ្រាមត្រជាក់។ មិនតែប៉ុណ្ណោះអាស៊ានថែមទាំងគាំទ្រចិននិងទទួលស្គាល់គោលការណ៍ប្រទេសចិនតែមួយទៀតផងលើឆាកអន្តរជាតិ។ នៅក្នុងបរិបទនេះតាំងពីដើម

[10] ដកស្រង់ចេញពីសៀវភៅ ចម្បាំងត្រជាក់រវាងអាមេរិកនិងចិន ទំព័រទី ១២១និង១២២ និពន្ធដោយ ហ្សង់ ហ្វ្រង់ស័រតាន់ បោះពុម្ពផ្សាយនៅថ្ងៃទី១២ ខែ មិថុនា ឆ្នាំ ២០១៤ ដោយលោក ពុយ គា

ទសវត្សទី ៩០ មកចិនបាននឹងកំពុងបន្តជំរុញកូនអុករបស់គេបន្តិចម្តងៗចូលក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ដោយសារតែការទូត សេដ្ឋកិច្ច វប្បធម៌ និងដោយសារការប្រើប្រាស់នយោបាយដ៏ប្រសព្វក្នុងជម្លោះសមុទ្រចិនខាងត្បូង។ ចិនប្រើអំណាចទន់ និងនយោបាយ ឈ្នះ ឈ្នះក្នុងគោលដៅពង្រីកឥទ្ធិពល និងលាងសំអាតកេរ្តិ៍របស់ខ្លួនក្នុងអាស៊ីអាគ្នេយ៍។

ជាងពីរទសវត្សចុងក្រោយនេះ ជាទូទៅអាស៊ានកក់ក្តៅ ក្នុងចិត្តជាងការសម័យសង្គ្រាមត្រជាក់ ពីព្រោះថ្នាក់ដឹកនាំចិនឲ្យតម្លៃទៅលើការអភិវឌ្ឍសេដ្ឋកិច្ចជាងឥទ្ធិពលមនោគមន៍វិជ្ជា ហើយពីព្រោះសុន្ទរកថារបស់ថ្នាក់ដឹកនាំចិនសំដៅចង់បានសន្តិភាព និងស្ថេរភាពក្នុងប្រទេសចិន និងតំបន់ជុំវិញ។ នៅក្នុងន័យនេះ នៅឆ្នាំ២០០៤ វេន ជៀប៉ៅ (Wen Jiabao) ដែលជានាយករដ្ឋមន្ត្រីជំនាន់នោះ បានប្រដូចប្រទេសចិនទៅនឹងសត្វដំរីដ៏ស្លូតមួយ ដែលគ្មានបំណងអាក្រក់ចង់បៀតបៀនអាស៊ានឡើយ។ តាមរយៈនយោបាយទន់ ចិនបាននឹងពង្រឹងឥទ្ធិពលវប្បធម៌របស់ខ្លួនទៅលើភូមិភាគអាស៊ីអាគ្នេយ៍ជាច្រើនដែលមើលទៅហាក់ដូចជាស្អិតរមួនជាខ្លាំង។ គេឃើញថាមានតែបញ្ហាសមុទ្រចិនខាងត្បូងតែមួយគត់ជាហេតុធ្វើឲ្យប្រទេសដែលពាក់ពន្ធ័នឹងជម្លោះ និងចិនមានភាពតឹងតែងជាខ្លាំងពីព្រោះការដណ្តើមផលប្រយោជន៍រៀងៗខ្លួន។ ការមិនអាចស្វែងរកភាពស្របគ្នា ឬកិច្ចព្រមព្រៀងទៅលើដែនអធិតេយ្យទឹកនេះវាហាក់ដូចជាឥរិយាបថបង្ករឿងរបស់នីមួយៗ ជាមួយចិន។ ប៉ុន្តែជាការពិតណាស់ចិនហាក់ដូចជាទាមទារហួសហេតុពេកហើយរហូតដល់ទៅ ៩០% សមុទ្រចិនខាងត្បូងទាំងមូល។ តើប្រទេសណាមួយអាចយល់ព្រមទៅលើការទាមទារបែបនេះ? ដូច្នេះយើងនឹងយល់កាន់តែច្បាស់ពីមហិច្ឆតារបស់ចិន សកម្មភាពនិងឥរិយាបថរបស់ប្រទេសនីមួយៗដូចខាងក្រោមនេះ។

## ១.មហិច្ឆិតានិងយុទ្ធសាស្ត្ររបស់ចិនលើសមុទ្រចិនខាងត្បូង

សមុទ្រចិនខាងត្បូងដែលចិនហៅថាជាច្រកសមុទ្ររបស់ខ្លួន មានប្រវត្តិសាស្ត្រជីកឬសជីកគល់ជាមួយប្រទេសជាច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍។[11] សមុទ្រចិនខាងត្បូងជាគន្លឹះសំខាន់ ជាមហិច្ឆិតាធំបំផុតរបស់ចិន ដោយអំពើទាំងនេះត្រូវបានដាក់នៅក្នុងរបៀបវារៈមួយដ៏ពិសេសបំផុត សំណូមពរនៃការទាមទាររបស់ចិន នៅលើសមុទ្រចិនខាងត្បូងត្រូវបានបង្ហាញឡើងតាមរយៈផែនទីអក្សរ U ដែលខ្សែបន្ទាត់របស់អក្សរ U នេះ ហាក់បីដូចជាបានរត់ជុំសមុទ្រចិនខាងត្បូងដោយផ្លូវរត់នេះបាន

[11] ដកស្រង់ចេញពីសៀវភៅសមុទ្រចិនខាងត្បូងក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ ទំព័រទី ៤៦ និពន្ធដោយ ហើស សិរីធន បោះពុម្ពផ្សាយខែឧសភា ឆ្នាំ ២០១៣

កាត់ទទឹងបណ្តាផ្លូវទឹកដ៏សំខាន់ទាំងអស់ លើតំបន់សមុទ្រចិនខាងត្បូង។ ប្រទេសចិនស្គាល់ខ្លួនឯងយ៉ាងច្បាស់ថាជាប្រទេសមានប្រវត្តិសាស្ត្រយូរជាងគេ ហើយឆ្លងកាត់វត្តមានយោធាលើតំបន់នោះច្រើនលើកច្រើនសារនៅតំបន់នោះ ដែលជាហេតុធ្វើឲ្យចិនមានយុទ្ធសាស្ត្រយ៉ាងរឹងមាំដើម្បីទាមទារដែនទឹកមួយភាគធំនេះ។ មើលទៅ គ្មានផ្លូវអាចធ្វើឲ្យចិនអាចបន្ទន់ឥរិយាបថបាននោះទេទៅលើបញ្ហាដ៏ក្តៅគគុកមួយនេះព្រោះ សេដ្ឋកិច្ចរបស់ចិនរីកចម្រើនយ៉ាងឆាប់រហ័សនៅក្នុងការប្រកួតប្រជែងជាអន្តរជាតិ។ [12] នៅឆ្នាំ២០១៤ ប្រទេសចិនបានអះអាងអំពីការពង្រីកកម្លាំងយោធារបស់ខ្លួនចំនួន ១២.២% ដើម្បីការពារបន្ថែមផ្លូវអាកាស និងមានសព្វាវុធទំនើប លើសពីនេះទៅទៀតប្រទេសចិនបានទាមទារគ្រប់គ្រងកៅសិបភាគរយ នៃផ្ទៃសមុទ្រ ៣.៥០០.០០០គីឡូម៉ែតការ៉េស្មើនឹង១.៣៥ លានម៉ាយនៃសមុទ្រចិនខាងត្បូង ក្នុងទិសដៅកេងចំនេញធនធានធម្មជាតិដ៏មហាសាលក្នុងសមុទ្រនោះ ស្របពេលដែលប្រទេសហ្វីលីពីន ម៉ាឡេស៊ី ព្រុយណេ វៀតណាម ទាមទារផ្ទៃកមួយចំនួននៃតំបន់នោះដែរ។ គេសង្កេតឃើញថា យុទ្ធសាស្ត្ររបស់ចិននៅតំបន់អាស៊ីអាគ្នេយ៍មានការវិវត្តន៍ទៅមុខកាន់តែរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ ដោយការពង្រឹងទំនាក់ទំនងសេដ្ឋកិច្ចរបស់ខ្លួននៅក្នុងតំបន់ ស្របពេលដែលសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិច និងសហភាពអឺរ៉ុបរង្គោះរង្គើដូច្នេះ វាជាឱកាសមាស ឱកាសពេជ្រសម្រាប់ចិនក្លាយជាដៃគូរ ពាណិជ្ជកម្មដ៏សំខាន់បំផុតរបស់សមាជិកអាស៊ាន។ នាយប់ថ្ងៃទី ១៨ មិថុនានេះ ដែលចិនបានផ្សាយយ៉ាងទូលំទូលាយតាមរយៈអាជ្ញាធរប៉េកាំងផ្សាយនៅហុងកុងថា ចិនបានបំពេញការងារត្រៀមយ៉ាងល្អសុក្រឹតលើផ្នែកយោធាក្នុងករណីដែលពួកប្រទេស មានការពាក់ពន្ធ័ មានសកម្មភាពបង្កហេតុណាមួយ លើតំបន់សមុទ្រចិនខាងត្បូង គឺពួកគេនឹងទទួលរងនូវការវាយបកយ៉ាងធ្ងន់ធ្ងរ។ មិនត្រឹមតែប៉ុណ្ណោះអាជ្ញាធរចិនបានប្រើពាក្យយ៉ាងមុតថា ប្តេជ្ញាមិនអង្គុយមើលសភាពការណ៍សោះឡើយ។ នេះជាការសំដែងឥរិយាបថមួយយ៉ាងខ្លាំងក្លាបំផុតរបស់អ្នកកាន់អំណាចចិន បន្ទាប់ពីសភាពការណ៍លើតំបន់សមុទ្រចិនខាងត្បូង ចាប់ពុះកញ្ជ្រោលឡើងមិនឈប់ឈរនោះព្រោះ មុននេះជាផ្លូវការនិង ចំហរចិនតែងតែប្រើភាសាដោយសង្កត់ធ្ងន់មកលើការ ដោះស្រាយដោយសន្តិវិធី មិនប្រើប្រាស់កម្លាំងបាយ និងជាប្រទេសជិតដ៏ល្អតែប៉ុណ្ណោះ។

[12] Reporting by Michael Martina, Li Hui and Ben Blanchard and David Brunnstrom. *The REUTERS.* Mar 04, 2014. http://www.reuters.com/article/2014/03/05/us-china-parliament-defence-idUSBREA2400H20140305 (accessed May 09, 2014).

# ២. ដំណើរការជម្លោះរវាងចិន និង បណ្ដាប្រទេសសមាជិកអាស៊ាន

## ២.១ ជម្លោះចិន និង ហ្វីលីពីន

ទំនាក់ទំនងរវាងហ្វីលីពីនជាមួយចិន មានភាពល្អប្រសើរត្រឹមតែពេលសហរដ្ឋអាមេរិករវល់យកចិត្តទុកដាក់មកតំបន់ភូមិសាស្ត្រនយោបាយផ្សេងទៀតដូចនៅអាស៊ីកណ្ដាល មជ្ឈឹមបូព៌ា តំបន់ Balkan តែភ្លេចពុំសូវអើពើមកលើតំបន់អាស៊ីឡើយសោះ។ ចិនដឹងច្បាស់ថាហ្វីលីពីនជាផ្ទះបាយរបស់សហរដ្ឋអាមេរិកនឹងជាភូមិសាស្ត្រយោធាដ៏ល្អប្រសើរមួយ។ ជាអកុសលនៅពេលដែលសហរដ្ឋអាមេរិកបង្វែលគោលនយោបាយការបរទេសរបស់ខ្លួន មកតំបន់អាស៊ីអាគ្នេយ៍ក៏ជាហេតុដែលធ្វើឲ្យទំនាក់ទំនងរវាងហ្វីលីពីននិងចិនមានភាពផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស ដោយយើងដឹងច្បាស់ថាកោះស្ព្រែតលី (Spratlys) ជាមូលហេតុដែលជាភាពតានតឹងរវាងទំនាក់ទំនងហ្វីលីពីន និងចិនមានសញ្ញាអាក្រក់ទៅៗដោយការការអះអាងអធិបតេយ្យរបស់ប្រទេសទាំងពីរ។ ភាពតានតឹងកើតឡើងមិនចេះចប់មិនចេះហើយ រហូតធ្វើឲ្យអាជ្ញាធរហ្វីលីពីន ធ្វើការថ្កោលទោសមកលើនាវារបស់ចិនដែលបានបំពានចូលមកក្នុងដែនសមុទ្ររបស់ហ្វីលីពីនជាបន្តបន្ទាប់នោះ។ [13] ប្រធានាធិបតីហ្វីលីពីន Aquino III បានប្រកាសថាចាប់តាំងពីថ្ងៃទី ២៥ ខែកុម្ភៈ មកមានករណីបំពាន ៦ទៅ ៧ដង មកលើដែនអធិបតេយ្យភាពរបស់នាវាចិន ហើយក្នុងចំណោមនាវាដែលបានលួចជ្រៀតចូលទាំងនេះមានករណីនាវារបស់ចិនមួយបានផ្ទុះអាវុធ មកលើនាវារបស់ហ្វីលីពីនទៀតផង។ បើប្រៀបធៀបជាមួយនឹងប្រទេសចិននាវារបស់ហ្វីលីពីននៅមានភាពទន់ខ្សោយនៅឡើយ និងកម្លាំងជើងអាកាសមិនអាចធ្វើការគ្រប់គ្រងស្ថានភាពនៅតំបន់នោះគ្រប់ពេលវេលាបានទេ។ ដូច្នេះហើយទើប ហ្វីលីពីនតែងតែងាកទៅរកសម្ព័ន្ធមិត្តរបស់ខ្លួនគឺអាមេរិក ដើម្បីតាមដាន និងចាប់កំហុសសកម្មភាពរបស់ចិន ហើយប្រកាសទង្វើខុសច្បាប់ទាំងនោះជាអន្តរជាតិ ជាប្រយោជន៍ទាញយកសម្លេងគាំទ្រពីមជ្ឈដ្ឋានជុំវិញ ជាពិសេសប្រទេសដែលមានជម្លោះផ្ទាល់ទាក់ទងនឹងសមុទ្រចិនខាងត្បូង។ [14] ដោយគ្មានការព្រួយបារម្ភ ចិនគ្រោងនឹងចាត់បញ្ជូនស្ថានីយខ្ទង់យកប្រេងមកតាំងក្នុងតំបន់សមុទ្រមានការវិវាទកាលពីខែ កក្កដា ឆ្នាំ ២០១១ ដែលជាហេតុធ្វើឲ្យប្រទេសហ្វីលីពីនបានរៀបចំឯកសារស្ដីពីការបំពានខុសច្បាប់ទាំងនេះ រួមទាំងការបាញ់មកលើនាវានេសាទរបស់ហ្វីលីពីន ដើម្បីផ្ញើរទៅភាគីចិន

---

[13]Castro, Renato Cruz De. "The Philippines in the South China dispute." In *The South China Sea and Australia's Regional Security Environment*, 31. The National Security College is a joint initiative of the Commonwealth Government and The Australian National University, 2013.

[14]Stout, David. *TIME.* March 31, 2014. http://time.com/43362/philippines-china-un-intervention-south-china-sea/ (accessed May 27, 2014).

ផងនិងប្តឹងទៅអង្គការសហប្រជាជាតិផង។ ទាក់ទងនឹងការចោទប្រកាន់នេះ ភាគីចិនបានឆ្លើយតបដោយបញ្ជាក់ថា រាល់របាយការណ៍របស់ហ្វីលីពីន អំពីនាវាចិនរំលោភមកលើដែនសមុទ្រហ្វីលីពីននោះ សុទ្ធតែជាការមិនពិត ដោយនាវាចិនទាំងនោះសុទ្ធតែជានាវារុករកស្រាវជ្រាវក្នុងសមុទ្រ ហើយធ្វើសកម្មភាពធម្មតា និងជាអចិន្ត្រៃយ៍នៅក្នុងតំបន់សមុទ្រចិនខាងត្បូងនេះជាយូរមកហើយ។ សង្គ្រាមពាក្យសំដី និងការទូតបានកើតឡើងជាបន្តបន្ទាប់ហើយកាន់តែជ្រៅទៅៗ ដោយសារហេតុការណ៍នេះបានជះឥទ្ធិពលយ៉ាងអវិជ្ជមានមកលើ វិស័យជំនួញរបស់ប្រទេសទាំងពីរ លោក Francis Chua ប្រធានសភាពាណិជ្ជកម្ម និងឧស្សាហកម្មហ្វីលីពីនបានមានប្រសាសន៍ថា ការជួបប្រាស្រ័យមកលើបញ្ហាដោយផ្តើមចេញពីផលប្រយោជន៍សេដ្ឋកិច្ចទាក់ទងដល់គ្រប់ភាគីហើយទាញយកផលប្រយោជន៍រួមមួយនិងជាកូនសោរគន្លឹះក្នុងដំណោះស្រាយវិវាទលើតំបន់សមុទ្រចិនខាងត្បូង។ មិនត្រឹមតែប៉ុណ្ណោះ ប្រធានាធិបតីហ្វីលីពីនក៏បានធ្វើការព្រមានថា នឹងពុំមានការខិតខំប្រឹងប្រែងការទូតណាមួយ ដែលអាចធ្វើការរារាំងទប់ស្កាត់ចិន កុំឲ្យមានការរំលោភបំពានមកលើតំបន់សមុទ្រមានការវិវាទឡើយ។ [15] ក្រៅអំពីការប្រឆាំងជំទាស់មកលើនាវាយោធារបស់ចិន ដែលបានរំលោភបំពានមកលើដែនសមុទ្រហ្វីលីពីន ហើយហ្វីលីពីនក៏បានធ្វើកំណត់ទូតជំទាស់ម្តងទៀត ចំពោះនាវាយាមល្បាតពីរគ្រឿងរបស់កងទ័ពជើងទឹកចិន ដែលថ្ងៃទី២ មិនា បានមកធ្វើការរំខានអុកឡុកមកលើនាវារុករកប្រេង MV Veritas Voyager របស់ហ្វីលីពីន ដែលកំពុងតែបំពេញភារកិច្ចការងារក្នុងដែនសមុទ្ររបស់ប្រទេសហ្វីលីពីន។

ដល់ថ្ងៃទី ២ មិថុនា ឆ្នាំ ២០១១ ក្រសួងការបរទេសហ្វីលីពីន ក៏បានកោះហៅតំណាងស្ថានទូតចិនប្រចាំនៅហ្វីលីពីន ដើម្បីតវ៉ាចំពោះនាវារបស់ចិនដែលបានដឹកសម្ភារមកកសាងបង្គោលសម្គាល់នៅលើសមុទ្រចិនខាងលិចរបស់ហ្វីលីពីន នាថ្ងៃទី ៣១ ឧសភា ២០១១ កន្លងមកនេះ ដោយភាគីហ្វីលីពីនបានស្នើឲ្យលោកភារធារីស្តីទីចិន ធ្វើការពន្យល់អំពីនាវាយាមល្បាត និងនាវាកងទ័ពជើងទឹកចិនដែលបានចូលមកក្នុងតំបន់ភាគខាងលិចរបស់ប្រទេសហ្វីលីពីន។ យោងតាមការជូនពត៌មានរបស់សារពត៌មានជាតិរបស់ហ្វីលីពីនបានឲ្យដឹងថា នាវាខាងលើនេះបានលួចចូលដោយបានដឹងមកជាមួយនូវសម្ភារសំណង់រួមទាំងការលួចកសាងបង្គោលសម្គាល់ និងទម្លាក់ពោងជាសញ្ញាសម្គាល់នៅក្នុងតំបន់សមុទ្រនេះ ដោយកងទ័ពចិនផង។ រដ្ឋមន្ត្រីការបរទេសហ្វីលីពីន បានធ្វើការអះអាងថាទោះបីជាមានសំណង់របស់ ដែលបានបន្ទុកកសាងឡើងនៅលើតំបន់សមុទ្រជុំវិញ ដែលតំបន់ទាំង

[15] Thayer, Carlyle A. "China's New Wave of Aggressive Assertiveness in the South China Sea." Washington DC, 2011.

នេះ ពុំដែលបានមនុស្សរស់នៅសោះ ហើយដែលតំបន់នេះស្ថិតនៅក្នុងជួរកោះ Iroquois Bank ក៏ដោយ ក៏អំពើទាំងនេះសុទ្ធតែជាការរំលោភមកលើក្រមប្រតិបត្តិនេះ បានចុះហត្ថលេខារវាងពួកអាស៊ានជាមួយនឹងចិននាឆ្នាំ ២០០២។ ក្រៅអំពីហេតុការណ៍រំលោភបំពានខាងលើរបស់ចិននេះ ក្រសួងការបរទេសហ្វីលីពីនក៏បានសំដែងការបារម្ភទាំងឡាយ ដែលបណ្តាញសារពត៌មានចិនបានធ្វើការផ្សព្វផ្សាយថា ចិនមានគម្រោង ដាក់ស្ថានីយខួងប្រេងដ៏ ទំនើបហើយធំនៅលើសមុទ្រចិនខាងត្បូង នាខែកក្កដានេះ ដោយហ្វីលីពីនបានសំណូមពរឲ្យភាគីចិនបង្ហាញឲ្យច្បាស់ថា ចិននឹងដាក់តាំងស្ថានីយ៍ខួងយកប្រេងនេះនៅកន្លែងណា? ទីណានៃតំបន់សមុទ្រនេះ? ព្រមទាំងបានសង្កត់ធ្ងន់ថា ចិនមិនត្រូវបន្តបំពារបំពានមកលើបូរណភាពទឹកដី ឬដែនសមុទ្ររបស់ហ្វីលីពីនទៀត។ ទស្សនៈកិច្ចរបស់រដ្ឋមន្ត្រីការបរទេសហ្វីលីពីនទៅសហរដ្ឋអាមេរិចគឺជាយុទ្ធសាស្ត្រការទូតរបស់ហ្វីលីពីនដែលហ្វីលីពីនចាំចាច់ត្រូវឈានមុខក្នុងការនាំបញ្ហាវិវាទសមុទ្រចិនខាងត្បូងនេះប្រែក្លាយទៅជាបញ្ហាមានចរិកអន្តរជាតិ និងលក្ខណះអន្តរជាតិហើយដំណោះស្រាយដ៏ល្អបំផុតនៅពេលនេះគឺ ភាគីទាំងអស់ត្រូវរួមគ្នាដើម្បីទប់ទល់នឹងប្រទេសចិន។

អ្វីដែលគួរឲ្យកត់ជាងនេះទៅទៀតនោះគឺ ដើម្បីឈានទៅដល់ការធ្វើនិត្យានុកូលភាព ដោយ de facto នោះ គឺខុទ្ទកាល័យរបស់ប្រធានាធិបតីហ្វីលីពីន បានចេញសេចក្តីប្រកាសមួយដោយសម្រេចប្តូរឈ្មោះតំបន់សមុទ្រចិនខាងត្បូងទៅជា សមុទ្រហ្វីលីពីនខាងលិច ( West Philippines sea ) វិញដោយបញ្ជាឲ្យគ្រប់ស្ថានបេសកកម្មការទូត និងក្រសួងការពារជាតិហ្វីលីពីនត្រូវប្រើពាក្យ សមុទ្រហ្វីលីពីនខាងលិច ( West Philippines sea ) ជំនួសទៅដោយពាក្យ សមុទ្រចិនខាងត្បូង ( South China Sea ) ចាប់ពីពេលនេះតទៅជាផ្លូវការ ។

## ២.២ ជម្លោះចិន និង វៀតណាម

ចិន និងវៀតណាមតែងតែធ្វើការអះអាងដែនអធិបតេយ្យរបស់ខ្លួននៅក្នុងសមុទ្រចិនខាងត្បូងផ្អែកលើប្រវត្តិសាស្ត្រ ហើយប្រទេសទាំងពីរតែងតែមាន ជម្លោះជាមួយគ្នាជាញឹកញយដោយសារ កប៉ាល់ និងនាវាដឹកទំនិញមួយចំនួនដើម្បីដណ្តើមផលប្រយោជន៍រៀងៗខ្លួន នៅលើដែនសមុទ្រកំពុងមានជម្លោះមិនត្រូវបាននរណាម្នាក់អាចសន្មត់ឲ្យច្បាស់ថា តើប្រទេសណាមួយជាម្ចាស់ឲ្យពិតប្រាកដ ទោះបីជាសន្និសីទអង្គការសហប្រជាជាតិបានកំណត់ព្រំដែនទឹក ២០០ ម៉ាយ (Nautical Miles)។ សហាក្រុមហ៊ុនប្រេង Exxon Mobil របស់អាមេរិកនឹងចាប់ផ្តើមខួងរុករកប្រេងនៅក្នុងតំបន់សមុទ្រខាងត្បូងដែលស្ថិតក្នុងសមុទ្ររបស់វៀតណាម ដោយចាប់ផ្តើមខែមេសាឆ្នាំ ២០១១ នេះទៅដែលសកម្មភាពខាងលើនេះ ធ្លាប់មានប្រតិកម្មយ៉ាងខ្លាំងពីអាជ្ញាធររបស់រដ្ឋាភិបាលចិន

ចំពោះការខ្វងនេះ។ សកម្មភាពធ្វើការរុករកនេះ មានរយៈពេល៩០ថ្ងៃ ត្រូវបានដំណើរការនៅក្នុងប្លុក១១៩ ខាងក្រៅតំបន់សមុទ្ររបស់ខេត្ត Da Nang និង Quang Ngai របស់ភូមិភាគកណ្ដាលនៃប្រទេសវៀតណាម ហើយសេចក្ដីសម្រេចនៃសកម្មភាពនេះ ត្រូវបានលើកឡើងនាកិច្ចប្រជុំរវាងក្រុមហ៊ុន Exxon Mobil ជាមួយនឹងគណៈកម្មាធិការខេត្ត Da Nang ដើម្បីមានផែនការរុករកនេះ ដោយឡែក Exxon Mobil ហាក់បីពុំបានធ្វើសេចក្ដីបរិយាយណាមួយទាក់ទងដល់ហេតុការណ៍ខាងលើនេះឡើយ។

ក្រុងប៉េកាំង និងហាណូយ បាននឹងកំពុងមានការវិវាទនឹងគ្នាលើប្រជុំកោះផារ៉ាសែ្សល (Paracels) និង ស្ព្រាតលី (Spratlys) ក្នុងតំបន់សមុទ្រចិនខាងត្បូង។ ជាកិច្ចព្រមព្រៀងមិនច្បាស់លាស់របស់វៀតណាមទទួលបានការគាំទ្រពីសហរដ្ឋអាមេរិក ជាពិសេសគឺក្នុងដំណោះស្រាយលើអធិករណ៍ ព្រំដែនសមុទ្រលើមូលដ្ឋានពហុភាគី។ នៅខែកក្កដា ២០០៨ ចិនធ្លាប់បានសំណូមពរឲ្យ Exxon Mobil បោះបង់ចោលនូវគម្រោងរុករកប្រេងខាងលើជាមួយវៀតណាមទៅ បើមិនដូច្នោះទេវាល់សកម្មភាពរបស់ Exxon Mobilនិងមានការប៉ះពាល់ឥទ្ធិពលមកលើកិច្ចសន្យារកស៊ីទាំងឡាយរបស់ក្រុមហ៊ុន Exxon Mobil នេះនៅសាធារណរដ្ឋប្រជាមានិតចិន។ ហើយមុននេះនៅឆ្នាំ២០០៧ ចិនក៏ធ្លាប់បានទិទៀនយ៉ាងខ្លាំងមកលើអាជ្ញាធរវៀតណាម ដែលបានចុះហត្ថលេខាជាមួយក្រុមហ៊ុន BP របស់អង់គ្លេស អំពីការរុករកប្រេង ឧស្ម័ន នៅជិតប្រជុំកោះស្ព្រាតលី (Spratlys)ផងដែរ។ នេះពុំមែនជាលើកដំបូងដែលចិន និងវៀតណាម មានវិវាទជាមួយគ្នាជុំវិញគម្រោងរុករកប្រេង និងឧស្ម័ន ដែលគ្មានភាគីទី៣ចូលរួមនោះ ពីព្រោះចិនក៏ធ្លាប់បានទទួលរងការប្រឆាំងយ៉ាងខ្លាំងក្លានៅពេលដែលចិនបានអញ្ជើញភាគីបរទេសចូលរួមក្នុងគម្រោងរុករកប្រេងផងដែរ។ ដូចក្នុងបណ្ដាឆ្នាំ១៩៩០ នៅពេលដែលបានចូលរួមជាមួយសហក្រុមហ៊ុន CRESTONE របស់អាមេរិកធ្វើការរុករកប្រេងមកលើបណ្ដាប្លុក ១៣៥ និង ១៣៦ ដែលស្ថិតនៅភូមិភាគខាងត្បូងរបស់កោះPoulo Condor (កោះត្រឡាច) ក៏ត្រូវរដ្ឋាភិបាលវៀតណាមប្រឆាំងជំទាស់ជាខ្លាំងដែរ។ ដូច្នេះហើយទើបគេឃើញក្នុងឆ្នាំ២០០២ ប្រទេសទាំងអស់ដែលមានការពាក់ពន្ធ័ដល់អធិបតេយ្យមកដល់តំបន់សមុទ្រខាងត្បូងនេះបានជំរុញនិងចុះហត្ថលេខា លើក្រមប្រតិបត្តិ DOC 2002 សំដៅអត់ធ្មត់ ទប់ស្កាត់ និងរាំងកុំឲ្យមានអធិករណ៍កើតឡើងដោយយថាហេតុណាមួយលើតំបន់សមុទ្រចិនខាងត្បូងនេះ។ Petrovietnam និង Exxon Mobil បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខណ្ឌស្ដីពីកិច្ចសហប្រតិបត្តិការក្នុងតំបន់សមុទ្រចិនខាងត្បូង ក្នុងឱកាសទស្សនៈកិច្ចផ្លូវការរបស់នាយករដ្ឋមន្ត្រីវៀតណាមទៅសហរដ្ឋអាមេរិកនៅឆ្នាំ២០០៨។ យោងតាមពត៌មានគួរឲ្យទុកចិត្តទាំងឡាយពីមជ្ឈដ្ឋានហុងកុង

ឲ្យដឹងថា Exxon Mobil មានជំនឿជាក់ថាប្លុកទាំងឡាយដែលក្រុមហ៊ុនមានគម្រោងត្រូវខួង ដើម្បីរុករកនោះគឺនៅដែនអធិបតេយ្យភាពពិតប្រាកដរបស់វៀតណាម។ នៅពេលនោះរដ្ឋាភិបាលអាមេរិកបានដឹងអំពីហេតុការណ៍ ដោយអាមេរិកអត់មានពេលវេលាគ្រប់គ្រាន់ក្នុងការលោតចូលធ្វើការប្រកែកវែកញែកអំពីដំណើរហេតុនៅក្នុងតំបន់សមុទ្រចិនខាងត្បូងតែប៉ុណ្ណោះទេ។ ក៏ប៉ុន្តែឆ្នាំមុននាឱកាសកិច្ចប្រជុំសន្តិសុខតំបន់ នៅសិង្ហបុរីរដ្ឋមន្ត្រីការពារជាតិរបស់អាមេរិកព្រមានចិនថាមិនគួរសំឡុតមកលើប្រទេសជិតខាងក្នុងវិស័យសម្បត្តិធម្មជាតិដែលមានស្រាប់ក្នុងសមុទ្រ ក្រោមបាតសមុទ្រឡើយ។

[16]ជម្លោះដែនអធិបតេយ្យភាពនៅក្នុងដែនសមុទ្រចិនខាងត្បូងចាប់ផ្ដើមក្នុងឆ្នាំ១៩៧០ ដែលប្រទេសចិន និងវៀតណាមខាងត្បូងប្រឈមមុខដាក់គ្នានៅក្នុងឆ្នាំ១៩៧៤ ប្រទេសចិនបានកាន់កាប់កោះផារ៉ាស៊ែល (Paracels) នៅក្នុងឆ្នាំ១៩៨០ និងពង្រីកអំណាចរបស់ខ្លួនកាន់កាប់កោះស្ព្រែតលី (Spratlys) រហូតបណ្ដាលឲ្យជម្លោះរីកធំឡើងៗរវាងប្រទេសចិន និង វៀតណាម។ នៅខែធ្នូ ឆ្នាំ ២០០៨ ប្រទេសចិន និងវៀតណាមបានចុះកិច្ចព្រមព្រៀងដើម្បីចាប់ផ្ដើមពិភាក្សាទ្វេភាគីលើបញ្ហាលើដែនសមុទ្រ ដែលជាអត្ថិភាពបំផុតដើម្បី គោលការណ៍បង្កើតជាមូលដ្ឋាន" Fundamental Guiding Principles" ដែលជាគម្រោងមួយសម្រាប់ដំណោះស្រាយបញ្ហាជាក់លាក់ទាំងនោះ។ ការពិភាក្សារវាងចិន និងវៀតណាមដែលគួរឲ្យទុកចិត្តហើយផ្លូវការនេះត្រូវបានរៀបចំឡើងចំនួន ៥ដងក្នុងឆ្នាំ២០១០។ យោងទៅតាមពត៌មានក្រសួងការបរទេសវៀតណាម ប្រទេសចិន និងវៀតណាមបានដោះស្រាយទៅលើបញ្ហាខ្វែងគំនិតគ្នា តាមរយៈកិច្ចចរចាសន្តិភាព "Peace negotiation" ស្ដីពីបញ្ហាស្មុគស្មាញមួយចំនួន ការប្រើអំពើហិង្សានិងការគំរាមគំហែងដល់ការផ្ទុះកម្លាំងប្រដាប់អាវុធ។ [17]អ្វីដែលសំខាន់ជាងនេះទៅទៀតប្រទេសចិន និងប្រទេសវៀតណាមបានព្រមព្រៀងពិភាក្សាទ្វេភាគីទៅលើបញ្ហាមួយចំនួនដែលមិនធ្វើឲ្យពាក់ព័ន្ធភាគីទីបី។ ប្រទេសវៀតណាមចង់ឲ្យប្រទេសចិនលើកយកកោះប៉ារ៉ាស៊ែល (Paracels) មកពិភាក្សាពប៉ុន្តែចិនបានបដិសេធ។ មិនត្រឹមតែប៉ុណ្ណោះ ប្រទេសចិន និងប្រទេសវៀតណាមបានខ្វែងគំនិតគ្នាទៅលើកិច្ចពិភាក្សាពហុភាគី ដែលការពិភាក្សានោះទាក់ទងទៅនឹងភាគីដទៃទៀតដូចជាកោះស្ព្រែតលី (Spratlys) មិនអាចត្រូវបានដោះស្រាយដោយចិននិងវៀតណាម វាត្រូវតែមានការចូលរួមពីភាគីដែលពាក់ព័ន្ធទាំងអស់

[16] Shoji, Tomotaka. "Vietnam, ASEAN, and the South China Sea: Unity or Diverseness?" *NIDS Journal of Defense and Security*, 2012: 04.

[17] Thayer, Carlyle A. "China's New Wave of Aggressive Assertiveness in the South China Sea." Washington DC, 2011.

សម្រាប់បញ្ហាដែលមិនត្រឹមតែពាក់ព័ន្ធជាមួយវៀតណាម និងចិនទៅលើសុវត្ថិភាពនិងសន្តិសុខសមុទ្រចិនខាងត្បូងត្រូវតែចូលរួមពីសមាជិកទាំងអស់ត្រូវបង្ហាញពីចំណាប់អារម្មណ៍ និងអះអាងពីដែនអធិបតេយ្យភាពរបស់ពួកគេ។

**កិច្ចប្រជុំកំពូលលើកទី ៤** : ពាក់កណ្តាលឆ្នាំ ២០១១ ចិន និងវៀតណាមបានរៀបចំកិច្ចប្រជុំសំខាន់ផ្តោតទៅលើបញ្ហាសមុទ្រចិនខាងត្បូងនៅខែកក្កដាឆ្នាំ២០១១ បន្ទាប់ពីគណបក្សកុម្មុនីស្តសភាជាតិវៀតណាមបានតែងតាំងអគ្គលេខាធិការថ្មីឈ្មោះ Nguyen Phu Trong ដែលបានបញ្ជូនបេសកម្មពិសេសដែលឈ្មោះ Hoang Binh Quan ទៅទីក្រុងប៉េកាំង។ លោក Quan បានជួបជាមួយលោក Hu Jintao ដែលជាប្រធាន និងជាអគ្គលេខាធិការនៃគណបក្សកម្មុនីសចិន ហើយបានជួបពិភាក្សាដោយរយៈពេលខ្លី។ លោក Quan ក៏បានអញ្ជើញលោកប្រធានាធិបតី Hu និងសមាជិកបក្សដទៃ ព្រមទាំងមន្ត្រីនានាដើម្បីទៅធ្វើទស្សនកិច្ចទៅប្រទេសវៀតណាម។ [18]ជាការឆ្លើយតបវិញលោកប្រធានាធិបតី Hu ក៏បានអញ្ជើញលោក Trong ដែលជាអគ្គលេខាធិការបក្សកម្មុនីស ដើម្បីធ្វើទស្សនកិច្ចនៅប្រទេសចិនវិញ។

នៅខែមេសា លោកអគ្គមេបញ្ជាការ Guo Boxiong និងជាអនុប្រធានគណៈកម្មការយោធា Central Military Commission បានទស្សនកិច្ចទៅទីក្រុងហាណូយដោយតាមរយៈការអញ្ជើញរបស់លោក Phung Quang Thanh រដ្ឋមន្ត្រីក្រសួងការពារជាតិវៀតណាម។ លោកអគ្គមេបញ្ជាការ Guo ក៏បានទទួលពីលោកនាយករដ្ឋមន្ត្រីវៀតណាម Nguyen Tan Dung និង លោក Nguyen Phu Trong ជាអគ្គលេខាធិការបក្សកុម្មុនស្តសភាជាតិវៀតណាម។ លោកនាយករដ្ឋមន្ត្រី Dung បានធ្វើសំណើរទៅភាគីទាំងពីរដើម្បីស្វែងរកវិធានការដោះស្រាយអំឡុងរយៈពេលវែងដែលភាគីទាំងពីរទទួលយកបញ្ហាសមុទ្រចិនខាងត្បូងនេះ។ បន្ទាប់ពីទស្សនកិច្ចរបស់លោកអគ្គមេបញ្ជាការ Guo ប្រទេសវៀតណាមបានរៀបចំកិច្ចប្រជុំមួយដោយចូលរួមដោយមេដឹកនាំនៃគណៈប្រតិភូរដ្ឋាភិបាលលើការចរចាព្រំដែនរវាងប្រទេសចិន និងប្រទេសវៀតណាមថ្ងៃទី ១៨ និង ១៩ ខែ មេសា នៅកំរិតអនុរដ្ឋមន្ត្រី។[19] ក្រសួងការបរទេសរបស់ប្រទេសចិនបានរាយការណ៍ថា អនុរដ្ឋមន្ត្រីទាំងពីរបានសន្យាដោះស្រាយជម្លោះដែនសមុទ្រឲ្យបានត្រឹមត្រូវ តាមរយៈការពិគ្រោះយោបល់និងរកដំណោះស្រាយដែលងាយស្រួលជាមួយផលវិជ្ជមាននិងស្ថាបនាអាកប្បកិរិយា ។ ខណៈពេលអ្នកនាំពាក្យរបស់វៀតណាមមួយ

[18] "Chinese president vows to further ties with Vietnam," Xinhua, Feb 18, 2011 and "China's Hu Jintao invites Nguyen Pho Trong, " Voice of Vietnam News, Feb 19, 2011.

[19] "Vietnamese Prime Minister Nguyen Tan Dung Meets with Chinese Vice Foreign Minister Zhang Zhijun," Ministry of Foreign Affairs of the People's Republic of China, April 20, 2011.

បានបង្ហាញថាភាគីទាំងពីរបានព្រមព្រៀងគ្នាថាពួកគេនឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយស្ដីពីគោលការណ៍ណែនាំជាមូលដ្ឋាន ក្នុងការដោះស្រាយបញ្ហាសមុទ្រប៉ុន្តែការចរចារនៅតែបន្តហើយគ្មានកាលបរិច្ឆេទត្រូវបានកំណត់ទៅចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ។ កិច្ចប្រជុំកំពូលលើកទី ៤ បានប្រារព្ធឡើងនៅប្រទេសសិង្ហបុរីនៅក្នុងខែ មិថុនា នៅខាងក្រោយនៃកិច្ចពិភាក្សា Shangri-Laនេះមានការចូលរួមរដ្ឋមន្ត្រីការពារជាតិទាំងពីរគឺ Liang Guanglie និង Phung Quang Thanh ។ កិច្ចប្រជុំនេះបានធ្វើឡើងនៅរៀបចំទាំងងងឹតនៅថ្ងៃទី 26 ខែឧសភា ដោយអគ្គិសនីបានដាច់ដោយចៃដន្យ។ រដ្ឋមន្ត្រី Thanh បានសម្តែងការព្រួយបារម្ភរបស់ថ្នាក់ដឹកនាំបក្សនិងមេដឹកនាំរដ្ឋវៀតណាមលើបញ្ហានេះ ហើយបន្ទាប់មកបានផ្តល់ការអត្ថាធិប្បាយផ្សះផ្សានេះថាពេលខ្លះករណីសោកស្តាយកើតឡើងហួសពីការរំពឹងទុករបស់ភាគីទាំងពីរ។ រដ្ឋមន្ត្រី Liang បានឆ្លើយតបថាប្រទេសចិនមិនចង់មានឧប្បត្តិហេតុស្រដៀងគ្នាមួយកើតឡើងនៅក្នុងនាពេលអនាគត។ លោកបានកត់សម្គាល់ជាពិសេសថាកងទ័ពរំដោះប្រជាជនមិនត្រូវបានជាប់ពាក់ព័ន្ធនៅក្នុងឧប្បត្តិហេតុនោះទេ ហើយ បួនថ្ងៃក្រោយមកមានហេតុការណ៍នៃការដាច់ភ្លើងកើតឡើងម្តងទៀត។

**បម្រាមរបស់ប្រទេសចិនក្នុងការនេសាទឯកតោភាគី ៖** នៅថ្ងៃទី ១១ ខែឧសភា អភិបាលក្រុងហៃគូខេត្តហៃណានបានចេញការប្រកាស ដាក់បម្រាមហាមឃាត់នេសាទឯកតោភាគីមួយរដូវរបស់ប្រទេសចិននៅក្នុងសមុទ្រចិនខាងត្បូងចាប់ពីថ្ងៃទី១៦ខែឧសភា ដល់ថ្ងៃទី១ខែសីហា ដែលទំនងជាដើម្បីការពារត្រីធ្លាក់ចុះក្នុងរដូវត្រីពងនេះ។ ប្រទេសវៀតណាមបានតវ៉ាពាក្យសំដីមួយថាប្រតិបត្តិការឯកតោភាគីរបស់ប្រទេសចិនហាមឃាត់ការនេសាទ នៅក្នុងសមុទ្រខាងកើតគឺ ជាការរំលោភអធិបតេយ្យភាពរបស់វៀតណាមមួយ លើប្រជុំកោះ Hoang Sa កោះផារ៉ាស៊ែល (Paracels) ស្របពេលប្រទេសនេះមានអធិបតេយ្យភាព និងយុត្តាធិការលើតំបន់សេដ្ឋកិច្ចផ្តាច់មុខ និងខ្ពង់រាបបាតសមុទ្ររបស់ខ្លួន។

ប្រទេសវៀតណាមក៏បានតវ៉ាក្នុងការដាក់ពង្រាយនូវនាវានេសាទរដ្ឋបាលចិន (Leizhou 44261) ដើម្បីល្បាតនៅក្នុងដែនទឹកជុំវិញកោះផារ៉ាស៊ែល (Paracels) ចាប់ពីថ្ងៃទី៥ ដល់ ២៥ ខែឧសភា ។ ប្រទេសវៀតណាមបានចោទប្រកាន់ទូកល្បាតរបស់ចិនថា បង្កឱ្យមានការលំបាកសម្រាប់សកម្មភាពនេសាទធម្មតា ជាពិសេស អ្នកនេសាទវៀតណាមដែលនេសាទបែបប្រពៃណីនិងធ្វើឲ្យស្ថានភាពនូវតំបន់សមុទ្រមានភាពស្មុគស្មាញថែមទៀត។ អាជ្ញាធរមូលដ្ឋានវៀតណាមបានរាយការណ៍មកដល់ទូកនេសាទចិនដែលនៅក្នុងតំបន់ទឹកវៀតណាម ដែលមានចំនួនកើនឡើងជាងមុនជាបន្តបន្ទាប់។ ប្រធានការិយាល័យកណ្តាលឆ្មាំព្រំដែននៃខេត្ត Phu Yen បានថ្លែងថា ជា

រៀងរាល់ថ្ងៃទូកនេសាទប្រមាណចំនួន ១២០ ដល់ ១៥០ របស់ប្រទេសចិន ត្រូវបានធ្វើការនេសាទនៅក្នុងដែនទឹកទីក្រុង Da Nang ទៅប្រជុំកោះ Truong Sa (ប្រជុំកោះស្ព្រាតលី Spratlys)។ ពីមុនទូកនេសាទចិនបានរំលោភលើទឹករបស់វៀតណាម ហើយវាជាលើកដំបូងដែលមានទូកជាច្រើន។ ដោយពេលខ្លះទូកនេសាទចិនបានកើនឡើងដល់ទៅ ពីររយគ្រឿង ។ អ្នកនេសាទវៀតណាមបានបង្កើតក្រុមនេសាទ ដែលមានទូកចំនួនប្រាំទៅដប់គ្រឿងការពារការគំរាមកំហែងពីនាវារបស់ប្រទេសចិនមានទំហំធំ ហើយដែលពេលខ្លះត្រូវបានគេប្រើអាវុធដើម្បីគំរាមកំហែងដល់ពួកគេផងដែរ។ បច្ចុប្បន្ននេះរដ្ឋាភិបាលវៀតណាមបានកំពុងពិចារណាសំណើរមួយរបស់ក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទ ដើម្បីកសាងសង់ទូកល្បាតចំនួនដប់ដែលចំណាយថវិកាសរុបចំនួន ១០,២១៥ លានដុល្លារសហរដ្ឋអាមេរិក។ បើទោះបីជាអ្នកនេសាទវៀតណាមបានប្តេជ្ញាប្រឆាំងនឹងការហាមឃាត់នេះក៏ដោយតែសារព័ត៌មានរបស់វៀតណាមមិនបានរាយការណ៍ថា ឧប្បត្តិហេតុណាមួយដ៏សំខាន់នៃការឃាយឺឬការឃុំខ្លួនឡើយដល់ពួកគេឡើយ។ នៅថ្ងៃទី ១ ខែមិថុនា សារព័ត៌មានរបស់វៀតណាមរាយការណ៍ថានាវាយោធារបស់ចិនបានគំរាមក្នុងប្រើអាវុធរបស់ពួកគេដើម្បីប្រឆាំងនឹងទូកនេសាទវៀតណាមក្នុងការនេសាទនៅក្នុងដែនទឹកក្បែរប្រជុំកោះប្រជុំកោះស្ព្រាតលី Spratlys ។

នាយករដ្ឋមន្ត្រី Dung បានអះអាងនៃការមិនអាចប្រកែកបាននូវអធិបតេយ្យភាព (Incontestable Sovereignty) ។ នៅថ្ងៃទី ៩ ខែមិថុនានាយករដ្ឋមន្ត្រី លោក Nguyen Tan Dung បានឆ្លើយតបទៅនឹងការរីកលូតលាស់សម្ពាធក្នុងស្រុកមួយចំនួន ដើម្បីបង្ហាញភាពរឹងមាំក្នុងការដោះស្រាយជាមួយប្រទេសចិន ដោយការធ្វើសេចក្តីថ្លែងការណ៍មួយដ៏ខ្លាំងខុសពីធម្មតាក្នុងការការពារអធិបតេយ្យភាពជាតិ។ នាយករដ្ឋមន្ត្រី Dung បាននិយាយថាមយើងបន្តបញ្ជាក់យ៉ាងខ្លាំង និង បង្ហាញពីការការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លានៃគណបក្សទាំងអស់ និងមនុស្សទាំងអស់ និងកងទ័ពទាំងអស់នៅក្នុងការការពារអធិបតេយ្យភាពរបស់វៀតណាមនៅតំបន់សមុទ្រនៃប្រទេសនេះ។ នាយករដ្ឋមន្ត្រី Dung បានអះអាងជាថ្មីផងដែរថាការមិនអាចប្រកែកបាននូវអធិបតេយ្យភាពសមុទ្រនៃប្រទេសវៀតណាមឆ្ពោះទៅរកប្រជុំកោះទាំងពីរនេះគឺប្រជុំកោះផារ៉ាស៊ែល Paracels និងប្រជុំកោះ ស្ព្រាតលី Spratlys ។ នៅថ្ងៃដដែលនោះប្រធាន Nguyen Minh Triet ការទៅទស្សនា កោះCo To នៅខេត្ត Quang Ninh នៅជិតព្រំដែនប្រទេសចិនបានថ្លែងថាប្រទេសវៀតណាមប្តេជ្ញាដើម្បីការពារកោះរបស់ខ្លួន យើងមានការត្រៀមខ្លួនជាស្រេចដើម្បីបូជាអ្វីគ្រប់យ៉ាងដើម្បីការពារទឹកដី សមុទ្រនិងអធិបតេយ្យភាពកោះរបស់យើង។

## ២.៣ ជម្លោះចិន និង ម៉ាឡេស៊ី

នៅថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៩ ប្រទេសម៉ាឡេស៊ីបានផ្ញើរឯកសារដើម្បីការអះអាងរបស់ខ្លួននៅជុំវិញប្រជុំកោះស្ព្រែតលី Spratlys ក្នុងសមុទ្រចិនខាងត្បូងទៅគណៈកម្មាធិការអង្គការសហប្រជាជាតិដោយការផ្ញើរនេះធ្វើឡើងជំណាលគ្នាជាមួយប្រទេសវៀតណាម មុនពេលផុតកំណត់ចំពោះប្រទេសទាំងឡាយចង់ក្លាយជារដ្ឋហត្ថលេខី របស់កតិកាសញ្ញាស្តីពីច្បាប់សមុទ្រអង្គការសហប្រជាជាតិ។ ប្រទេសម៉ាឡេស៊ីអះអាងសុំកាន់កាប់ទៅលើតំបន់ Borneo ដែលមិនជាប់ទាក់ទងទៅនឹងឧបទ្វីបម៉ាឡេដែលតំបន់នោះស្ថិតនៅតាមរយៈបណ្តាយសមុទ្រចិនខាងត្បូង និងច្រកសមុទ្រម៉ាឡាកា(Malacca) ហើយនឹងមិនប៉ះពាល់ទៅនឹងអះអាងរបស់ចិន និងវៀតណាមទៅលើដែនត្រួតស៊ីគ្នា។

[20]ប្រទេសម៉ាឡេស៊ីបានក្លាយជារដ្ឋហត្ថលេខីនៃកតិកាសញ្ញាស្តីពីច្បាប់សមុទ្រនៅឆ្នាំ ១៩៩៦។ តែផ្ទុយទៅវិញ ប្រទេសចិនមិនធ្វើការគាំទ្រទៅលើការផ្តល់សច្ចាប័នរបស់ប្រទេសវៀតណាម និងម៉ាឡេស៊ីនោះទេ។ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ ២០០៩ ប្រទេសចិនបានផ្ញើរលិខិតការទូតទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក Ban Ki-Moon ថា " **ចិនមានអធិបតេយ្យភាពលើកោះនៅក្នុងសមុទ្រចិនខាងត្បូងមិនអាចប្រកែកបាន"** ហើយបានបញ្ជាក់ថាការអះអាងរបស់ប្រទេសម៉ាឡេស៊ី និងវៀតណាមមានការប៉ះពាល់យ៉ាងខ្លាំងដល់អធិបតេយ្យភាពរបស់ចិន។ ទោះបីជាយ៉ាងណាក៏ដោយនៅថ្ងៃទី២០ ខែមេសា ឆ្នាំ ២០០៩ ប្រទេសម៉ាឡេស៊ីបានឆ្លើយតបការអះអាងរបស់ចិនដែលបានផ្ញើរទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ថាខ្លួនមានសិទ្ធិស្របច្បាប់ក្នុងការអនុវត្តមាត្រាទាំងឡាយនៅក្នុងកតិកាសញ្ញាស្តីពីច្បាប់សមុទ្រ។ ជាការពិតណាស់ប្រទេសម៉ាឡេស៊ីបានលាតត្រដាងឆន្ទៈរបស់ខ្លួន និងចូលកាន់កាប់កោះទាំង៥នៃតំបន់ជម្លោះដែលចិនមិនទាន់បានទៅដល់កោះទាំងនោះទេ។ ដូចនឹងហ្វីលីពីន និងវៀតណាម ម៉ាឡេស៊ីក៏បានអះអាងចូលកាន់កាប់តំបន់សេដ្ឋកិច្ចផ្តាច់មុខនៅលើផ្ទៃទឹកដល់ធំនៃតំបន់ខាងកើតនៃម៉ាឡេស៊ីត្រូវបានគេហៅថា Sabah និង Sarawak។

ទំនាក់ទំនងរវាងម៉ាឡេស៊ី និងចិនមានការប្រែប្រួលជាខ្លាំងនៅពេលនេះ បើគិតពីការកសាងទំនាក់ទំនងជាមួយគ្នាដំបូងនៅឆ្នាំ ១៩៧៤។ តាំងពីឆ្នាំ ១៩៧៤ រហូតដល់បញ្ចប់សង្គ្រាមត្រជាក់។ ការដើរចូលទៅជិតចិន និងម៉ាឡេស៊ីពីព្រោះចិនបានគាំទ្របក្សកុម្មុនិស្តខុសច្បាប់របស់ម៉ាឡេស៊ី និង

[20] Finkbeiner, John M. "Malaysia's Great Power Balance and the South China Sea Disputes." *Strategy Research Project*, 2013: 05.

ក្រុមពួកអភិជនជនជាតិចិននៅក្នុងម៉ាឡេស៊ី បន្ទាប់ពីទទួលបានឯករាជ្យឆ្នាំ ១៩៥៧។ យោងទៅតាមកិច្ចព្រមព្រៀងទ្វេភាគីរវាងចិន និងម៉ាឡេស៊ីនៅឆ្នាំ ១៩៩០ ម៉ាឡេស៊ីដើរតួនាទីយ៉ាងសំខាន់ដើម្បីជំរុញឲ្យចិនភ្ជាប់ខ្លួនទៅនឹងអាស៊ាន។ ម៉ាឡេស៊ីផ្តើមគំនិតមុនគេបង្អស់ដើម្បីបង្អស់ដើម្បីបង្កើតកិច្ចប្រជុំជាមួយចិនក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសលើកទី ២៤ ឆ្នាំ ១៩៩១ ដែលម៉ាឡេស៊ីជារដ្ឋម្ចាស់ផ្ទះ។

នៅខែមេសា ឆ្នាំ ២០០៩ នាយករដ្ឋមន្ត្រីម៉ាឡេស៊ី លោក Najib បានទៅទស្សនកិច្ចនៅប្រទេសចិនហើយប្រទេសទាំងពីរបានចុះហត្ថលេខាទៅលើសកម្មភាពគម្រោងនៃយុទ្ធសាស្ត្រសហប្រតិបត្តិការដែលបានប្រកាសគន្លឹះសំខាន់១៣សម្រាប់ពេលអនាគត។ លោកនាយករដ្ឋមន្ត្រីម៉ាឡេស៊ីបាននិយាយថាទំនាក់ទំនងរវាងចិន និងម៉ាឡេស៊ីគឺជាទំនាក់ទំនងគ្រឹះសម្រាប់ផលប្រយោជន៍ប្រជាជាតិទាំងពីរ ហើយថែមទាំង ប្រទេសទាំងពីរត្រូវពង្រីកនិងពង្រឹង ទំនាក់ទំនងឲ្យកាន់តែប្រសើរឡើង។ លើសពីនេះទៅទៀត គាត់បានសសើរប្រទេសចិនថាមានការកាន់ឡើងសេដ្ឋកិច្ចចំនួន ៦.១% ក្នុងឆ្នាំ២០០៩ ប៉ុន្តែគាត់មិនបានលើកឡើងពីជម្លោះសមុទ្រចិនខាងត្បូងនោះទេ ផ្ទុយទៅវិញនិយាយតែពីទំនាក់ទំនងសេដ្ឋកិច្ចហើយចង់ពង្រីកវិស័យពាណិជ្ជកម្ម ដូចជា ធនធានប្រេង អគ្គិសនី បច្ចេកទេស សេវាកម្មហិរញ្ញវត្ថុ និងផលិតផលកសិកម្មទំនើបៗ។ ប៉ុន្តែក្រោយមក ម៉ាឡេស៊ីមានការព្រួយបារម្ភជាខ្លាំងចំពោះ កំនើនយោធារបស់ចិនក្នុងសមុទ្រចិនខាងត្បូង ដែលជាហេតុធ្វើឲ្យម៉ាឡេស៊ីពង្រឹងកញ្ចប់ថវិការរបស់ខ្លួនទៅផ្នែកយោធា។

### ២.៤ ជម្លោះចិន និង ព្រុយណេ

[21]ស្តេចស្លូតង់ (Sultan Hassanal Bolkiah)នៃប្រទេសព្រុយណេបានធ្វើទស្សនកិច្ចនៅដើមខែមេសាក្នុងពេលលោក Xi Jinping ទើបតែកាន់តំណែងជាប្រធានាធិបតីនៃប្រទេសចិនដំបូងនៃអាណត្តិ របស់ខ្លួន។ នៅក្នុងអំឡុងពេលទស្សនកិច្ចប្រទេសទាំងពីរបានព្រមព្រៀងគ្នាដើម្បីពង្រឹង **ទំនាក់ទំនងយុទ្ធសាស្ត្រ និងសហប្រតិបត្តិការ** (strategic cooperative relationship)។ ប្រទេសព្រុយណេទទួលបន្ទុកជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលអាស៊ានបន្ទាប់ពីកម្ពុជា ដែលត្រូវប្រឈមមុខនឹងបញ្ហាជាច្រើនស្របពេលដែល នយោបាយការបរទេសរបស់សហរដ្ឋអាមេរិក ងាកមកអាស៊ីប៉ាស៊ីហ្វិក ហើយមានស្ថានភាពធ្ងន់ធ្ងរៗទៅក្នុងការបង្កើតសមាគមន៍សេដ្ឋកិច្ចអាស៊ានក្នុងឆ្នាំ២០១៥។ អ្នក

[21] Zhida, Jiang. *China Institute of International Studies.* April 16, 2013. http://www.ciis.org.cn/english/2013-04/16/content_5878251.htm (accessed June 25, 2014).

អង្កេតអន្តរជាតិបានកំពុងឃ្លាំមើលបញ្ហាចំពោះងចំរះរបស់អាស៊ានពីរបៀបព្រុយណេ សម្របសម្រួលក្នុងបញ្ហាជាច្រើន ដូចជាសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន និងសហប្រតិបត្តិការអាស៊ីខាងកើត ជាពិសេសការចាត់វិធានការទាំងឡាយណាដើម្បីរក្សាសន្តិភាព និង សន្តិសុខក្នុងតំបន់សមុទ្រចិនខាងត្បូង។ ប្រទេសព្រុយណេមិនសូវសកម្មភាពណាមួយធ្ងន់ធ្ងរក្នុងជម្លោះជាមួយចិនប៉ុន្មានទេ ពីព្រោះប្រទេសមួយនេះគ្រាន់តែសូមឲ្យរដ្ឋភាគីទាំងអស់គោរពតាមសន្ធិសញ្ញាស្តីពីនីតិសមុទ្រ ដោយសារសន្ធិសញ្ញានេះនឹងផ្តល់ប្រយោជន៍ ឲ្យប្រទេសព្រុយណេក្នុងការអះអាង និងទទួលបានផលប្រយោជន៍ពីច្បាប់នេះ។ ព្រុយណេមិនដែលតំឡើងសាច់ដុំដោយសារបញ្ហាណាមួយជាមួយចិន ដូចវៀតណាម និងហ្វីលីពីននោះ គេគ្រាន់ចូលរួមប្រឆាំងនឹងការទាមទារលើសលុបរបស់ប្រទេសចិនទៅលើសមុទ្រចិនខាតត្បូងជាមួយប្រទេសដទៃទៀត ដែលធ្វើការបដិសេធនជាខ្លាំងចំពោះការអះអាងនេះ។

## កថាខណ្ឌទី ២៖ ការលូកដៃចូលជ្រៀតជ្រែករបស់មហាអំណាច

### ១.វត្តមានរបស់អាមេរិចក្នុងជម្លោះសមុទ្រចិនខាងត្បូង

ក្នុងនាមជាមហាអំណាចពិភពលោក សហរដ្ឋអាមេរិកតែងតែសាយភាយគោលនយោបាយការបរទេសរបស់ខ្លួនស្ទើរគ្រប់តំបន់ ដើម្បីចូលជ្រែតជ្រែកដោះស្រាយបញ្ហាពិភពលោក និងជះឥទ្ធិពលអំណាចយោធាដូចជាការអន្តរាគមន៍ធ្វើសង្គ្រាមនៅ Iraq និង Afganistan។ ប៉ុន្តែដោយការស្ទុះឡើងនូវឥទ្ធិពលសេដ្ឋកិច្ចរបស់ចិនប៉ុន្មានចុងទសវត្សនេះ សហរដ្ឋអាមេរិចបានបង្វែរគោលនយោបាយការបរទេសរបស់ខ្លួនមកភូមិសាស្ត្រនយោបាយអាស៊ីវិញដោយផ្តោតទៅលើតែតំបន់អាស៊ីបូព៌ា និងកូរ៉េខាងជើងតែប៉ុណ្ណោះ ដោយឡែកបច្ចុប្បន្ននេះ សហរដ្ឋអាមេរិកបានតម្រង់ត្រីវិស័យរបស់ខ្លួនមករកអាស៊ីអាគ្នេយ៍ជាពិសេសគឺអាស៊ាន ស្របពេលដែលជម្លោះសមុទ្រចិនខាងត្បូង រវាងចិន និងសម្ព័ន្ធមិត្តរបស់មហាអំណាចមួយចំនួនកំពុងឡើងកំដៅជាខ្លាំង និងទំនាក់ទំនងពាណិជ្ជកម្ម វិនិយោគទុនសេដ្ឋកិច្ចក្នុងតំបន់ Atlantic និង Pacific មានការីកផុសផុលគួរឲ្យកត់សម្គាល់។ [22]នៅក្នុងវេទិកានៃកិច្ចប្រជុំកំពូលអាស៊ានលើកទី ២នៅទីក្រុង ហាណូយ នាថ្ងៃទី ២២ កក្កដា ២០១០ លោកជំទាវ Hillary Clinton រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិចបានប្រកាសថា សហរដ្ឋអាមេរិកគាំទ្រទៅលើសេរីភាពក្នុងការធ្វើនាវាចរណ៍ គោរពច្បាប់អន្តរជាតិក្នុងសមុទ្រចិនខាងត្បូងលើសពីនេះទៅទៀតសហរដ្ឋអាមេរិកធ្វើការសម្របសម្រួលផ្នែកការទូត ដោយចូលរួមរាល់កិច្ចប្រជុំដែលទាក់ទង

[22]Yujuico, Dr Emmanuel. "The real story behind the South China Sea dispute." *Southeast Asia International Affairs*, n.d.: 01.

នឹងបញ្ហានេះ ហើយសហរដ្ឋអាមេរិកដើរតួនាទីយ៉ាងសំខាន់ដើម្បីសម្របសម្រួល និងផ្តល់មធ្យោបាយពិភាក្សាតាមផ្លូវការទូត។ [23]សមុទ្រចិនខាងត្បូងត្រូវបានសហរដ្ឋអាមេរិក ចាត់ទុកជាកន្លែងនៃប្រភពធនធានធម្មជាតិ ជាពិសេសប្រេង និងឧស្ម័ន និងភូមិសាស្ត្រនយោបាយរបស់ខ្លួន វាបានក្លាយទៅជាទីលានប្រជែងដ៏សំខាន់បំផុតព្រោះ ទោះបីជាមហាអំណាចណាក៏ដោយឲ្យតែមានអនុភាពគ្របដណ្តប់មកលើសមុទ្រចិនខាងត្បូងបានគឺប្រទេសនោះ នឹងធ្វើជាម្ចាស់នៃសសៃឈាមសេដ្ឋកិច្ចហើយតួនាទីនោះនឹងមិនមានអ្នកមកហ៊ានប្រកួតប្រជែងទៀតឡើយ។ [24] ដោយសមុទ្រចិនខាងត្បូង បានក្លាយទៅជាអត្ថប្រយោជន៍ស្លាប់រស់ ក្នុងអនាគតយ៉ាងដូច្នេះទើបខ្លឹមសារនៅក្នុង Joint Statement 2nd US ASEAN leaders Summit អាមេរិកបោះជំហានសម្បទានជាមួយអាស៊ានដ៏ច្រើនក្នុងបញ្ហាមួយដែលពោរពេញទៅដោយការចម្រូងចម្រាសគឺបញ្ហាដ៏រសើបអំពីសិទ្ធិមនុស្សនៅមីយ៉ាន់ម៉ា ការធ្វើសម្បទានរបស់អាមេរិកអំពីបញ្ហាមីយ៉ាន់ម៉ាត្រូវបានប្តូរទូរទាត់មកវិញដោយអាស៊ានក៏មានជំហានសម្បទានជាមួយអាមេរិក ក្នុងបញ្ហាគន្លឹះមួយចំនួនដែលក្នុងនោះមានបញ្ហាអ៊ីរ៉ង់ និងអំពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េផងដែរ។ ប៉ុន្តែរហូតមកទល់ពេលនេះ យើងមិនទាន់មានកិច្ចព្រមព្រៀងសហប្រតិបត្តិការពិតប្រាកដដោយឡែកណាមួយ អំពីយោធាជាមួយនឹងអាមេរិកនៅឡើយទេ ព្រោះវាអាចនឹងធ្វើឲ្យប្រទេសនោះស្ថិតនៅក្នុងស្ថានភាពផ្ទាញ់ផ្ទាលដោយផ្ទាល់ទៅនឹងអានុភាពរបស់មហាអំណាចចិននៅក្នុងភូមិសាស្ត្រនេះផ្ទាល់។ ក្រោយពីកិច្ចប្រជុំលើកទី ២ រវាងអាស៊ាន អាមេរិក សហរដ្ឋអាមេរិកធ្វើការអះអាងដោយបង្ហាញឲ្យចិនឃើញថា តំបន់សមុទ្រចិនខាងត្បូងលែកជាផ្ទះបាយរបស់ចិនតទៅទៀត ហើយយុទ្ធសាស្ត្រថ្មីរបស់អាមេរិកគឺផ្តោតសារៈសំខាន់មយកលើការផ្សារភ្ជាប់នូវទំនាក់ទំនងដ៏ជិតស្និទ្ធជាម្បក្រុមប្រទេសអាស៊ាន ដែលមុននេះអាមេរិកតែងតែព្រងើយកន្តើយ ពុំសូវយកចិត្តទុកដាក់រាប់សិបឆ្នាំ ទុកឲ្យចិនមានលទ្ធភាពវាទីពង្រឹងអានុភាពរបស់ខ្លួនទាំងសេដ្ឋកិច្ច នយោបាយ រហូតដល់កម្លាំងយោធាដែលគួរឲ្យមានការព្រួយបារម្ភ។ ក៏ប៉ុន្តែបន្ទាប់ពីការអះអាងចូលរួមរបស់អាមេរិកនៅក្នុងតំបន់អាស៊ីសារជាថ្មី បានធ្វើឲ្យសភាព ការណ៍នៅក្នុងតំបន់នេះមានការវិវត្តន៍ប្រែប្រួលទៅតាមចរន្តថ្មី។ ក្នុងប៉ុន្មានទសវត្សន៍កន្លងទៅ មានការទិតៀនយ៉ាងខ្លាំងមកលើអាមេរិក អំពីការមើលស្រាលរបស់អ្នកកាន់អំណាចខ្លួនមកលើតំបន់អាស៊ីអាគ្នេយ៍។ ព្រោះក្រៅពីមហាអំណាចក្នុងតំបន់ ដូចជាប្រទេសចិន ជប៉ុន កូរ៉េខាងត្បូង គឺអាមេរិកនេះ ហាក់ដូចជាពុំយកចិត្តទុកលើប្រទេសអាស៊ីណាមួយឡើយ។ តែបន្ទាប់ពីចិន

[23] Bonnie S. Glaser, Senior Fellow, Center for Strategic and International Studies. *Council of Foreign Relation .* April 2012. http://www.cfr.org/world/armed-clash-south-china-sea/p27883 (accessed May 20, 2014).

[24] កថាខណ្ឌទី ១៧ នៃ Joint Statement 2nd US and ASEAN leaders Summit

បង្កើនភាពខ្លាំងក្លាទាំងនយោបាយ និងសេដ្ឋកិច្ចប៉ះពាល់មកលើសិទ្ធិប្រយោជន៍របស់មួយចំនួនក្នុងតំបន់ ព្រមទាំងធ្វើឲ្យឥទ្ធិពលរបស់អាមេរិករួមទៅ ចាប់ពីពេលនោះមករដ្ឋកាលរបស់លោក Barack Obama ចាប់មានការប្រែធាតុ ហើយបង្កើនទាំងធនធានមនុស្សទាំងសម្ភារៈ ទោះបីជានៅមាកម្រិតក៏ដោយ។ ឥរិយា បថនយោបាយការបរទេសរបស់អាមេរិកនៅពេលនេះ គឺត្រៀមទទួលយកនូវគ្រប់លក្ខខណ្ឌរបស់អាស៊ានឲ្យតែខ្លួនបានចូលមកដោយសុខនៅក្នុងតំបន់នេះ ដោយអាមេរិកលែងទ្រាំទ្របានទង្វើជិះសេះលែងដៃរបស់ចិនទៀតហើយ និងឈរអោបដៃមើលការរីកវាលដាលគ្រប់ទិសទីលើពិភព លោករបស់ទៅទៀត។ ត្រូវទទួលស្គាល់តថភាពមួយ ប្រការដែលនាំឲ្យសម្រេចបានស្ថានភាពមួយយ៉ាងដូច្នេះ គឺចិនបានអត់ធ្មត់រក្សាកិត្យានុភាព និងតម្លៃការទូតរបស់ចិន ដែលតម្លៃទាំងនេះផ្អែកលើគោលការណ៍សន្តិសហវិជ្ជមាននិងការជួយឧបត្ថម្ភគាំទ្រ ដល់បណ្តាប្រទេសអាស៊ីអាគ្នេយ៍។

## ២. ការប្រឈមមុខគ្នារវាងចិន និង អាមេរិក

បញ្ហាសមុទ្រចិនខាងត្បូង ជាមូលហេតុដែលធ្វើឲ្យប្រទេសដែលពាក់ពន្ធ័ទាំងអស់សម្លឹងឃើញផលប្រយោជន៍សេដ្ឋកិច្ច រួមទាំងសហរដ្ឋអាមេរិកផងដែរ។ ហើយក៏ជាមូលហេតុដែលធ្វើឲ្យសហរដ្ឋអាមេរិចនិងចិនពាក់មុខយក្សដាក់គ្នាជារឿយៗ។ ការអះអាងដើម្បីកាន់កាប់កោះស្ព្រែតលី (Spratlys)ដោយចិន និងវៀតណាម ផងដែរការអះអាងកាន់កាប់កោះផារ៉ាស៊ែល (Paracels) ដោយព្រុយណេ វៀតណាម ម៉ាឡេស៊ី និង ហ្វីលីពីន ស្របពេលដែលអាមេរិកត្រូវបានបដិសេធចំពោះពាណិជ្ជកម្ម និងយោធានៅក្នុងតំបន់នោះ។ ហើយចិនបានអះអាងថា សហរដ្ឋអាមេរិចគ្មានតួនាទីអ្វីដើម្បីមកពាក់ព័ន្ធនឹងជម្លោះនេះទេពីព្រោះសហរដ្ឋអាមេរិចមិនមែនជាភាគីជម្លោះ ហើយក៏គ្មានភូមិសាស្ត្រនយោបាយនៅក្នុងនោះដែរ។ [25] រដ្ឋមន្ត្រីការបរទេសចិនបានធ្វើការចោទប្រកាន់សហរដ្ឋអាមេរិចបំពក់ភ្លើងកំហឹងនៅក្នុងបញ្ហាជម្លោះសមុទ្រខាងត្បូង ទៅលើប្រទេសវៀតណាម និង ហ្វីលីពីនដើម្បីបង្ករឥរិយាបថគ្រោះថ្នាក់គំរាមកំហែងដល់សន្តិសុខជុំវិញតំបន់។ ប៉ុន្តែសហរដ្ឋអាមេរិកក៏បានចោទប្រកាន់ចិនវិញដែរចំពោះការបង្ហាញឥរិយាបថបង្ករឿង ហើយបានសូមអំពាវនាវដល់ប្រទេសចិនដើម្បីដកកងទ័ពចេញពីតំបន់នោះដើម្បីធ្វើការចរចាជាមួយប្រទេសវៀតណាម និង ហ្វីលីពីនម្តងហើយម្តងទៀតដោយសន្តិវិធីជាជាងការដោះស្រាយដោយកំលាំងប្រដាប់អាវុធ។ ដោយឆ្លើយតបទៅវិញ អ្នកនាំពាក្យរបស់ក្រសួងការបរទេសចិនបានឲ្យដឹងថានាវារបស់ចិនមាន

[25] Beckma *Reuters* . May 09 , 2014. http://www.reuters.com/article/2014/05/09/us-china-usa-idUSBREA4804Z20140509 (accessed May 22, 2014).

សិទ្ធិពេញលេញឆ្លងកាន់ និង រុករកជុំវិញកោះផារ៉ាសែ្សល (Paracels) និង ស្ព្រែតលី (Spratlys) ដែលជាអធិបតេយ្យភាពរបស់ចិន ដោយគ្មានប្រទេសណាមួយមានសិទ្ធិលូកដៃបានឡើយ។ ភាពតានតឹងរវាងអាមេរិកនិងចិនតែងតែកើតមានឡើងជាហូរហែរ ទោះបីកាលពីខែ មេសា ឆ្នាំ ២០១៤ សហរដ្ឋអាមេរិក និង ប្រទេសដែលមានព្រំដែនជាប់មហាសមុទ្រប៉ាស៊ីហ្វិកបានចុះហត្ថលេខាព្រមព្រៀងកាត់បន្ថយភាពតានតឹងការពារកុំឲ្យប៉ះទង្គិចផ្នែកយោធាដោយប្រការណាមួយក៏ដោយ។ [26] កិច្ចព្រមព្រៀងមានគោលបំណងដើម្បីបង្កើនការទំនាក់ទំនងដើម្បីការពារការដឹកជញ្ជូនតាមផ្លូវទឹកជុំវិញតំបន់។ ប៉ុន្តែវាគ្មានលក្ខណៈចាប់បង្ខំតាមផ្លូវច្បាប់ និងអះអាងច្បាស់លាស់ថាតើប្រទេសណាមានអធិបតេយ្យភាពនៅជុំវិញតំបន់នោះទេ។ មុនពេលសហរដ្ឋអាមេរិចមកចូលមកពាក់ពន្ធ័នៅក្នុងបញ្ហាសមុទ្រចិនខាងត្បូងនេះ វាបានជំរុញយ៉ាងខ្លាំងនូវកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយនឹងប្រទេសបួន ដែលស្ថិតនៅក្រោមដងទន្លេមេគង្គដែលស្ថានភាពទាំងនេះ បានធ្វើឲ្យប្រទេសចិនមានការបារម្ភយកចិត្តទុកដាក់យ៉ាងខ្លាំងព្រោះគេសម្លឹងឃើញវិធីសាស្ត្ររបស់សហរដ្ឋអាមេរិក ក្នុងការរុកចូលក្នុងតំបន់ទន្លេមេគង្គដែលសកម្មភាពនេះមានចរិកយុទ្ធសាស្ត្រ និងមានប្រសិទ្ធិភាពខ្ពស់ក្នុងការជួយសម្រួលនិងការស្តារឥទ្ធិពលរបស់ខ្លួនឡើងវិញនៅតំបន់អាស៊ីអាគ្នេយ៍។ ដោយសហរដ្ឋអាមេរិកសម្លឹងឃើញថាតំបន់ទន្លេមេគង្គបាននឹងកំពុងមានសេចក្តីទោមនស្សយ៉ាងខ្លាំង ចំពោះទង្វើរបស់ប្រទេសចិនដែលធ្វើផ្តេសផ្តាស់ស្រាច់តែចិត្តមកលើតំបន់ទន្លេមេគង្គខាងលើ ដែលនាំឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើជីវភាព ប្រចាំថ្ងៃរបស់ពួកអ្នករស់នៅខាងភាគមេគង្គខាងក្រោម។ អាមេរិកនឹងសម្រេចបាននយោបាយការទូតនេះ ជាពិសេសដណ្តើមបានបេះដូងរបស់ពួករស់នៅខាងភាគមេគង្គខាងក្រោមជាយថាភាព។ បណ្តាប្រទេសដែលស្ថិតនៅតំបន់មេគង្គក្រោមបានធ្វើការទិតៀនយ៉ាងខ្លាំងក្លាមកលើអាជ្ញាធរចិន ដែលគិតតែអំពីការកសាងទំនប់វារីអគ្គិសនី ដើម្បីស្រូបយកផលចំណេញសម្រាប់ប្រជាជនប្រទេសរបស់ខ្លួន ទុកឲ្យប្រជាជនដទៃទៀតដែលរស់នៅតាមទន្លេមេគង្គខាងក្រោមស្លាប់ ដោយសារការប្រែប្រួលរបស់ចរន្តទឹកនិងអត់ត្រី។ អ្នកសង្កេតការណ៍អំពីគោលនយោបាយទឹករបស់ទន្លេមេគង្គបានធ្វើការអះអាងថាចិនត្រូវតែមានគោលនយោបាយមួយសម្រាប់ទន្លេមេគង្គចិនមានអាកប្បកិរិយាមើលស្រាល និងគំរាមគំហែងមកលើពួកប្រទេសដែលរស់នៅតាមទន្លេមេគង្គខាងក្រោម នៅពេលដែលផលប្រយោជន៍ឯកសិទ្ធិរបស់ចិនត្រូវបានប៉ះពាល់បំពានមកលើនោះ។ ចិនបានធ្វើខ្លួនទៅជាអ្នកមានចិត្តល្អមួយក្នុងការផ្តល់ហិរញ្ញប្បទាន ឬជាកម្ចីសម្បទានមានចរិកអនុគ្រោះ ដោយពុំមានភ្ជាប់នូវទោះបីលក្ខខណ្ឌណាមួយទៅឲ្យបណ្តារដ្ឋាភិបាល

[26] *BBC .* April 22, 2014. http://www.bbc.com/news/world-asia-27118587 (accessed May 22, 2014).

ក្នុងទ្វីបអាស៊ី ជាពិសេសគឺបណ្តាលប្រទេសដូចជាហ្វីលីពីន ឬថៃនោះជាប្រទេសដែលមានពេលខ្លះបានដើរចេញផុតពីតារាវិថីនៃឥទ្ធិពលរបស់ Wishington ងាកមករកចិនម្តងម្កាល ស្របទៅតាមកាលៈទេសៈនៃផលប្រយោជន៍របស់សម័យកាលនីមួយៗ។ ចិនបន្តរក្សាជំហរគ្រប់ពេលវេលាទោះបីមានវិវាទណាមួយដ៏តូចក៏ដោយ ក៏ចិនរក្សាភាពអត់ធ្មត់ មិនឲ្យកើតមានឡើងជាដាច់ខាតជៀសវាងការធ្វើឲ្យមានភាពមិនល្អប៉ះពាល់ដល់ចិន នូវរូបភាពណាមួយ នៅក្នុងឋានៈប្រទេសចិនជាមិត្តរបស់បណ្តាប្រទេសតតីយលោកនោះ។

## ២.១. ចិន និងអាមេរិក ក្រោមអាណត្តិប្រធានាធិបតី លោកប៊ូស (Bush)

ផ្ទុយពីប៊ីល គ្លីនតុន (Bill Clinton) ប៊ូស (Bush) ចាត់ទុកថាចិនកុម្មុយនិស្តថា ជាគូប្រជែងយុទ្ធសាស្ត្ររបស់អាមេរិក។ ក្រោយពីបានជាប់ឆ្នោតជាប្រធានាធិបតីអាមេរិកភ្លាម ប៊ូសបានបញ្ជាឲ្យពង្រឹងការស្រាវជ្រាវបង្កើតខែមីស៊ីលប្រឆាំងមីស៊ីល ដើម្បីការពារដែនដីអាមេរិក ពីការវាយប្រហារនុយក្លេអ៊ែរជាយថាហេតុពីបណ្តាប្រទេសសត្រូវ។ ប៊ូសក៏បានប្រាប់ឲ្យដឹងដែលថា ប្រទេសជប៉ុនក៏នឹងចូលរួមចំណែកក្នុងផែកការបង្កើតប្រពន្ធ័ខែមីស៊ីលប្រឆាំងនឹងមីស៊ីលដែរ ពីព្រោះតាមសំដីរបស់ប្រធានាធិបតីរូបនេះ អាមេរិកក៏ចង់ការពារផងដែរជប៉ុន និងតៃវ៉ាន់នៅចំពោះមុខបំណងមិនល្អរបស់បក្សសម្ព័ន្ធនៃសភាវអាក្រក់ជាពិសេសកូរ៉េខាងជើង។

ប៉ុន្តែថ្នាក់ដឹកនាំចិនឆោត យល់ភ្លាមថាគម្រោងខែមីស៊ីលប្រឆាំងមីស៊ីលរបស់អាមេរិកនេះជាការត្រៀមលក្ខណៈធ្វើសង្គ្រាមក្នុងករណីណាដែលមានភាពអាសន្នកើតឡើង នៅក្នុងតំបន់ដែសមុទ្រតៃវ៉ាន់។ [27]ប្រសិនបើជានៅថ្ងៃណាមួយសង្គ្រាមមែននៅក្នុងតំបន់នេះ ជប៉ុនដែលជាសម្ព័ន្ធមិត្តរបស់អាមេរិកក៏នឹងចូលរួមកោះតៃវ៉ាន់ដែរ។ នេះហើយជាប្រភពនៃក្តីព្រួយបារម្ភរបស់ចិន។ ម៉្យាងវិញទៀត ចិនបារម្ភពីព្រោះនៅឆ្នាំ ២០០៥ ទីក្រុងវ៉ាស៊ីនតោន និងតូក្យូបានប្រកាសរួមគ្នាជាសម្លេងតែមួយថាជាពេលពីនេះទៅជាដែនសមុទ្ររួមយុទ្ធសាស្ត្ររួមសំខាន់ជាងគេរបស់អាមេរិក និងរបស់ជប៉ុន។

លើសពីនេះទៅទៀត ចិនមិនសប្បាយចិនពីព្រោះ ពីឆ្នាំ ២០០១ ដល់ ២០០៦ អាមេរិកក្រោមការគ្រប់គ្រងរបស់ប៊ូស និងជប៉ុនបានពង្រឹងឲ្យបានរឹងមាំលើសពេលណាៗទាំងអស់ សម្ព័ន្ធភាពជាប្រវត្តិសាស្ត្ររបស់គេ។ សំនុំរឿងមួយទៀតដែលជាបញ្ហាធំនៅចន្លោះចិន និងអាមេរិកគឺឧបទ្វីប ប៉ុន្តែមកទល់ពេលនេះ ចប់ហើយ ហួសហើយ សម័យដែលចិននិងអាមេរិកចាប់ដៃគ្នាក្នុងនាមជាដៃគូរ

[27] ដកស្រង់ចេញពីសៀវភៅមហាយក្សចិនភូមិសាស្ត្រនយោបាយនៃប្រទេសចិន ទំព័រទី ៨៣ និពន្ធដោយ ហ្សង់ ហ្វ្រង់ស័រតោន់ បោះពុម្ពផ្សាយ ខែវិច្ឆិកា ឆ្នាំ ២០១២

យុទ្ធសាស្ត្រ ដើម្បីទប់ទល់នឹងសហភាពសូវៀត។ ពីពេលនេះតទៅ មហាអំណាចទាំងពីរចៀសមិនរួចពីប្រឈមមុខដាក់គ្នាពីបញ្ហាថ្មីៗទៀត ជាពិសេសបញ្ហាសមុទ្រចិនខាងត្បូង។ ហើយក៏ទាក់ទងនឹងវិស័យសេដ្ឋកិច្ច ពីព្រោះតែការអភិវឌ្ឍលឿនរហ័សពេករបស់ចិន។ ប្រឈមលើវិស័យយោធានិងនយោបាយពីព្រោះ តែមហិច្ចតារបស់ចិន ក្នុងការក្លាយជាមហាអំណាចពិភពលោក និងពីព្រោះសមុទ្រចិនខាងត្បូង និងអាស៊ានជាចំណុចក្តៅជាងគេបង្អស់មួយនៅលើផែនទីនយោបាយពិភពលោកបច្ចុប្បន្ន។

## ២.២. ចិន និងអាមេរិក ក្រោមអាណត្តិប្រធានាធិបតី លោកអូបាម៉ា (Obama)

ដោយសម្គាល់ឃើញសកម្មភាពដែលបានរៀបរាប់ខាងលើនេះជានយោបាយ ជោគជ័យរបស់ចិន ទើបរដ្ឋកាល Barack Obama បានថតសម្លេងធ្វើតាមចិនដោយយកអាស៊ានជាមូលដ្ឋានស្នូលក្នុងការ កែលំអរូបភាពរបស់អាមេរិកក្នុងទស្សនៈរបស់អាស៊ាន។ រហូតដល់ឆ្នាំ ២០១០ រដ្ឋការ **Obama** បានខ្នះខ្នែងយកចិត្តទុកដាក់ទីក្រុងប៉េកាំងពីព្រោះ ផ្ទុយពីរដ្ឋការប៊ូស ដែលមានជំហរឯកតោភាគីនិយម លោកអូបាម៉ាយល់ឃើញថា ពិភពលោកសព្វថ្ងៃនេះ ជាពិភពលោកពហុប៉ូលហើយចង់ឬ មិនចង់ចិនជាមហាអំណាចនៃប៉ូលមួយស្រេចបាត់ទៅហើយ។ នៅក្នុងបរិបទនេះអាមេរិកគ្មានជម្រើសអ្វីផ្សេងក្រៅពីទទួលស្គាល់តួនាទីដ៏សំខាន់របស់ចិនលើឆាកអន្តរជាតិ ហើយគឺនៅកាលៈទេសៈនេះឯងដែលគេចាប់ផ្តើមលឺល្ចិចល្ចៀងថា ទីក្រុងវ៉ាស៊ីន និងទីក្រុងប៉េកាំងអាចនឹងបង្កើតជំនួបកំពូលទ្វេភាគី G2 មួយឡើងទៀតផង។

ក៏ប៉ុន្តែនៅឆ្នាំ ២០១០ ដដែលនោះ បន្តិចម្តងៗស្រាប់តែអាមេរិកប្តូរឥរិយាបថភ្លាមជាក់ស្តែងលោកស្រីក្រសួងការបរទេសអាមេរិក ហ៊ីលឡារី ក្លីនតុន (Hillary Clinton) បានប្រកាសគាំទ្រក្រុមហ៊ុន Gologle ដែលកាលនោះមានទំនាស់ខ្លាំងជាមួយអាជ្ញាធរចិន។ ជាក់ស្តែងអាមេរិកបានសម្រេចលក់អាវុធសរុបតម្លៃ ៦លានដុល្លារ ទៅឲ្យកោះតៃវ៉ាន់ហើយលោកអូបាម៉ាថែមទាំងទទួលជួបជាមួយសម្តេចសង្ឃ ដាឡៃឡាម៉ា (Dalai Lama) ទៀតផង។

តាមពិត ការដែលអាមេរិកចាប់ផ្តើមកាចដាក់ប្រទេសចិនវិញនេះ មិនមែនជារឿងចៃដន្យទេ។ អ្នកដឹកនាំកំពូលៗរបស់សហអាមេរិក ចាប់ផ្តើមគុំទីក្រុងប៉េកាំងនិងចាប់ផ្តើមលែងទុកចិត្តទីក្រុងប៉េកាំង។ មូលហេតុច្រើនយ៉ាង។

ម្យ៉ាងគឺមកពីលោកអូបាម៉ាអន់ចិត្តខ្លាំង ដោយហេតុថាកាលដែលលោកបានអញ្ជើញទៅបំពេញទស្សនកិច្ចនៅប្រទេសចិន ក្នុងខែវិច្ឆិកាឆ្នាំ២០០៩ ថ្នាក់ដឹកនាំចិនរាំងមិនឲ្យលោកធ្វើដំណើរទៅទី

កន្លែងមួយចំនួន ដែលសេតវិមានបានដាក់ពាក្យជាមុនសុំឲ្យលោកប្រធានាធិបតីអាមេរិកទៅបំពេញទស្សនកិច្ច។

មូលហេតុម្យ៉ាងទៀត ដែលធ្វើឲ្យលោកអូបាម៉ាមិនពេញចិត្ត គឺឥរិយាបថរបស់ប្រទេសចិននៅក្នុងជំនួបកំពូល ស្តីពីការប្រែប្រួលអាកាសធាតុនៅទីក្រុងកូប៉ែនហាក (Copenhague) ប្រទេសដាណឺម៉ាកក្នុងឆ្នាំ២០០៩។ កាលនោះលោកនាយករដ្ឋមន្ត្រីចិន វេន ជៀប៉ៅ (Wen Jiabao) មានវត្តមាននៅទីក្រុងកូប៉ែនហាក (Copenhague) មែនពិត តែបានបញ្ជូនមន្ត្រីជាន់ខ្ពស់មួយរូបឲ្យមកជួបលោកក្នុងអង្គប្រជុំសំខាន់ៗដែលមានសុទ្ធតែប្រមុខរដ្ឋឬ ប្រមុខរដ្ឋាភិបាល។

រីឯមូលហេតុចុងក្រោយ និងសំខាន់ជាងគេដែលធ្វើឲ្យលោកអូបាម៉ា មិនពេញចិត្តគឺចិនបន្តគាំទ្រប្រទេសអ៊ីរ៉ង់ ក្នុងសំណុំរឿងនុយក្លេអ៊ែរ។

រហូតដល់ដើមឆ្នាំ២០១០ ប្រធានាធិបតីអាមេរិកបានពង្រឹងនិងពង្រីកសហប្រតិបត្តិការជាមួយទីក្រុងប៉េកាំង បានសុខចិត្តបិទភ្នែកនៅចំពោះមុខការរំលោភសិទ្ធិមនុស្សនៅប្រទេសចិន នៅចំពោះមុខនយោបាយវាយបង្ក្រាបទៅលើជនជាតិ អ៊ុយហ្គួរ (Ouigours) ព្រមទាំងទៅលើជនជាតិទីបេ (Tibet) ដោយឡែក លោកអូបាម៉ា ថែមទាំងបានយល់ព្រមផ្តើមកិច្ចសន្ទនាជាមួយភូមាដែលជាប្រទេសមិត្តរបស់ចិនទៀតផង។ ជាថ្នូរវិញលោកអូបាម៉ា ចង់ឲ្យចិនជួយគាំទ្រការបង្កើតទណ្ឌកម្មអន្តរជាតិទៅលើប្រទេសអ៊ីរ៉ង់។ តែសម្រេចសម្រួលទៅចិនធ្វើមិនដឹង មិនព្រមធ្វើសម្បទាន។

មែនទែនទៅទាំងអូបាម៉ា ទាំងថ្នាក់ដឹកនាំចិនគ្មានជម្រើសអ្វីក្រៅពីពង្រឹងគោលជំហររបស់គេរៀងៗខ្លួន ពីព្រោះមហាអំណាចទាំងពីរមានប្រយោជន៍ខ្វែងគ្នាជាដៃគូរប្រជែងនឹងគ្នា លើឆាកអន្តរជាតិ។ ក្នុងន័យនេះ សំនុំរឿងប្រទេសចិនក្នុងនាមជាមហាអំណាចយោធាត្រូវបានគេលើកឡើងជាថ្មីក្នុងឆ្នាំ២០០៩។ អ្នកដែលបាននិយាយពីបញ្ហានេះមុនគេ គឺវិទ្យាស្ថានសិក្សាយុទ្ធសាស្ត្រអន្តរជាតិ (IISS) នៅទីក្រុងឡុងដ៍ប្រទេសអង់គ្លេសដែលបានចេញផ្សាយរបាយការណ៍ឆ្នាំ២០០៩ របស់ខ្លួន។ បន្ទាប់មកនៅចុងឆ្នាំ ២០០៩ ដដែលនោះ ដល់វេនក្រសួងស៊ើបការណ៍សំខាន់របស់អាមេរិកវិញម្តងដែលបានចេញផ្សាយរបាយការណ៍មួយ។ ជារបាយការណ៍ដែលគូសបញ្ជាក់ថា ចិនជាប្រទេសដែលអាចនឹងគំរាមផលប្រយោជន៍អាមេរិកខ្លាំងជាងគេ។ ពីរបីថ្ងៃក្រោយមក ក្រសួងការពារជាតិអាមេរិកផ្ទាល់តែម្តងបានអះអាងថា មិនយូរមិនឆាប់កងទ័ពជើងទឹក និងជើងអាកាសរបស់អាមេរិកនៅតំបន់ប៉ាស៊ីហ្វិក និងត្រូវប្រឈមមុខនឹងការគំរាមគំហែងពីសំណាក់ប្រទេសចិនជាមិនខានឡើយ។ រីឯចិនវិញបញ្ចេញប្រតិកម្មឆ្លងតបថា អាមេរិកដែលនៅតែមានគំនិតចាស់គំរឹលបន្សល់ពីសម័យសង្គ្រាមត្រជាក់ចេះតែនិយាយបង្អើល និងបំផ្លើសឲ្យពិភពលោកខ្លាចប្រទេសចិន។

តាមពិតថវិការយោធារបស់ចិន កើនឡើងជាលំដាប់មែនពីមួយឆ្នាំទៅមួយឆ្នាំ។ ទីក្រុងប៉េកាំងមានគោលដៅសំខាន់ៗ ៣ តាមរយៈទំនើបកម្ម និងការអភិវឌ្ឍវិស័យយោធារបស់ខ្លួន។ ទីមួយគឺបង្ការកុំឲ្យប្រទេសមហាអំណាចដូចយ៉ាង អាមេរិក រុស្ស៊ី ឬក៏ឥណ្ឌាវាយប្រហារមកលើប្រទេសចិន។ ទីពីរគឺការការពារព្រំដែននៃប្រទេស។ ទីបីគឺ ទប់ទល់នឹងពួកផ្តាច់ទឹកដីនិយមក្នុងប្រទេសដូចជា នៅទីបេ និងស៊ីងជាំងជាដើម។

មានគោលដៅមួយទៀត ដែលរបបទីក្រុងហាប៉េកាំងខ្លួនឯងមិនដែលនិយាយ និងមិនដែលទទួលស្គាល់ គឺចិនមហិច្ឆតាចង់ធ្វើឲ្យជញ្ជីងតុល្យភាពពិភពលោក ជាពិសេសជញ្ជីងតុល្យភាពនៃតំបន់អាស៊ីប៉ាស៊ីហ្វិក ឈប់ផ្អៀងទៅខាងសហរដ្ឋអាមេរិកខ្លាំងពេក។

ទល់តែមានកងទ័ពខ្លាំងបំពាក់ទៅដោយសព្វាវុធទំនើប ជាពិសេសខាងជើងអាកាសនិង ជើងទឹក ទើបប្រទេសចិនអាចដាក់គំនាមទៅលើអាមេរិកបាន ឧទាហរណ៍នៅក្នុងដំណោះស្រាយកោះតៃវ៉ាន់ និងសមុទ្រចិនខាងត្បូងជាដើម។

## ៣. ជំហររបស់ឥណ្ឌាក្នុងបញ្ហាសមុទ្រចិនខាងត្បូង

មូលហេតុចម្បងដែលនាំឲ្យមានបំពាក់សព្វាវុធ និងទំនើបកម្មកងទ័ពក៏ស្ថិតនៅបរិបទយុទ្ធសាស្ត្រ ស្វ័យការពារនៅចំពោះមុខនៃការងើបឡើយមិនប្រក្រតីខាងនយោបាយរបស់អ្នកភូមិផងពីរនាក់ដែលជាដៃគូរសត្រូវជាយូររបស់ឥណ្ឌាគឺ ប៉ាគីស្ថាន និងចិននោះ។ ក្រៅពីនេះ កងទ័ពជើងទឹករបស់ចិនកំពុងប្រែក្លាយទៅជាកម្លាំងគំរាមកំហែងមួយមកលើផ្លូវនាវាចរណ៍របស់ឥណ្ឌាលើសមុទ្រ ឥណ្ឌាដូចជាតំបន់រុករកប្រេងដ៏ទៃទៀតដែលឥណ្ឌាត្រូវបានវៀតណាមប្រគល់សិទ្ធិឲ្យធ្វើការរុករក និងធ្វើអាជីវកម្មលើតំបន់សមុទ្រចិនខាងត្បូង។ ក្នុងបរិបទនេះឥណ្ឌាឆ្លៀតប្រើប្រាស់វៀតណាម ដើម្បីពង្រឹងឥទ្ធិពលរបស់ខ្លួនក្នុងតំបន់ និងលើសមុទ្រចិនខាងត្បូង បើវៀតណាមវិញចង់កេងលេងសន្លឹកបៀរឥណ្ឌាដើម្បីសមតាទៅនឹងអនុភាពជាមួយចិននោះ។ ក្នុងផលប្រយោជន៍រួមចំពោះមុខ និងយូរអង្វែង ឥណ្ឌាប្តេជ្ញាជំរុញកិច្ចសហប្រតិបត្តិការ ក្នុងការរកស៊ីប្រេងជាមួយវៀតណាម ដែលទោះបីជាមានការប្រឆាំងជំទាស់ពីអាជ្ញាធរចិនក៏ដោយ។

ឥណ្ឌានិងរដ្ឋសមាជិករបស់អាស៊ានទាំងអស់ បានចែករំលែកទំនាក់ទំនងសេដ្ឋកិច្ចដែលមានការវិវត្តន៍កើនឡើងជាបន្តបន្ទាប់រហូតដល់ពេលបច្ចុប្បន្ននេះ។ សហរដ្ឋអាមេរិកនិងឥណ្ឌាបានពង្រឹងទំនាក់ទំនងយុត្តិសាស្ត្រនៅក្នុងតំបន់អាស៊ាន ប៉ុន្តែការពង្រឹងយុត្តិសាស្ត្រជាមួយចិន វាហាក់បីដូចជាមិនមែនជារឿងងាយស្រួលទេ ក្នុងខណៈពេលយោធារបស់ប្រទេសចិនបានកើនឡើងគួរឲ្យ

កត់សម្គាល់។ ឥណ្ឌា និងចិនជាញឹកញយតែងតែមើលមុខគ្នាមិនចំដោយសារជម្លោះប្រវត្តិសាស្ត្រមួយចំនួន តែឥណ្ឌាក៏មិនព្រងើយកន្តើយចំពោះបញ្ហាសមុទ្រចិនខាងត្បូងដែរ នៅខណៈពេលដែលសមាជិកអាស៊ានជាច្រើនរងគ្រោះដោយសារឥទ្ធិពលសេដ្ឋកិច្ចរបស់ចិន។ កិច្ចប្រជុំរបស់អាស៊ាន និងឥណ្ឌាក៏ត្រូវបានបង្កើតឡើងក្នុងទំនាក់ទំនងពហុភាគីក៏ព្រោះតែបងធំក្នុងអាស៊ីមួយនេះក៏សំឡឹងឃើញផលប្រយោជន៍របស់ខ្លួនមិនខុសពីអាមេរិកប៉ុន្មាននោះទេ ដើម្បីទប់ទល់ឥទ្ធិពលរបស់មហាយក្សចិន។ នៅក្នុងពិភពលោក ទោះបីគេដឹងថា ប្រទេសឥណ្ឌាមួយនេះជីវភាពរស់នៅរបស់ប្រជាជននៅមានកំរិត ប៉ុន្តែគ្មាននរណាម្នាក់ភ្លេចថាប្រទេសដែលមានប្រជាជនច្រើនបន្ទាប់ពីចិនមួយនេះអាចបង្កើត និងធ្លាប់សាកល្បងគ្រាប់បែកបរមាណូរបស់ខ្លួនទៀតផង ជាហេតុដែលធ្វើឲ្យប្រទេសនៅក្នុងអាស៊ានដែលមានជម្លោះសមុទ្រចិនខាងត្បូងជាមួយចិនមិនអាចបំភ្លេចបាន។

## ៤. ជំហររបស់អូស្ត្រាលីក្នុងបញ្ហាសមុទ្រចិនខាងត្បូង

សមុទ្រចិនខាងត្បូងជាចំណុចក្តៅក្នុងយុទ្ធសាស្ត្រការពារជាតិរបស់អូស្ត្រាលី លោក Stephen Smith រដ្ឋមន្ត្រីការពារជាតិរបស់អូស្ត្រាលីបានជំរុញឲ្យកងទ័ពបង្កើនកម្លាំងការពារភាគខាងជើងរបស់អូស្ត្រាលី។ ព្រោះដើម្បីសតវត្សទី ២១នេះគន្លឹះសំខាន់ក្នុងខឿនសេដ្ឋកិច្ចរបស់អូស្ត្រាលីគឺបញ្ហាធ្វើអាជីវកម្មរុករករ៉ែនៅម្តុំភាគខាងជើងរបស់ប្រទេសនេះ។ ដូច្នេះការមានមុខជាយោធាទាំងជើងគោក និងជើងអាកាសមានសារៈសំខាន់សម្រាប់ការការពារសម្បត្តិធម្មជាតិ សេដ្ឋកិច្ចនៅទីនេះ។ ក្រៅពីនេះ នៅមានបញ្ហាភូមិសាស្ត្រនយោបាយមួយទៀតនៅតំបន់ភាគខាងជើង និងពាយ័ព្យរបស់អូស្ត្រាលីគឺជាប់ទៅនឹងសមុទ្រចិនខាងត្បូង និងតំបន់សមុទ្រឥណ្ឌា។ ដូច្នេះ អូស្ត្រាលីបានចាត់ទុក តំបន់ភាគខាងជើងមានសារៈសំខាន់ព្រោះទីនេះ ជាចំណុចក្តៅដែលមានភាពងាយស្រួលកកើត ទៅជាការប្រទូស្តរាយដោយកំលាំងបាយ ដល់តំបន់សមុទ្រចិនខាងត្បូងនោះ។ ប្រទេសអូស្ត្រាលីអះអាងថាខ្លួនមានផលប្រយោជន៍ស្របច្បាប់មួយគឺការថែរក្សា ការពារសន្តិសុខ និងស្ថេរភាពព្រមទាំងគោរពច្បាប់អន្តរជាតិ និងសេរីភាពក្នុងការធ្វើនាវាចរណ៍ក្នុងតំបន់ជម្លោះខាងលើ។ ជាក់ស្តែង ៥៧% នៃការនាំទំនិញចេញរបស់អូស្ត្រាលី និង៤៨% នៃទំនិញអូស្ត្រាលីត្រូវឆ្លងកាត់សមុទ្រចិនខាងត្បូង។

## កថាខណ្ឌទី ៣៖ ទិដ្ឋភាពច្បាប់អន្តរជាតិនៃជម្លោះសមុទ្រចិនខាងត្បូង

### ១.នីតិសមុទ្រអន្តរជាតិ

អនុសញ្ញាស្តីពីច្បាប់សមុទ្រនៃអង្គការសហប្រជាជាតិ ឬគេហៅម្យ៉ាងទៀតថាជាសន្ធិសញ្ញាច្បាប់សមុទ្រគឺជាកិច្ចព្រមព្រៀងដែលបានមកពីសន្និសីទអង្គការសហប្រជាជាតិលើទី៣ (UNCLOS III) ដែលចាប់ផ្តើមពីឆ្នាំ ១៩៧៣ ដល់ ១៩៨២។ [28]អនុសញ្ញាស្តីពីច្បាប់សមុទ្រត្រូវបានឲ្យនិយមន័យថាគឺជាសិទ្ធិនិងការទទួលខុសត្រូវរបស់ប្រជាជាតិ ដែលអាចប្រើប្រាស់ព្រំដែនសមុទ្ររបស់ពួកគេ ដែលអាចជាការបង្ហាញសម្រាប់ការធ្វើជំនួញ បរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងសមុទ្រ។ ក្នុងជម្លោះសមុទ្រចិនខាងត្បូងអនុសញ្ញានេះបានកំណត់ពីដែនសមុទ្រចំពោះរដ្ឋ ដែលបានអះអាងថា ជាកម្មសិទ្ធិរបស់ពួកគេរួមបញ្ចូលទាំងកោះ ផងដែរវាបានកំណត់អំពី សិទ្ធិកាតព្វកិច្ចនិងយុត្តាធិការរបស់រដ្ឋតំបន់សមុទ្រតាំងពី រដ្ឋដែលបានអះអាងទាំងអស់ក្លាយជាភាគីនៃអនុសញ្ញានោះ។ ទាំងនេះគឺជាមូលដ្ឋាននៃការអះអាងដែលមានភាពស្របច្បាប់។ [29]យោងទៅតាមអនុសញ្ញាស្តីពីច្បាប់សមុទ្ររដ្ឋដែលមានព្រំដែនសមុទ្របានអះអាងអំពីព្រំដែនសមុទ្ររបស់ខ្លួននឹងទីប្រជុំមួយចំនួនដូចជាករណីប្រទេសឥណ្ឌូនេស៊ី និងហ្វីលីពីនដែលមានសិទ្ធិកាន់កាប់ក្នុងរយៈចម្ងាយ២០០ ម៉ាយ(Nautical Miles)។ រដ្ឋទាំងអស់មានសិទ្ធិនិងអធិបតេយ្យភាពដើម្បីស្វែងរកនិងរុករកធនធានធម្មជាតិនៅក្នុងទឹកនិងបាតសមុទ្រ ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ពួកគេ។ សមាជិកទាំង៤របស់អាស៊ានដែលពាក់ព័ន្ធក្នុងជម្លោះសមុទ្រចិនខាងត្បូងបានអះអាងកាន់កាប់រយៈចម្ងាយ២០០ ម៉ាយ (Nautical Miles) ពីមាត់ឆ្នេរដីគោករបស់ពួកគេ ពួកគេមានសិទ្ធិ និងអធិបតេយ្យភាពក្នុងការរុករកធនធានធម្មជាតិក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ពួកបាន លើកលែងតែតំបន់ត្រួតស៊ីគ្នានិងតំបន់កំពុងមានជម្លោះ។ រដ្ឋទាំងអស់មានសិទ្ធិអះអាងរយៈចម្ងាយ២០០ ម៉ាយ(Nautical Miles) ពីកោះនៅក្នុងអនុសញ្ញាស្តីពីច្បាប់សមុទ្រ ដែលឈ្មោះថាជាព្រំដែនសមុទ្រធម្មជាតិនៃរយៈកំពស់ខ្ពស់បំផុត ប្រសិនបើមានមនុស្សរស់នៅនឹងជាកន្លែងសេដ្ឋកិច្ចរបស់ពួកគេផ្ទាល់ វាក៏ត្រូវចាត់ទុកជាតំបន់សេដ្ឋកិច្ចផ្តាច់មុខនិងតំបន់ខ្ពង់រាបបាតសមុទ្រ (continental shelf)។ សមាជិកទាំង៤របស់អាស៊ានមិនបានអះអាងសុំកាន់កាប់តំបន់ដែលគិតចេញពីកោះរបស់គេនោះទេ ពួកគេគ្រាន់តែអះអាងកាន់

---

[28] Sea, The United Nations Convention on the Law of the. *The United Nations.* 2012. http://www.un.org/Depts/los/convention_agreements/convention_historical_perspective.htm#Third%20Conference (accessed 06 16, 2014).

[29] Beckman, Robert. "Geopolitics,International Law and the South China Sea." *2012 Tokyo Plenary Meeting*, 2012: 04.

កាប់ពីឆ្នេរសមុទ្ររបស់ពួកគេ។ ជាផលវិបាកការកំណត់ភូមិសាស្ត្រនៅក្នុងតំបន់សមុទ្រចិនខាងត្បូង ត្រូវតែកំណត់យ៉ាងប្រុងប្រយ័ត្នបំផុតដែលមិនត្រឹមតែពិនិត្យរយៈ ចម្ងាយ២០០ ម៉ាយ(Nautical Miles)នោះទេតែត្រូវពិនិត្យលើរយៈចម្ងាយ១២ ម៉ាយ(Nautical Miles) ពីកោះទៀត។

តាំងពីអនុសញ្ញាស្តីពីច្បាប់សមុទ្របានចូលជាធរមាន ច្បាប់នេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រឹងសន្តិភាព សន្តិសុខ សហប្រតិបត្តិការ និងទំនាក់ទំនងយ៉ាងជិតស្និទ្ធិក្នុងចំនោមភាគីសមាជិក ដើម្បីគោរពគោលការណ៍យុត្តិធម៌ និងសិទ្ធិស្មើរគ្នា ច្បាប់នេះបានរក្សាទំនាក់ទំនង និងពង្រីកសហប្រតិបត្តិការណ៍សេដ្ឋកិច្ច ដែលជាគោលការណ៍សំខាន់របស់អង្គការសហប្រជាជាតិដែលបានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ដែលមានគោលដៅសំខាន់រក្សាតំបន់សមុទ្រឲ្យមានសន្តិភាព ជានិរន្តរភាព ហើយទទួលដោយរដ្ឋនិងសហគមន៍អន្តរជាតិយ៉ាងពេញទំហឹង។ នៅក្នុងជម្លោះសមុទ្រចិនខាងត្បូងត្រូវបានប្រមើលមើលដើម្បីស្វែករកដំណោះស្រាយដែលប្រកបដោយទស្សនវិស័យពីរគឺ ការដោះស្រាយចំពោះតំបន់ត្រួតស៊ីគ្នា និងការដោះស្រាយចំពោះការអះអាងកាន់កាប់ប្រជុំកោះនៅក្នុងសមុទ្រនេះ។ [30]ជម្លោះនេះត្រូវបានចាត់ទុកជាបញ្ហាមួយដ៏ស្មុគស្មាញនៅអាស៊ីខាងកើត ហើយជាជម្លោះដ៏គ្រោះថ្នាក់ដែលក្លាយជាជម្លោះអន្តរជាតិ ដែលរហូតដល់ពេលនេះវាមិនទាន់ត្រូវដោះស្រាយ និងគ្រប់គ្រងបាននៅឡើយទេ។ ភាពស្មុគស្មាញនេះកើតឡើងដោយកត្តាជាច្រើនដែលទាក់ទងនឹងយុទ្ធសាស្ត្រសេដ្ឋកិច្ច និងការសុំកាន់កាប់កោះដែលផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្រទេសនីមួយៗ ដូចជាកោះស្ព្រែតលី (Spratlys) ជាបញ្ហាដ៏ចម្បងមួយ និងជាជម្លោះដ៏ក្តៅគគុះក្នុងសហគមន៍អន្តរជាតិ ដើម្បីស៊ើបអង្កេតដើមហេតុពិតប្រាកដហើយឈានដល់ដោះស្រាយយ៉ាងសមស្របមួយ។ អ្វីដែលសំខាន់ជាងនេះទៀតគឺ តំបន់សមុទ្រចិនខាងត្បូងក្លាយជាបញ្ហាដ៏រសើបដល់ប្រជាជាតិទន់ខ្សោយដែលពាក់ព័ន្ធ។

ប្រតិកម្មរបស់ចិនជុំវិញគម្រោងការជំរុញឲ្យមានការផ្តល់សច្ចាប័នមកលើអនុសញ្ញាស្តីពីច្បាប់សមុទ្រនៃអង្គការសហប្រជាជាតិ (UNCLOS) របស់គណៈកម្មាធិការការបរទេសរបស់ព្រឹទ្ធសភាអាមេរិកព្រោះដោយសារមុននេះមកពីមានអត្ថប្រយោជន៍គិតគូរជាបុគ្គល ទើបអាមេរិកតែងតែឈរនៅខាងក្រៅខ្សែរៀននៃអនុសញ្ញា ពេលនេះនឹងនាំឲ្យអាមេរិកមានប្រៀបក្នុងការបំពេញមុខងារដើរតួរជាអ្នកដឹកនាំមកលើរាល់ដំណើរការវិវត្តន៍រីកចម្រើនលើមហាសាគរទាំងឡាយក្នុងអនាគត ហើយក៏ដើម្បីស្វែងរកបង្អែកលើផ្លូវច្បាប់ ដើម្បីអាមេរិកមានកម្លាំងគតិយុត្តិ និងភាពងាយស្រួលក្នុង

[30] Nguyen, Dong Manh. "Settlement of disputes under the 1982 United Nations Convention on the Law of the Sea The case of the South China Sea dispute." *UN-Nippon Foundation* , December 2005: 04.

ការជ្រៀតជ្រែក ធ្វើអន្តរាគមន៍ចូលមកសមុទ្រចិនខាងត្បូងសំដៅដណ្តើមភាពជាអ្នកដឹកនាំក្នុងតំបន់ អាស៊ី ប៉ាស៊ីហ្វិកនេះផង។ ព្រោះនៅក្នុងពេលដែលហេតុការណ៍វិវាទលើម្តុំ Scarorough Shoal ដែលជាតំបន់ជម្លោះដ៏ក្តៅគគុករវាងហ្វីលីពីន និងចិនកំពុងតែតានតឹងនោះលោក Panetta រដ្ឋមន្ត្រីការពារជាតិអាមេរិក បានលើកហេតុផល និងអះអាងអំពីការជំរុញឲ្យមានការផ្តល់សច្ចាប័នមកលើអនុសញ្ញាស្តីពីច្បាប់សមុទ្រដែលអនុសញ្ញានេះនឹងជួយធានាដល់សេរីភាពនាវាចរណ៍របស់អាមេរិកក្នុងក្របខណ្ឌពិភពលោកទាំងមូល។ ពីស្ថានភាពជាអ្នកឈរ នៅខាងក្រៅខ្សែរៀនអាមេរិកក្លាយទៅជាអ្នកដឹកនាំបញ្ហាក្នុងរាល់ការជួបពិភាក្សាទាំងឡាយ ដែល ហេតុការណ៍នេះ នឹងធ្វើឲ្យអាមេរិកមានឥទ្ធិពលមកលើរាល់សកម្មភាពការណ៍វិវត្តន៍រីកចម្រើនរបស់អនុសញ្ញានេះអាស្រ័យទៅតាមប្រទេសហត្ថលេខីនីមួយៗផង។

លោកជំទាវ Hilary Clinton ធ្លាប់បាននិយាយយ៉ាងច្បាស់ថា ដោយពុំមែនជាភាគីចូលរួម ទើបអាមេរិកគ្រាន់តែឈរនៅពីក្រៅនៃគោលការណ៍ទាំងឡាយរបស់ អនុសញ្ញស្តីពីច្បាប់សមុទ្រដោយពុំអាចចូលរួមក្នុងដំណើរការនៃការកំណត់មកលើគោលនយោបាយសមុទ្រ របស់ពិភពលោកបាន។ ដូច្នោះ ទើបតួនាទី និងមុខងាររបស់អាមេរិកនៅមានជំពាក់វាក់វិនមិនច្បាស់លាស់។ លើមូលដ្ឋាននៃការវិវត្ត ប្រែប្រួលឡើងវិញនូវយុទ្ធសាស្ត្រសកលលោក និងយុទ្ធសាស្ត្រអាស៊ីប៉ាស៊ីហ្វិក សហរដ្ឋអាមេរិកតែងតែ មានគោលគំនិតយ៉ាងសកម្មរាល់សកម្មភាពទាំងនៅក្នុងតំបន់សមុទ្រចិនខាងត្បូងទាំងនៅក្នុងតំបន់ ប៉ូលខាងជើងផង។

ផ្តើមចេញពីអត្ថប្រយោជន៍យុទ្ធសាស្ត្រ និងយូរអង្វែងនេះ បាននាំឲ្យមានគំនិតជំរុញឲ្យសភាអាមេរិកត្រូវតែផ្តល់សច្ចាប័នមកលើអនុសញ្ញាស្តីពីច្បាប់សមុទ្រដែលជាកិច្ចការមួយបន្ទាន់ និងចំពោះមុខក្នុងផលប្រយោជន៍របស់មហាអំណាចអាមេរិក។ អនុសញ្ញាស្តីពីច្បាប់សមុទ្រជាក្របខណ្ឌនៃអនុសញ្ញាអន្តរជាតិមួយ ដែលមានភាពទូលំទូលាយបំផុត គ្រប់វិស័យនិងមានឥទ្ធិពលបំផុត ហើយមានបទដ្ឋានច្បាស់លាស់ក្នុងការគ្រប់គ្រង យ៉ាងសុក្រឹត្យមកលើរាល់សកម្មភាពលើសមុទ្រនាពេលបច្ចុប្បន្នចនេះយ៉ាងបំផុតដែរ។ ព្រោះអនុសញ្ញានេះ មិនត្រឹមតែជាមូលដ្ឋានគ្រឹះមួយសម្រាប់របៀបរបបសណ្តាប់ធ្នាប់លើសមុទ្ររបស់ពិភពលោក តែថែមទាំងមានឥទ្ធិពលមួយដ៏ធំ ចំពោះការផ្លាស់ប្តូរប្រែប្រួល និងធ្វើឲ្យល្អប្រសើរក្នុង ទំនាក់ទំនងអន្តរជាតិទៀតផង។ គិតរហូតមកដល់ពេលនេះមានទាំងអស់ ១៦៥ ប្រទេសនិងសហភាពអ៊ឺរ៉ុបដែលបានផ្តល់សច្ចាប័នមកលើអនុសញ្ញានេះទៅសភាពេញអង្គដើម្បីសុំការអនុម័តផ្តល់ សច្ចាប័ននៅឡើយទេ។

ក្នុងប៉ុន្មានឆ្នាំនេះ ភពផែនដីចាប់មានកម្តៅឡើងៗ ដែលធ្វើឲ្យមានការរលាយផ្ទាំងទឹកកក និងភ្នំទឹកកកធ្លាក់បាក់ទាំងផ្ទាំងៗនៅម្តុំប៉ូលខាងជើង លែងកកខ្លាំងដូចមុនទៀត ដែលជាឱកាសមួយដ៏ល្អ នាំឲ្យមានការរុករក និងការអភិវឌ្ឍប្រភពធនធានធម្មជាតិ និងការធ្វើនាវាចរណ៍អន្តរជាតិនាម្តុំទាំងនេះ អាមេរិក ជាប្រទេសមួយមានទំនាក់ទំនងទៅដល់ប៉ូលខាងជើង ទើបអាមេរិកតែងតែស្វែងរកលាភសក្កាៈពីតំបន់នេះ ទន្ទឹមនេះក៏ដើម្បីនាំយកតំបនប៉ូលខាងជើងមកធ្វើជាយុទ្ធសាស្ត្ររបស់ខ្លួនផង។ ក្នុងអនុសញ្ញាស្តីពីច្បាប់សមុទ្រ ក៏បានកសាងក្របខណ្ឌច្បាប់មួយយ៉ាងទូលំទូលាយលើបញ្ហាមួយចំនួន ទាក់ទងពាក់ពន្ធ័ដល់តំបន់ប៉ូលខាងជើងនេះ ដែលក្នុងពេលនោះអាមេរិក ជាប្រទេសដែលឥតទាន់ បានផ្តល់សច្ចាប័នមកលើអនុសញ្ញានេះ ទើបសំណូមពរមួយចំនួនរបស់អាមេរិក ដែលបានលើកឡើងពាក់ពន្ធ័ដល់តំបន់ប៉ូលខាងជើង ពុំត្រូវបានទទួលយក និងទទួលស្គាល់ជាតថភាពឡើយ ដូច្នោះហើយបានជាពេលនេះ មានចលករមួយយ៉ាងផុសផុលក្នុងការជំរុញឲ្យមានការផ្តល់សច្ចាប័នពីសភាអាមេរិកចំពោះអនុសញ្ញានេះ។ អនុសញ្ញាច្បាប់សមុទ្រគឺជាការស្វែងរកមូលដ្ឋានច្បាប់ ដើម្បីអាមេរិកមានលទ្ធភាពធ្វើការជ្រៀតជ្រែក អន្តរាគមន៍យ៉ាងចំហរចូលមកសភាពការណ៍លើសមុទ្រចិនខាងត្បូង។ ចាប់ពីខែ កក្កដា ២០១០ នៅហាណូយ លោកជំទាវ Hilary Clinton បានប្រកាសថា អាមេរិកមានផលប្រយោជន៍លើសមុទ្រចិនខាងត្បូង ហើយអាមេរិកបានទាមទារឲ្យមានអន្តជាតូបនីយកម្ម ពហុភាគីមកលើបញ្ហាសមុទ្រចិនខាងត្បូង។ ជាការពិតកលយុទ្ធរបស់អាមេរិក គឺចង់ឆ្លងតាមរយៈមូលដ្ឋាននៃបទដ្ឋានគតិយុត្តិ ដែលមានចែងក្នុងអនុសញ្ញានេះ ដើម្បីធ្វើការជ្រៀតជ្រែកចូលមកដោយផ្ទាល់ក្នុងបញ្ហាសមុទ្រចិនខាងត្បូងនេះតែម្តង។

អាមេរិក និងចិនមានទស្សនៈខុសគ្នាអំពីរបៀបពន្យល់បកស្រាយ មកលើប្រការមួយចំនួននៅក្នុងអនុសញ្ញាស្តីពីច្បាប់សមុទ្រ ដោយភាគីចិនបានចាត់ទុកថា ប្រទេសទាំងអស់ពុំមានសិទ្ធិជាឯកតោភាគីក្នុងការធ្វើសកម្មភាពយោធា ក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខ(Exclusive Economic Zone) ២០០ ម៉ាយតាមការកំណត់របស់អនុសញ្ញាស្តីពីច្បាប់សមុទ្រតែបើអាមេរិកវិញបានចាត់ទុកថា គ្មានប្រទេសណាមួយមានសិទ្ធិកំណត់ប្រទេសផ្សេងមួយទៀត ក្នុងការធ្វើសកម្មភាពយោធាខាងក្រៅដែនសមុទ្រចេញពីតំបន់សមុទ្រក្នុងរង្វង់ ១២ ម៉ាយ ពីផ្លូវមូលដ្ឋានរបស់ខ្លួននោះឡើយ។ តែបើយើងពិនិត្យទិដ្ឋភាពយុទ្ធសាស្ត្រអន្តរជាតិ គឺអាមេរិកមានគោលគំនិតប្រាកដក្នុងការរារាំង ទប់ស្កាត់ចិនសំដៅដណ្តើមសិទ្ធិដឹកនាំនៅអាស៊ីប៉ាស៊ីហ្វិក បានក្លាយទៅជាតំបន់មួយដ៏សំខាន់ ក្នុងការប្រកួតប្រជែងគ្នាអំពីអានុភាពអន្តរជាតិ និងអំពីភូមិសាស្ត្រនយោបាយ ពិភពលោកនាសហសម័យនេះ ចំពោះចិនវិញបានចាត់ទុកថា អាស៊ីប៉ាស៊ីហ្វិកជាទីកន្លែងផ្ញើរខ្លួន និងជាបង្អែយុទ្ធសាស្ត្រមួយដ៏

សំខាន់ ដើម្បីអភិវឌ្ឍសន្តិភាព ដោយចិនបានវិនិយោគដ៏មហិមាមក លើវិស័យសេដ្ឋកិច្ច នយោបាយការទូតសន្តិសុខ ដែលប្រមូលផ្តុំមកលើតំបន់អាស៊ីប៉ាស៊ីហ្វិកមួយ។ ចំពោះអាមេរិកវិញ បានចាត់ទុកអាស៊ីប៉ាស៊ីហ្វិកមួយគឺជាកន្លែងមួយដល់សំខាន់ដើម្បីអនុវត្ត នូវនយោបាយការទូតនេះ ក្នុងរយៈពេល ១០ឆ្នាំខាងមុខនោះ។ តំបន់អាស៊ីប៉ាស៊ីហ្វិគឺជាកន្លែងប្រមូលផ្តុំនូវដៃគូរសហប្រតិបត្តិការយុទ្ធសាស្ត្រដ៏គន្លឹះរបស់អាមេរិកដូចជា ជប៉ុន កូរ៉េខាងត្បូង អូស្ត្រាលី ហ្វីលីពីន និងថៃ។

ជាតថភាព អាស៊ីប៉ាស៊ីហ្វិក ជាតំបន់លាយលំ និងប្រមូលផ្តុំទៅដោយផលប្រយោជន៍ដ៏សារវន្តរវាងអាមេរិក និងចិន ដោយក្នុងអនាគតទំនាក់ទំនងរវាងអាមេរិក និងចិនត្រូវស្ថិតនៅក្នុងរូបភាពជាកិច្ចសហប្រតិបត្តិការ ឬជាការប្រឈមមុខដាក់គ្នា។ ជាកិច្ចសម្របសម្រួល ឬជាការបដិបក្ខនឹងគ្នាជាការត្រួតត្រាបាននូវទំនាស់វិវាទឬមួយជាការបំផុសបន្ថែមឲ្យមានការខ្វែងការគំនិតគ្នាទៀត។ ទាំងអស់នេះជាសហនិមិត្តមូលហេតុមួយក្នុងការសម្រេចដោយផ្ទាល់ដែលអនុលោមទៅតាមការវិវត្តន៍របស់ស្ថានភាពទាំងមូលនៃភូមិសាស្ត្រនយោបាយអាស៊ីប៉ាស៊ីហ្វិក រវាងប្រទេសមហាអំណាចទាំងពីរក្នុងទំនាក់ទំនងយោគយល់គ្នាទៅវិញទៅមក ហើយទំនាក់ទំនងបដិការរវាងអាមេរិក និងចិននេះក៏ប្រមូលផ្តុំសារៈសំខាន់ជុំវិញតែលើកម្មវត្ថុសមុទ្រចិនខាងត្បូងតែមួយគត់នេះឯង។ ពីដើមឡើយពួកអ្នកកាន់អំណាចរបស់អាមេរិកតែងមានគំនិតចង់គេងចំណេញពីផលប្រយោជន៍បានមកពីអនុសញ្ញាស្តីពីច្បាប់សមុទ្រ ដោយពួកគេគ្មានបំណងចង់អនុវត្តឬបំពេញនូវកាតាព្វកិច្ចណាមួយឡើយ ក៏ប៉ុន្តែដោយដំណើរការពិភពលោកមានការវិវត្តន៍ផ្លាស់ប្តូរប្រែប្រួល នាសភាពការណ៍បច្ចុប្បន្នបានបង្ខំអាមេរិកមើលឃើញថាត្រូវតែអនុម័តដោយឆ្លងតាមច្បាប់អន្តរជាតិទាំងនេះ ដើម្បីអាមេរិកបន្តការពារនូវសិទ្ធិដឹកនាំរបស់ខ្លួនបាន ជាពិសេសគឺក្នុងពេលដែលស្ថានការណ៍លើតំបន់សមុទ្រចិនខាងត្បូងនៅតែក្តៅគគុក មិនថយចុះដូចបច្ចុប្បន្ននេះ។ អនុសញ្ញាស្តីពីច្បាប់សមុទ្រអាចជាកូនសោរក្នុងការរំសាយ ធុងរំសេវគ្រាប់ផ្ទុះនៅលើសមុទ្រចិនខាងត្បូង។ រហូតមកទល់ពេលនេះ ចិនហាក់បីដូចជាពុំមានការសម្រមសម្រួល ធ្វើសម្បទានណាមួយពាក់ពន្ធ័ដល់ការអះអាងដែនអធិបតេយ្យភាពនាម្ចុំកោះ Scarborough Shoal ឡើយ។ អាមេរិកតែងតែលើកហេតុផលថា អនុសញ្ញាច្បាប់សមុទ្របានចែងយ៉ាងច្បាស់ថាការប្រកាសអំណាចយុត្តាធិការ របស់រដ្ឋមួយមកលើធនធានធម្មជាតិក្រោមបាតសមុទ្រត្រូវតែផ្អែកមក លើកត្តាភូមិសាស្ត្ររបស់ខ្សែបន្ទាត់ព្រំដែនសមុទ្រដូចផ្តើមចេញពីខ្សែមូលដ្ឋាន (Base Line)។ នៅក្នុងយុទ្ធសាស្ត្រសកលរបស់លោក Obama បានប្រមូលផ្តុំសារៈសំខាន់មកលើអាស៊ីប៉ាស៊ីហ្វិក ដោយទីក្រុងវ៉ាស៊ីនតោនយល់ឃើញថានីតិសមុទ្រ បានក្លាយទៅជាមធ្យោបាយនិងជាឧបករណ៍សន្តិភាពដល់សំខាន់សម្រាប់បន្ទាត់នយោបាយការទូតរបស់អាមេរិក

នាពេលនេះ។ នីតិសមុទ្រ អាចជាផលចំណេញដល់ពិតប្រាកដ និងចាំបាច់ក្នុងការគិតគូរជាយុទ្ធសាស្ត្ររបស់អាមេរិកមកលើតំបន់សមុទ្រទាំងអស់។ អនុសញ្ញាស្ដីពីច្បាប់សមុទ្រមិនត្រឹមតែជាកូនសោក្នុងការជួយដោះស្រាយ នៅបញ្ហាដ៏ស្មុគស្មាញនិងយូរអង្វែងប៉ុណ្ណោះទេ តែថែមទាំងជាកូនសោរដើម្បីកម្លាំងពិតរបស់អាមេរិកក្នុងឯាកទៅរកគោលដៅសន្តិសុខ និងការបង្កើនអាទិភាព និងកិត្យានុភាពមកលើសភាពការណ៍បច្ចុប្បន្ននេះផង។

## ២.សេចក្តីថ្លែងការស្តីពីការប្រតិបត្តិក្នុងសមុទ្រចិនខាងត្បូងរបស់អាស៊ាន

នៅខែតុលា ឆ្នាំ ២០១៣ កិច្ចប្រជុំកំពូលនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ដែលប្រកាសសសរស្តុបបីដែលត្រូវបានគេឲ្យឈ្មោះថា ការសហប្រតិបត្តិការសន្តិសុខនយោបាយ សេដ្ឋកិច្ច និងវប្បធម៌ ស្ថិតក្រោមបាវចនា សហគមន៍តែមួយ វាសនាតែមួយកំពុងខិតខំស្វែងរកសន្តិភាពយ៉ាងសស្រាក់ សស្រាំដើម្បីសម្រេចឲ្យបានគោលដៅរបស់ខ្លួន។ ទោះបីជាយ៉ាងណាក៏ដោយ គេឃើញថា អាស៊ាននៅតែមានបញ្ហាចម្រោងចម្រាស់ជាច្រើនដែលមិនទាន់ដោះស្រាយចេញ។ នៅពេលនេះបញ្ហាសមុទ្រចិនខាងត្បូងត្រូវបានគេទទួលស្គាល់ថា ជាបញ្ហាជាប់គាំងមួយដែលមិនអាចដោះស្រាយបានយ៉ាងជោគជ័យ ដោយសារភាពខុសគ្នាក្នុងចំណោមសមាជិកអាស៊ានអំពីការគ្រប់គ្រងជម្លោះនៅក្នុងសមុទ្រចិនខាងត្បូងនេះ។ ប៉ុន្តែឥលូវនេះ ដំណោះស្រាយដែលចាប់ផ្តើមលេចឡើងដ៏ល្អបំផុតនោះគឺ ការបង្កើតក្រមប្រតិបត្តិសមុទ្រចិនខាងត្បូង ដើម្បីឆ្លងតបទៅនឹងសមត្ថភាពរបស់សមាជិកអាស៊ានដើម្បីសំរេចសសរស្តុបរបស់ខ្លួនក្នុងឆ្នាំ ២០១៥។

នៅក្នុងខ្លឹមសារនៃសេចក្តីថ្លែងការណ៍ការប្រតិបត្តិសមុទ្រចិនខាងត្បូង រដ្ឋាភិបាលអាស៊ាន និងសាធារណៈរដ្ឋប្រជាមានិតចិន ធ្វើការប្តេជ្ញាជាខ្លាំងដើម្បីពង្រឹងសហប្រតិបត្តិការក្នុងការជំរុញក្នុងការជំរុញភាពជាដៃគូរ និងទុកចិត្តគ្នាទៅវិញទៅមកក្នុងនាមជាអ្នកជិតខាងដ៏ល្អក្នុងទស្សនៈវិស័យសតវត្សទី២១។ សេចក្តីប្រកាសនេះ ក៏ជាការលើកកម្ពស់សេចក្តីប្រកាសរួមឆ្នាំ ១៩៩៧ នៃកិច្ចប្រជុំរវាងសមាជិកអាស៊ាន និងសាធារណៈរដ្ឋប្រជាមានិតចិន។ ក្នុងនោះ សមាជិកទាំងអស់បានអះអាងប្តេជ្ញាចិត្តដើម្បីគោរពគោលការណ៍ធម្មនុញ្ញសហប្រជាជាតិ អនុសញ្ញាស្តីពីនីតិសមុទ្រឆ្នាំ១៩៨២ សន្ធិសញ្ញាសហប្រតិបត្តិការចំណងមិត្តភាពអាស៊ីអាគ្នេយ៍ និងគោលការណ៍ទាំងប្រាំស្តីពីសន្តិសហវិជ្ជមាន និងច្បាប់អន្តរជាតិដទៃទៀតដែលបម្រើប្រយោជន៍ក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរដ្ឋ និងរដ្ឋ។ សំខាន់ជាងនេះទៅទៀត ភាគីក៏បានអះអាងគោរពសេរីភាពក្នុងការធ្វើនាវាចរនៅក្នុងសមុទ្រចិនខាងត្បូងដែលទទួលស្គាល់ជាសកលដោយច្បាប់អន្តរជាតិ និងអនុសញ្ញាស្តីពីច្បាប់សមុទ្រ១៩៨២។

ភាគីគ្រប់រូបធ្វើការកត់សម្គាល់ និងព្យាយាមស្វែងរកដំណោះស្រាយដោយសន្តិវិធី ដោយគ្មានការប្រើកំលាំងទ័ពប្រដាប់អាវុធតាមរយៈការចចារ និងយោគយល់គ្នាទៅវិញទៅមកក្នុងការដោះស្រាយវិវាទដែនទឹកមួយនេះ។ ភាគីទាំងអស់បានបញ្ជាក់យ៉ាងច្បាស់ថារាល់ភាពតានតឹងណាមួយកើតឡើង នោះពួកគេនឹងចាត់វិធានការសំខាន់ក្នុងស្មារតីសហប្រតិបត្តិការ និងយោគយល់ដោយកសាងទំនុកចិត្តដោយរួមបញ្ចូលដូចខាងក្រោម៖

1. ធ្វើការពិភាក្សានិងផ្លាស់ប្តូរទស្សនៈសមស្របទាំងឡាយរវាងមន្ត្រីការពារជាតិ និងមន្ត្រីយោធារបស់ពួកគេ។
2. ធានាយ៉ាងណាធ្វើឲ្យមានការអធ្យាស្រ័យគ្នាទៅ លើប្រជាជនណាមួយ ដែលចូលទៅក្នុងតំបន់គ្រោះថ្នាក់។
3. រាយការណ៍ដល់ភាគីដទៃទៀត អំពីការធ្វើសមយុទ្ធយោធារបស់ខ្លួនជាមួយរដ្ឋផ្សេងទៀត។
4. ផ្លាស់ប្តូរពត៌មានសំខាន់ៗ ទាក់ទងនឹងសន្តិសុខក្នុងតំបន់ ជាពិសេសសមុទ្រចិនខាងត្បូង។

ភាពយូរអង្វែងនៃការស្វែងរកដំណោះស្រាយនៃជម្លោះ គ្រប់ភាគីទាំងអស់នៅតែអាចធ្វើសកម្មភាពរុករក និងអភិវឌ្ឍផ្សេងៗដូចជា៖

- ការការពារបរិស្ថានសមុទ្រ
- ការស្រាវជ្រាវតាមផ្នែកវិទ្យាសាស្ត្រនៅក្នុងសមុទ្រ
- សុវត្ថិភាពធ្វើនាវាចរ និងទំនាក់ទំនងនៅលើសមុទ្រ
- សហប្រតិបត្តិការស្វែងរក និងជួយសង្គ្រោះ
- ការរួមបញ្ចូលបទល្មើសអន្តរជាតិ តែមិនរួមបញ្ចូលការជួញដូរគ្រឿងញៀន ការប្លន់តាមសមុទ្រ និងការធ្វើដំណើរខុសច្បាប់នោះទេពីព្រោះបញ្ហាទាំងនោះស្ថិតលើដែនអធិបតេយ្យភាពរបស់រដ្ឋនីមួយៗ ប៉ុន្តែក្នុងការគោរពការសហប្រតិបត្តិការទ្វេភាគី និងពហុភាគីគួរតែផ្អែកទៅលើកិច្ចព្រមព្រៀងមុនពេលចាត់វិធានការជាក់លាក់ណាមួយ។

មិនត្រឹមតែប៉ុណ្ណោះ ភាគីទាំងអស់ត្រូវតែត្រៀមខ្លួនដើម្បីធ្វើការផ្តល់យោបល់ និងពិភាក្សាទៅលើបញ្ហាដែលទាក់ទងតាមរយៈកិច្ចព្រមព្រៀង រួមបញ្ចូលទាំងកិច្ចពិភាក្សាជាទៀងទាត់ទៅលើការអង្កេតនៃសេចក្តីប្រកាសនេះ ក្នុងគោលបំណងជំរុញភាពជាអ្នកជិតខាង និងតម្លាភាព រក្សាស្ថេរភាពក្នុងតំបន់ប្រកបដោយសន្តិភាព និងនិរន្តភាព។ អ្វីដែលសំខាន់ជាងនេះទៅទៀតភាគីបានទទួលយកគោលការណ៍នៃសេចក្តីប្រកាសនេះ និងជំរុញឲ្យភាគីផ្សេងៗទៀតគោរពយ៉ាងជាប់ខ្ជាន់ដោយយល់

ព្រមអនុម័តក្រមប្រតិបត្តិសមុទ្រចិនខាងត្បូងដោយចុះហត្ថលេខាដោយរដ្ឋមន្ត្រីការបរទេសអាស៊ាន ទាំងអស់ និងអនុរដ្ឋមន្ត្រីការបរទេសរបស់សាធារណៈប្រជាមានិតចិន។

## ៣. ដំណើរការនៃការអនុម័តទទួលស្គាល់ក្រមប្រតិបត្តិសមុទ្រចិនខាងត្បូង

ស្ថានភាពប្រឈមមុខបច្ចុប្បន្នរវាងហ្វីលីពីន និងចិនបានធ្វើឲ្យមានមន្ទិលសង្ស័យជុំវិញប្រសិទ្ធភាព នៃដំណោះស្រាយទាំងឡាយហើយក្នុងករណីដែលភាពប្រឈមមុខគ្នានេះបន្តអូសបន្លាយទៅៗសួរថាតើក្រុមប្រទេសអាស៊ាន នៅមានបំណងចង់ប្រើប្រាស់ក្រមប្រតិបត្តិសមុទ្រចិនខាងត្បូង (Code of Conduct) ដើម្បីរារាំងទប់ស្កាត់នូវភាពប្រឈមមុខរបស់ចិន តើមានន័យអ្វីទៀតនោះ។ តាមពិតទៅ ស្ថានភាពនៃការបែកបាក់មិនឯកភាពផ្ទៃក្នុងរបស់អាស៊ានត្រូវបានបង្ហាញឡើយយ៉ាងច្បាស់លាស់ នាកិច្ចប្រជុំកំពូលអាស៊ានលើកទី២០ នៅភ្នំពេញ ដែលពេលនោះប្រទេសម្ចាស់ផ្ទះបាននិយាយថាភាគីចិនមានយោបល់ថាការតាក់តែងក្រមប្រតិបត្តិតាំងពីដំបូង ហ្វីលីពីន និងវៀតណាម ក៏បានជំទាស់ចំពោះចិនក្នុងការស្នើរបង្កើតក្រុមឥស្សរជនឆ្នើម ១០ នាក់ ដើម្បីជួយតាក់តែងខ្លឹមសារនៃក្រមប្រតិបត្តិនេះ តែទន្ទឹមនេះក៏មានប្រទេសអាស៊ានផ្សេងទៀត ដែលក្នុងនោះមានឥណ្ឌូណេស៊ីបានជំទាស់ទៅនឹងគំនិតរបស់ហ្វីលីពីន ក្នុងការចង់នាំយកយន្តការដោះស្រាយការវិវាទដាក់ទៅក្នុងក្រមប្រតិបត្តិនេះផងដែរ។

ដោយមានក្តីបារម្ភចំពោះសភាពការណ៍ក្នុងតំបន់សមុទ្រចិនខាងក្រោម ដែលជាហេតុនាំឲ្យមានការប្រទូសសារាយដោយអាវុធនោះ ទើបឥណ្ឌូនេស៊ីក្នុងឋានៈជាប្រធានអាស៊ានបានធ្វើសេចក្តីអំពាវនាវមួយដល់បណ្តាប្រទេសអាស៊ីអាគ្នេយ៍ និងចិនសូមឲ្យប្រញាប់ប្រញាល់ព្រមព្រៀងឲ្យបាននូវក្រមប្រតិបត្តិនេះរួមមួយឲ្យបានប្រញាប់។ ក្រៅពីនេះ រដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ីក៏បាន ធ្វើការព្រមានអំពីលទ្ធភាពនៃសភាពការណ៍ ដែលអាចវិវត្តន៍កើតមានឡើងទៅជាភាពស្មុគស្មាញបំផុតហើយដែលអាចជាសភាពការណ៍នេះ កើតហួសហេតុពីក្រមខណ្ឌ័នៃការគ្រប់គ្រង់របស់ខ្លួនទៀតផង។ នៅថ្ងៃទី ១៧មករា ២០១១នេះរដ្ឋមន្ត្រីការបរទេឥណ្ឌូណេស៊ីបានប្រកាសបន្ថែមថា សមាជិកអាស៊ាន និងចិនគួរចាំចាច់ត្រូវធ្វើការជាបន្ទាន់ដើម្បីសម្រេចឲ្យបាននូវរបៀបរបបការពារ រួមមួយនៅក្នុងតំបន់សមុទ្រចិនខាងត្បូងនេះហើយ ក្រមប្រតិបត្តិមួយនេះគួរតែមានលក្ខណៈ ចាប់បង្ខំគឺជាលក្ខខណ្ឌ និងជាសំណូមពរមួយដ៏ចាំចាច់ក្នុងការរារាំង ទប់ស្កាត់នូវគ្រោះថ្នាក់អាសន្នមួយអំពីការប៉ះទង្គិចគ្នាជាកំលាំងអាវុធនៅទីនេះ។

ទន្ទឹមនឹងនេះ លោកក៏បានអះអាងបន្ថែមទៀតថា ចាប់តាំងពីអាស៊ាន និងចិនឯកភាពរួមគ្នាកសាងសេចក្តីប្រកាសស្តីពីក្រមប្រតិបត្តិ (DOC) មួយរហូតដល់សព្វថ្ងៃនេះបាន ៩ឆ្នាំ កន្លងផុតទៅហើយ។ ដូច្នេះល្មមដល់ពេលហើយដែលត្រូវពិភាក្សាចាំចាច់ឈានទៅដល់ការព្រមព្រៀងជាលទ្ធផលជាក់ស្តែងណាមួយ ហើយបាននៅតែបណ្តោយទុកឲ្យសភាពការអាសន្ននេះបន្តអូសបន្លាយទៅមុខទៀត ច្បាស់ជានឹងនាំមកនូវផលវិបាកមួយដល់ស្មុគស្មាញដែលមិនចាំបាច់ត្រូវតែមានទល់តែសោះ។ ការទំនាស់វិវាទទាំងឡាយនៅលើសមុទ្រចិនខាងត្បូង បានធ្វើឲ្យមានសភាពការណ៍តានតឹងរវាងចិន និងបណ្តាប្រទេសភូមិផង ជាពិសេសគឺវៀតណាម និងហ្វីលីពីន។ ក្នុងឋានៈជាប្រធានអាស៊ានឆ្នាំ២០០១ កន្លងរដ្ឋមន្ត្រីការបរទេសឥណ្ឌូណេស៊ីបាននិយាយថា ត្រូវតែជំរុញឲ្យមានការជួបចចាររវាងអាស៊ាន និងចិននៅលើផ្លូវថ្មីមួយ និងជាបន្ទាន់ដោយមិនត្រូវរង់ចាំទៀត ព្រោះពិភពលោក និងតំបន់ទាំងមូលបាននឹងកំពុង រុលទៅមុខហើយ។ ក្នុងការចូលរួមកិច្ចប្រជុំនៅ Lombob នេះដែរក៏មានលោក Surin Pitsawan អគ្គលេខាធិការអាស៊ាន ដែលលោកបាននិយាយថា ចិនកំពុងស្វែងរកនូវដំណោះស្រាយមួយ ចំពោះ អាស៊ានវិញក៏កំពុងស្វែងរកនូវគោលចំហររួមមួយ។ យោងទៅតាមសារពត៌មាន AFP គឺអាស៊ានមានបំណងចង់ដោះស្រាយវិវាទនេះទៅតាមការដោះស្រាយពហុភាគី ក្នុងពេលដែលចិនមាន បំណងចង់ដោះស្រាយរូបភាពជាទ្វេភាគី។ មានមូលហេតុចម្បងមួយជាមូលហេតុរាំងមិនឲ្យ ក្រមប្រតិបត្តិរួមមួយនេះទៅមុខបាន ដោយចិនមានឥរិយាបថស្ទាក់ស្ទើរមិនចង់ប្រឈមមុខ ជាមួយប្លុកអាស៊ានទាំងមូល។ នៅក្នុងទិដ្ឋភាពមួយដែលលោកប្រធានរដ្ឋ Hu Jintao កំពុងបំពេញទស្សនកិច្ចផ្លូវរដ្ឋនៅសហរដ្ឋអាមេរិកនោះ ពួកអ្នកវិភាគសភាពការណ៍អន្តរជាតិបានរំពឹងរង់ចាំថា ទីក្រុងវ៉ាស៊ីតោន នឹងសម្តែងឥរិយាបថនយោបាយផ្តល់ការគាំទ្រដល់អាស៊ានប្រៀបដូចជាកំពែងប្រឈមមុខមួយ តទល់ទៅនឹងអនុភាពយោធាដ៏ខ្លាំងខ្លារបស់ចិននៅក្នុងតំបន់នេះ។

# ជំពូកទី៣៖ យន្តការ និង ការវិវត្តន៍នៃដំណោះស្រាយជម្លោះសមុទ្រចិនខាងត្បូង

## កថាខណ្ឌទី ១៖ យន្តការដោះស្រាយលើវេទិកាអាស៊ាន និងលើឆាកអន្តរជាតិ

អាស៊ានរៀបចំកិច្ចប្រជុំកំពូលជារៀងរាល់ឆ្នាំក្នុងចំណោមសមាជិកទាំង១០របស់ខ្លួនជាមួយបណ្តាលប្រទេសដទៃទៀតដែលត្រូវបានគេហៅថា អាស៊ានបូក (ASEAN+) ដើម្បីចចារនិងពិភាក្សាទាក់ទងនឹងសេដ្ឋកិច្ច ពាណិជ្ជកម្ម និងបញ្ហាដទៃទៀតជាមួយប្រទេសដៃគូរជាច្រើន ក្នុងនោះក៏មានបញ្ហាជម្លោះសមុទ្រចិនខាងត្បូងផងដែរ ត្រូវបានគេមកពិភាក្សាដើម្បីស្វែងរកដំណោះស្រាយដ៏សមស្របមួយរវាងសមាជិកដែលពាក់ពន្ធ័ទាំងអស់។

### ១.ប្រតិកម្មក្រោយកិច្ចប្រជុំកំពូលលើកទី២ រវាងអាមេរិក និងអាស៊ាន (US-ASEAN)

ក្រោយពីកិច្ចប្រជុំកំពូលលើកទី២ អាស៊ាន-អាមេរិកមក សហរដ្ឋអាមេរិកធ្វើការអះអាងដោយបង្ហាញឲ្យចិនឃើញថា តំបន់សមុទ្រចិនខាងត្បូងលែងជាផ្ទះបាយរបស់ចិនតទៅទៀត។ ហើយយុទ្ធសាស្ត្រថ្មីរបស់អាមេរិក គឺជាសញ្ញាដ៏សំខាន់មកផ្សារភ្ជាប់នូវទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយនឹងក្រុមប្រទេសអាស៊ាន ដែលមុននេះអាមេរិកតែងតែព្រងើយកន្តើយ ពុំសូវយកចិត្តទុកដាក់រាប់សិបឆ្នាំ ទុកឲ្យចិនមានលទ្ធភាពវាតទី ពង្រឹងអានុភាពរបស់ខ្លួនទាំងសេដ្ឋកិច្ច នយោបាយ រហូតដល់កម្លាំងយោធាដែលគួរឲ្យមានការព្រួយបារម្ភ។ ក៏ប៉ុន្តែបន្ទាប់ពីការអះអាងចូលរួមរបស់អាមេរិកនៅតំបន់អាស៊ីសារជាថ្មីបានធ្វើឲ្យសភាពការណ៍នៅក្នុងតំបន់នេះ មានការវិវត្តន៍ប្រែប្រួលទៅតាមចរន្តមួយថ្មី។ ឥរិយាបថនយោបាយពេលនេះរបស់អាមេរិក គឺជាការត្រៀមទទួលយកនូវគ្រប់លក្ខខណ្ឌរបស់អាស៊ាន ឲ្យតែខ្លួនបានចូលមកដោយសុខនៅតំបន់នេះ ដោយអាមេរិកលែងទ្រាំទ្របាននូវឥទ្ធិពលមួយកាន់តែរីករាលដាលគ្រប់ទិសទីលើពិភពលោករបស់ចិនតទៅទៀត។ ត្រូវទទួលស្គាល់តថភាពមួយថា ប្រការដែលនាំឲ្យសម្រេចនូវស្ថានភាពពិតមួយយ៉ាងដូច្នេះ គឺចិនបានអត់ធ្មត់រក្សាកិត្យានុភាពនិងតម្លៃការទូតរបស់ចិន ដែលតម្លៃទាំងនេះផ្អែកលើគោលការណ៍សន្តិសហវិជ្ជមាននិងការជួយឧបត្ថម្ភគាំទ្រ ដល់បណ្តាប្រទេសអាស៊ីអាគ្នេយ៍។ [31]ចិនបន្តរក្សាជំហរ ទោះបីមានវិវាទណាមួយដ៏តូចក៏ដោយក៏ចិនរក្សាភាពអត់ធ្មត់ មិនឲ្យកើតមានឡើងជាដាច់ខាតជៀសវាងការធ្វើឲ្យមានភាពមិនល្អ ប៉ះពាល់ដល់រូបភាពរបស់ចិននៅក្នុងតំបន់ ក្នុងឋានៈប្រទេសចិនជាមិត្តរបស់ប្រទេស

[31] *Association of South East Asia Nations .* March 01, 2009. http://www.asean.org/communities/asean-political-security-community (accessed June 2014, 2014).

តតិយលោកនោះ។ ដោយសម្គាល់ឃើញ សកម្មភាពខាងលើនេះ ជានយោបាយជោគជ័យរបស់ចិនទើបរដ្ឋកាល Barack Obama បានថតចំលងធ្វើតាមចិនដោយយកអាស៊ានជាមូលដ្ឋានស្នូលក្នុងការ កែលំអរូបភាពរបស់អាមេរិកក្នុងទស្សនៈរបស់អាស៊ាន ដែលជាយូរមកហើយតែងតែមានការសង្ស័យចំពោះអាមេរិក។ ប្រការដែលអាមេរិកចូលរួមក្នុងសន្ធិសញ្ញាសហប្រតិបត្តិការចំណងមិត្តភាព និងសហប្រតិបត្តិការ The Treaty of Amity and Cooperation) នាឆ្នាំ ២០០៩ ការផ្លាស់ប្តូររបៀបរបបក្នុងការចូលរួមសហការអាចជាបំណងថ្មីមួយរបស់សហរដ្ឋអាមេរិក ក្នុងការខិតចូលមកជិតប្រទេសអាស៊ាន។ ឥលូវនេះ ក្នុងរដ្ឋការរបស់លោក Barak Obama យ៉ាងហោចណាស់គេឃើញថា មហាអំណាចអាមេរិកនេះដូចជាមិនសូវច្រងេងច្រងាង អុងអាត់និងតាំងខ្លួនជាបងធំដើរបង្រៀនប្រដៅគេដូចមុនទៀត។ ហើយពួកប្រទេសអាស៊ានក៏លែងមានអារម្មណ៍មិនល្អ យល់ឃើញថាពួកខ្លួនលែងជាកូនអុក នៅក្នុងនយោបាយរបស់អាមេរិកទៀត ដែលនេះធ្លាប់ជាទស្សនទានមួយកើតឡើងក្នុងសម័យសង្គ្រាមត្រជាក់ ពន្យល់ទុកមកជាសហានិមិត្តហេតុ ក្នុងផ្នត់គំនិតរបស់អ្នកនយោបាយគ្រប់រូប។ ក្នុងបរិបទនៃជំនោរថ្មីនេះ ក្រុមប្រទេសអាស៊ានចិញ្ចឹមគំនិត និងសង្ឃឹមថានឹងធ្វើការសម្របសម្រួល អូសទាញពួកប្រទេសមហាអំណាចធ្វើយ៉ាងណាឲ្យមានប្រយោជន៍ដល់តំបន់មួយ ដែលធ្លាប់ត្រូវបានហែកហួរដោយមនោគមវិជ្ជាឲ្យមានដំណើរវិវត្តន៍រីកចម្រើន។ បញ្ហាដែលចោទឡើងនៅទីនេះ តើពួកប្រទេសអាស៊ានមានលទ្ធភាព មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីសម្របសម្រួលជាមួយមហាអំណាចទាំងនេះ ឲ្យស្របតាមផលប្រយោជន៍ខ្លួនហើយឬនៅ?

ការផ្សារភ្ជាប់គ្នារវាងអាមេរិក និងអាស៊ាន ក្នុងវេទិការបស់បណ្តាថ្នាក់ដឹកនាំ ដែលត្រូវបានហៅថាកិច្ចប្រជុំកំពូលអាស៊ីប៉ូព៉ា នោះដែលជារង្វាស់មួយដ៏ល្អបំផុត អំពីការងើបឡើងរបស់លទ្ធិយុទ្ធសាស្ត្រប្រាកដនិយម។ ការផ្សារភ្ជាប់ទំនាក់ទំនងនេះ បានអនុញ្ញាតឲ្យអាមេរិកជួសមុខឲ្យប្លុកអាស៊ានលើកឡើងនូវបញ្ហាទាំងឡាយដែលមានចរិតសំខាន់របស់តំបន់ដូចជា សមុទ្រចិនខាងត្បូងនិងបណ្តាបញ្ហាសន្តិសុខដែលមានលក្ខណៈមិនមែនប្រពៃណី ដូច្នេះអាមេរិកអាចធ្វើការទិទៀនចិនបានក្នុងក្របខណ្ឌចង្អៀត ឬចំហរជាមួយក្រុមប្រទេសអាស៊ាន ឬយ៉ាងហោចណាស់ក៏ការទិទៀនទាំងនេះមានការឯកភាពយល់ព្រមពីអាស៊ានផងដែរ ព្រោះគេអាចបកស្រាយពីចំណុចនេះនៅពេលដែលគេឃើញហេតុអ្វីបានជាចិនធ្វើការប្រតិកម្មយ៉ាងខ្លាំងមកលើពាក្យសំដីរបស់លោកជំទាវ Hillary Clinton ពេលដែលគេបានថ្លែងនៅហាណូយអំពីការវិវាទលើព្រំដែនសមុទ្រ ដែលយូរមកហើយភាគីនីមួយៗមានការលាក់លាម មិនចំហរនូវទស្សនៈរៀងៗខ្លួនអំពីបញ្ហាទំនាស់ដ៏រសើបនេះ។

ចិនទទួលបានផលប្រយោជន៍ជាច្រើនពីទំនាក់ទំនង និងភាពជិតស្និទ្ធរបស់ខ្លួនជាមួយអាស៊ាន ក្នុងឋានៈជាប្រទេសមហាអំណាច បានចុះហត្ថលេខាលើសន្ធិសញ្ញាចំណងមិត្តភាព និងសហប្រតិបត្តិការនៅឆ្នាំ ២០០៣ បន្ទាប់មកក៏ចាប់ផ្តើមចចារពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយអាស៊ានតាំងពីឆ្នាំ ២០០០ មកម្ល៉េះ។ ចិនចង់បង្ហាញជាសាធារណៈថា ខ្លួនជាប្រទេសដំបូងដែលស្ថិតនៅខាងក្រៅតែបានចូលរួមក្នុងសន្ធិសញ្ញាចំណងមិត្តភាពនិងសហប្រតិបត្តិការ ស្តីពីតំបន់អាស៊ីអាគ្នេយ៍មួយដែលពុំមានអាវុធនុយក្លេអ៊ែរ ដែលទោះបីជាទស្សនៈអាស៊ានចំពោះចិនពេលនោះ នៅស្ទាក់ស្ទើរនៅឡើយ។

ក្នុងបរិបទថ្មី សហរដ្ឋអាមេរិកបានទទួលតួនាទីស្នូលដ៏ចម្បងរបស់អាស៊ាន ក្នុងការកសាងតំបន់ ហើយប្រធាធិបតីអាមេរិកជាអ្នកដើរតួនាទីសំខាន់ក្នុងការអនុវត្តន៍នូវជំហ៊ានការទូតថ្មី និងមានភាពអចិន្ត្រៃយ៍ទាំងនេះ។ ប្រធានាធិបតី Obama បានសម្តែងការគាំទ្រនូវតួនាទីដ៏សំខាន់របស់អាស៊ានក្នុងការកសាងសហគមន៍តំបន់ នាពេលដែលមានការជួបប្រាស្រ័យដំបូងរវាងសហរដ្ឋអាមេរិក និងប្រមុខអាស៊ាននៅសិង្ហបុរីនាចុងខែ វិច្ឆិកា ឆ្នាំ ២០០៧ ព្រោះពេលនោះពុំមាននរណាម្នាក់នឹកស្មានថា អាមេរិកនឹងមានជំហានសកម្មក្នុងការចង់ចូលរួម EAS នៅឡើយ ហើយទន្ទឹមនេះ ភាគីអាមេរិកក៏បានស្នើអញ្ជើញប្រមុខអាស៊ានទាំងអស់ ទៅចូលរួមប្រជុំ ជាមួយអាមេរិកនៅវ៉ាស៊ីនតោនទៀតផង។ មានមតិជាច្រើនធ្វើការប៉ាន់ស្មានថា ពេលដែលរៀបចំកិច្ចប្រជុំ APEC នៅ Haiwaii ពេលនោះប្រហែលជាសហរដ្ឋអាមេរិកនឹងមានសំណើរថ្មីមួយសម្រាប់រចនាសម្ព័ន្ធក្នុងតំបន់ បន្ទាប់ពីការផ្តួចផ្តើមរបស់អូស្រាលីស្តីពីបង្កើតឡើងនូវសហគមន៍អាស៊ី ប៉ាស៊ីហ្វិក មួយត្រូវបានបដិសេធ។ ឥរិយាបថដាច់ខាត និងបន្ទាន់របស់អាមេរិកនៅអាស៊ីអាគ្នេយ៍សំខាន់ផ្តោមមកលើចិន ប៉ុន្តែឥរិយាបថនេះ បានជះឥទ្ធិពលយ៉ាងទូលំទូលាយ ព្រមទាំងបានរុញពួកប្រទេសមហាអំណាចផ្សេងទៀតដូចជា រុស្ស៊ី និងឥណ្ឌា ឲ្យស្ថិតនៅក្នុងស្ថានភាពមួយបាត់ភាពម្ចាស់ការទៅវិញ។ ដោយឡែកចំពោះប្រទេសមហាអំណាចថ្នាក់តំបន់វិញដូចជាជប៉ុន អូស្ត្រាលី និងកាណាដាក៏ត្រូវពិនិត្យឡើងវិញ និងកែសម្រួលគោលនយោបាយការបរទេសរបស់ប្រទេសខ្លួន ឲ្យស្របតាមចរន្តវិវត្តន៍របស់អាស៊ីផងដែរ។ និយាយជារួម ទីលានទាត់បាល់មួយថ្មីដែលមានសកម្មភាពផុសផុល ត្រូវបានបង្កើតឡើងក្រោមការគាក់តែង និងគ្រប់គ្រងទៅដោយក្រុមប្រទេសអាស៊ាន។

នៅមុនពេលសម្រេចបាននូវទិសដៅទាំងនេះ គឺគោលដៅនយោបាយរបស់អាមេរិក ចំពោះតំបន់អាស៊ីអាគ្នេយ៍បានឆ្លងកាត់ដំណាក់កាលជាច្រើន ដូចនៅមុនឆ្នាំ ១៩៩០ ទំនាក់ទំនងរបស់ក្រុងវ៉ាស៊ីនតោន ជាមួយនឹងតំបន់នេះនៅមានកម្រិត ដោយគ្រាន់តែជាការបង្កើននូវសម្ព័នភាពយោធា

ទាំងឡាយ ដែលជាប្រពៃណីមានស្រាប់ និងក្នុងបញ្ហាសន្តិសុខមួយចំនួនដែលមានការទាក់ទិនផ្ទាល់ នឹងសហរដ្ឋអាមេរិក។ ទន្ទឹមនឹងនេះ រាល់ការខិតខំប្រឹងប្រែងក្នុងតំបន់សំដៅជំរុញឲ្យមានការកកើត ឡើងនូវ ទោះបីយន្តការពហុភាគីណាមួយអំពីសេដ្ឋកិច្ចឬសន្តិសុខ គឺសុទ្ធតែរងនូវការប្រឆាំងជំទាស់ពីអាមេរិកទាំងអស់នាពេលនោះ។ ដូចករណីអាមេរិក បានធ្វើការបដិសេធយ៉ាងខ្លាំងនូវគម្រោងការកកើត East Asian Caucus ដែលជាគំនិតផ្តួចផ្តើមរបស់នាយករដ្ឋមន្ត្រី ម៉ាឡេស៊ី Mahathir Mohammad នាឆ្នាំ ១៩៩១ ដែលគំនិតផ្តួចផ្តើមនេះគ្រាន់តែក្នុងគោលបំណងចង់បង្កើនទំនាក់ទំនង សហប្រតិបត្តិការសេដ្ឋកិច្ចនៅក្នុងតំបន់អាស៊ីប៉ូព៉ាតែប៉ុណ្ណោះ។

បន្ទាប់ពមកឆ្លងចូលអាណត្តិទី ២ របស់ប្រធានាធិបតី Bill Cliton ពេលនោះអាមេរិកក៏ចាប់ផ្តើមជំហានឯកភាព ក្នុងការទទួលស្គាល់នូវការបង្កើតឡើងនូវយន្តការសន្តិសុខពហុភាគីក្នុងក្របខណ្ឌនៅមានកំរិតដោយការឯកភាពនេះ មានបំណងចង់ឲ្យជួយចែងរំលែកនូវបន្ទុកដ៏ធ្ងន់របស់អាមេរិកតែប៉ុណ្ណោះ។ ពេលដែលមានទស្សនទានស្តីពី ASEAN Regional Forum ជាលើកដំបូងដែលបានស្នើឡើងវិញក្នុងបណ្តាឆ្នាំ ១៩៩២ ដល់ ១៩៩៤ ដែលវេទិកានេះ មានគោលដៅលើកកម្ពស់កិត្យានុភាពរបស់អាស៊ាន និងជាកម្លាំងតែមួយជាមួយចិនហើយសង្ឃឹមថានឹងអូសទាញចិនឲ្យចូលក្នុងទីលាននេះ ដើម្បីលើកឡើងសកម្មភាពរបស់ចិនក្នុងតំបន់ ត្រូវបានសហរដ្ឋអាមេរិកទទួលស្គាល់ជាខ្លាំង។ បញ្ហាសមុទ្រចិនខាងត្បូង បានវិលមកលងប្រទេសចិនគឺចាប់ពីមានការកកើតឡើងនូវវេទិកា ARF នេះមក។ ASEAN Regional Forum បានដើរតួនាទីយ៉ាងសំខាន់ក្នុងមុខងារជាវេទិកាសន្តិសុខសម្រាប់តំបន់ទាំងមូល ព្រមទាំងបានបំពេញភារកិច្ចជាអ្នកកសាងជំនឿទុកចិត្តគ្នាទៅវិញទៅមករវាងសមាជិកទាំង ២៧។ ក្នុងបរិបទនេះ ភាគីចិនទទួលបានជោគជ័យក្នុងការបញ្ចុះបញ្ចូលអូសទាញវេទិកា ARF នេះដើម្បីជួយលើកកម្ពស់តួនាទីរបស់ខ្លួននៅក្នុងតំបន់ដោយចិនមានយុទ្ធវិធីអាទិភាព គឺគាំទ្រនូវរាល់ទស្សនៈរបស់អាស៊ាន រួមមានបញ្ហាសន្តិសុខនៅក្នុងតំបន់ រួមទាំងវិបត្តិនៅលើ ឧបទ្វីបកូរ៉េទៀតផង។ ឥលូវនេះរាល់កិច្ចពិភាក្សាជាដៃគូរ សុទ្ធតែបានចូលរួមក្នុងសន្និសញ្ញា TAC ហើយតួនាទីរបស់អាស៊ាន ក្នុងបណ្តាបញ្ហាទាក់ទិនដល់សន្តិភាព និងសន្តិសុខក៏ត្រូវបានបង្កើន និងជំរុញយ៉ាងខ្លាំងក្លា។ មកដល់ដំណាក់កាលនេះ ចិនបានដឹងថាចរន្តនយោបាយនៅក្នុងតំបន់មានការវិត្តន៍ប្រែប្រួល ដូច្នេះប្រការមួយដ៏ល្អបំផុត គឺចិនត្រូវមានគោលនយោបាយថ្មីមួយដែលមានចរិត វាយប្រហារខ្ពស់ ដើម្បីអូសទាញ អាស៊ានឲ្យកាន់តែមានភាពខ្លាំងក្លាឡើង សំដៅធ្វើឲ្យភាគីទាំងពីរអាស៊ាន ចិន រួមមានប្រយោជន៍ទៅវិញទៅមក និងជឿទុកចិត្តគ្នា។

ចាប់ពីមានព្រឹត្តការណ៍អមិត្តនៅលើកោះ Mischief Reefs ក្នុងប្រជុំកោះ Spratlys នាឆ្នាំ ១៩៩៥ មក ដើម្បីផ្លាស់ប្តូរស្ថានភាពពីភាពមិនរាក់ទាក់ ជាមួយនឹងប្លុកអាស៊ានមកកាន់ស្ថានភាពដើមវិញចិនត្រូវប្រើរយៈពេល ១៥ ឆ្នាំ។ តែឥលូវនេះ បញ្ហាអធិករណ៍នៅតំបន់សមុទ្រចិនខាងត្បូង បានងាកមកលងពួកអ្នកនយោបាយចិនសារជាថ្មី ដោយទំនាស់វិវាទនេះមានលទ្ធភាពអាចប្រែក្លាយទៅជាបញ្ហាអន្តរត្តបនីយកម្មវិវាទលើសមុទ្រចិនខាងត្បូងនៅតែចំណុចក្រោយ និងរសើបរបស់ចិន ហើយក៏នៅតែជារបាំងរាំងមួយក្នុងដំណើរផ្លូវឆ្ពោះទៅរកការបង្កើនទំនាក់ទំនងល្អ រវាងអាស៊ានជាមួយនឹងចិន ចិន និងតំបន់ ផងដែរចិនជាមួយពិភពលោក។

មកដល់ពេលនេះ មុននឹងក្រោយពីមានកិច្ចប្រជុំរវាង អាស៊ាន-សហរដ្ឋអាមេរិកលើកទី ២មក អាមេរិកមានសេរីភាព ពេញលេញក្នុងការលើកឡើងនូវរាល់បញ្ហា ដែលមានទាក់ទិនទៅដល់បញ្ហារបស់អាស៊ាន។ ក៏ប៉ុន្តែការលើកឡើងទាំងអស់នេះរបស់អាមេរិកត្រូវមានភាពប្រសព្វនិងការថ្លឹងថ្លែងខ្ពស់ ព្រោះបើការលើកឡើងទាំងនេះមិនការវៃឈ្លាត និងបត់បែនទៅតាមស្ថានការរបស់អាមេរិកក្នុងបរិបទថ្មីនេះ អាចមានការប៉ះពាល់ ឬធ្វើឲ្យមានភាពទន់ខ្សោយនៅក្នុងទំនាក់ទំនងរវាងអាស៊ាន និងអាមេរិកទៅវិញ ត្រូវទទួលស្គាល់ការពិតមួយថា អាស៊ាននៅតែមានបំណងទទួចតាមទស្សនទានរបស់ខ្លួន ដែលចង់ឲ្យប្លុកអាស៊ានជាចំណុចផ្អែកឲ្យពួកមហាអំណាចមានសមតាជាមួយគ្នា ដើម្បីសុខសំបូររុងរឿងដល់អាស៊ាន។ ព្រោះនៅពេល ដែលអាមេរិកមានសំឡេងផ្តល់ការគាំទ្រដល់អាស៊ានមកលើបណ្តាបញ្ហានៅក្នុងតំបន់ គឺប្លុកអាស៊ាន បានស្វាគមន៍គាំទ្រដល់គំនិតនេះ។ ក៏ប៉ុន្តែក្នុងករណីដែលសភាពការណ៍វិវត្តន៍ទៅកាន់ភាពអវិជ្ជមាន ដែលហួសពីព្រំដែននៃក្របខ័ណ្ឌរបស់អាស៊ានវិញគឺប្រការនេះនឹងនាំឲ្យមានភាពធ្ងន់ធ្ងរក្នុងតុល្យភាពកម្លាំង ដែលពីដើមឡើយអាស៊ានមិនចង់បាននិងមិនចង់ឃើញទាល់តែសោះនោះ។

មានប្រទេសមួយចំនួននៅក្នុងតំបន់ ជាពិសេសគឺប្រទេសវៀតណាម ហ្វីលីពីន បានសំដែងការស្វាមន៍ចំពោះការវិលមកវត្តមានជាយោធារបស់អាមេរិកនៅក្នុងតំបន់នេះ ក្នុងពេលប្រទេសខ្លះពុំមានការទាក់ទិនណាមួយក្នុងអធិករណ៍នៅសមុទ្រចិនខាងត្បូងនោះហាក់បីដូចជាមានអារម្មណ៍មិនល្អនៅពេលដែលឃើញអាមេរិកបានចូលមកតំបន់នេះ ប្រទេសដែលមានអារម្មណ៍មិនរីករាយ គេអាចឃើញមានប្រទេសថៃ កម្ពុជា និងសិង្ហបុរី ព្រោះប្រទេសទាំងនេះមានការបារម្ភដោយមិនចង់ឃើញមានវិវាទណាមួយកើតឡើងរវាងអាមេរិកនិងចិន ដែលហេតុការណ៍ពេលនោះ នឹងបង្ខំឲ្យពួកគេត្រូវធ្វើការជ្រើសរើសផ្លូវណាដែលពួកគេត្រូវដើរតាមចិន ឬតាមអាមេរិក ដែលជាសភាពការណ៍អាយៈតនៈភាពមួយនៅក្នុងជម្រើសជាតិ។ តែជារួមពួកប្រទេសអាស៊ីអាគ្នេយ៍ទាំងអស់ពុំមាន

ប្រទេសណាមួយចង់ឃើញ ចិន-ជប៉ុន ចិន-អាមេរិក មានការប៉ះទង្គិចគ្នា ដែលជាការជះឥទ្ធិពលមួយដ៏អាក្រក់ ដល់ដំណើរវិវត្តន៍រីកចម្រើននៅក្នុងតំបន់ទាំងមូលសោះឡើយ។

## កថាខណ្ឌទី ២៖ យន្តការដោះស្រាយនិងពិភាក្សានៅក្នុងអង្គការសហប្រជាជាតិ

ជម្លោះសមុទ្រចិនខាងត្បូងត្រូវបានគេចាត់ទុកថាជាជម្លោះអន្តរជាតិមួយ ដែលមានភាគីជាសមាជិករបស់អង្គការសហប្រជាជាតិជាច្រើនពាក់ពន្ធ័ ហើយក៏ជាសមាជិកអង្គការក្នុងតំបន់ហៅកាត់ថាអាស៊ានផងដែរ។ ក្នុងតំណែងជាអគ្គលេខាធិការអង្គការសហប្រជាជាតិលោក Ban Ki-moon បានជំរុញឲ្យភាគីដែលពាក់ពន្ធ័ទាំងអស់ដោះស្រាយជម្លោះតាមរយៈការពិភាក្សា និងច្បាប់អន្តរជាតិរួមបញ្ចូលទាំងធម្មនុញ្ញអង្គការសហប្រជាជាតិ។ ទាក់ទងទៅនឹងការកើនឡើងនៃភាពតានតឹងនៅក្នុងសមុទ្រចិនខាងត្បូង នៅពេលដែលចិនបានធ្វើសមយុទ្ធយោធានៅក្នុងសេដ្ឋកិច្ចផ្តាច់មុខរបស់វៀតណាម។ លោក Ban Ki-moon បានជំរុញឲ្យរដ្ឋពាក់ពន្ធ័ដោះស្រាយជម្លោះនៅក្នុងសមុទ្រចិនខាងត្បូងដោយសន្តិភាព។ អគ្គលេខាធិការអង្គការសហប្រជាជាតិបានសម្តែងការព្រួយបារម្ភអំពីការកើនឡើងអំពីភាតានតឹងនៅក្នុងសមុទ្រចិនខាងត្បូង ជាពិសេសរវាងប្រទេសវៀតណាម និងចិននាពេលថ្មីៗនេះ។ ក្នុងស្ថានភាពកំពុងតែតានតឹងសមាជិកព្រឹទ្ធសភាអាមេរិកមានការព្រួយបារម្ភជាខ្លាំង ហើយបានជំរុញឲ្យសភាអាមេរិកអនុម័តស្វែងរកដំណោះស្រាយ ដើម្បីគាំទ្រចិនក្នុងការផ្តល់សេរីភាពនាវាចរនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ក៏ដូចជាការដោះស្រាយតាមផ្លូវការទូតនៅក្នុងជម្លោះដែនសមុទ្រនេះជាជាងកម្លាំងប្រដាប់អាវុធ។ ក្នុងអាណត្តិរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក Ban Ki-Moon តែងតែផ្តល់អនុសាសន៍ជាញឹកញយទៅបញ្ហានេះ ដើម្បីឲ្យរដ្ឋទាំងអស់មានឆន្ទៈដោះស្រាយដោយសន្តិវិធី។

## កថាខណ្ឌទី ៣៖ ការប្រមើលមើលឧបសគ្គ និងដំណោះស្រាយជម្លោះនៅសមុទ្រចិនខាងត្បូង

### ១. គំនិតផ្តួចផ្តើមប្រាំមួយយ៉ាងទាក់ទងដល់ការសម្របសម្រួល បន្ធូរ បន្ថយ នូវភាពតានតឹងលើសមុទ្រចិនខាងត្បូង

លោក Emest Bower នាយកកម្មវិធីអាស៊ីអាគ្នេយ៍របស់មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវបញ្ហាអន្តរជាតិរបស់អាមេរិក បានធ្វើសេចក្តីថ្លែងការណ៍នាសិក្ខាសិលាស្តីពី សន្តិសុខនាវាចរណ៍លើសមុទ្រចិនខាងត្បូងនៅអាមេរិក បានលើកឡើងនូវសំណើរប្រាំមួយយ៉ាងសំដៅបង្កើនសន្តិសុខសមុទ្រចិនខាងត្បូង ទាក់ទងដល់បញ្ហាសំខាន់នេះ លោក Emest Bower បានធ្វើសេចក្តីសន្និដ្ឋាន

ដោយសង្កត់ថា ស្ថានភាពសមុទ្រចិនខាងត្បូងនាពេលថ្មីៗនេះ មានសភាពតានតឹងគួរឲ្យបារម្ភ ដោយពុំឃើញមានភាគី ណាមួយមានជំហរសម្របសម្រួលបន្ទន់ឥរិយាបថសោះ។ ហើយដើម្បីជាការបន្ធូរបន្ថយនៅសភាពការណ៍ទាំងនេះ លោក Emest Bower បានអះអាងថា អាស៊ានត្រូវបំពេញកាតព្វកិច្ចដោយត្រូវធ្វើខ្លួនទៅជាជាតិការមួយសម្រាប់ផ្សារភ្ជាប់រដ្ឋទាំងអស់ជាមួយគ្នា ដោយឆ្លងកាត់តាមរយៈចរិកលក្ខណៈរបស់ប្រទេសជាសមាជិកអាស៊ាន ឬមួយក៏ឆ្លងតាមរយៈរចនាសម្ព័ន្ធក្នុងតំបន់ដូចជាអាស៊ាន+១(អាស៊ាននិងចិន) អាស៊ាន+៣ (អាស៊ាន និងប្រទេសអាស៊ីខាងកើតរួមមាន ជប៉ុន កូរ៉េខាងត្បូង និងចិន) វេទិកាតំបន់អាស៊ាន ARF សន្និសីទរដ្ឋមន្ត្រីការពារជាតិអាស៊ានបើកទូលាយ ADMM+ កិច្ចប្រជុំកំពូល EAS និងវេទិកា APEC ជាដើម។ក្រៅអំពីរចនាសម្ព័ន្ធក្នុងតំបន់នេះដើម្បីបំពេញមុខងារសម្របសម្រួលសភាពការណ៍ លើតំបន់សមុទ្រចិនខាងត្បូងកុំឲ្យមានសភាពតានតឹង និងការប្រឈមមុខដាក់គ្នាយ៉ាងនេះ លោក Emest Bower ក៏បានលើកឡើងនូវសំណើរ ០៦យ៉ាង ទាក់ទងដល់សភាពការណ៍នេះរួមមានៈ

**១. បង្កើនលទ្ធភាពព្យាករណ៍សភាពការណ៍ និងបង្កើនចរិកតម្លាភាពឲ្យកាន់តែច្បាស់លាស់ថែមទៀតៈ** ទំនាស់វិវាទ និងការប្រឈមមុខដាក់គ្នា ផ្តើមចេញពីប្រទេសទាំងអស់មិនយល់អស់ពីសំណូរពរ និងគោលបំណងរបស់គ្នាទៅវិញទៅមក។ ដូច្នេះអាស៊ានអាចបំពេញមុខងារជាអ្នកស្ថាបនា និងនូវការជឿទុកចិត្តគ្នា ដោយការធ្វើការនេះ តាមរយៈ ARF និង EAS ដើម្បីជំរុញលើកទឹកចិត្តដល់បណ្តាលប្រទេសអាស៊ាន ទាំងអស់ឲ្យចូលរួមចំណែកចែករំលែក និងពិភាក្សាអំពីយុត្តិសាស្ត្រសន្តិសុខ និងការពារជាតិជាមួយគ្នា។

**២. វិនិយោគទុនជាគំនិតមកលើការងារការទូតៈ** ពួកប្រទេសអាស៊ានគួរលើកទឹកចិត្តនិងយកចិត្តទុកដាក់មកលើការបណ្តាក់ទុនជាគំនិត ក្នុងការផ្លាស់ប្តូរប្រែប្រួលនូវរូបភាពពិភាក្សាដែលមានការទាក់ទងពាក់ព័ន្ធទៅនឹងស្ថេរភាពរបស់តំបន់សមុទ្រចិនខាងត្បូង ក៏ដូចជាការស្វែងរកនូវគ្រប់មធ្យោបាយសំដៅជំរុញ និងការបង្កើននូវកិច្ចពិភាក្សាទាំងឡាយដែលមានចរិកផ្តល់ការគាំទ្រ លើកទឹកចិត្តដល់កិច្ចការចចារទាំងឡាយនាបណ្តាវេទិកាស្តីពីនាវាចរណ៍ដូចជា ARF ADMM+ និងEAS ជាដើម។

**៣. បង្កើនថាមពលដល់បណ្តាស្ថាប័នរបស់អាស៊ានៈ** ការកើតវិវាទលើតំបន់សមុទ្រចិនខាងត្បូង ក៏ដូចជាអធិករណ៍ទាំងឡាយរួមទាំងដំណើរនៃល្បឿនសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងតំបន់បានឈានដល់ដំណាក់កាលមួយដែលឃើញថា ចាំបាច់ត្រូវពង្រឹងដល់បណ្តាស្ថាប័នរបស់អាស៊ាន

ទាំងនេះ ហើយក៏ដើម្បីបង្កើន និងជំរុញសន្តិសុខ និងល្បឿនសេដ្ឋកិច្ចឲ្យកាន់តែមានចង្វាក់វិវត្តន៍រីកចម្រើនល្អឡើងៗ។

**៤. សន្យាចូលរួមការចចារ និងការងារការទូត:** អាស៊ានត្រូវតែសន្យានាំមកដល់វេទិកាទាំងឡាយដូចជា ARF ADMM+ និងEAS នូវការងារប្រាកដនិយមទាំងនេះរួមទាំងការងារខ្លះ ដែលមើលទៅឃើញថាមានចរិករសើបនេះ។ ត្រៀមជាគំនិត ទិសដៅរួមទាំងដំណោះស្រាយជូនដល់គ្រប់ថ្នាក់ដឹកនាំ នៅពេលដែលចូលរួមកិច្ចប្រជុំកំពូល EAS ហើយបើកកិច្ចប្រជុំនីមួយៗនេះ តែងតែនាំគ្នាគេចវេចបញ្ហាមិនចង់ដោះស្រាយបញ្ហាគឺសភាពការណ៍ទាំងនេះកាន់តែមានភាពធ្ងន់ធ្ងរកាន់តែហានិភ័យប្រឈមមុខដាក់គ្នារួមទាំងការប្រទូស្តរាយដោយរបៀបណាមួយនោះ កាន់តែតានតឹងឡើងៗដោយការមិនយល់គ្នា។

**៥. ម្ចាស់ការក្នុងការងារការទូត:** អាស៊ានចាំបាច់ត្រូវតែដើរតួរនាទីយ៉ាងសំខាន់ជាងនេះក្នុងការលើកទឹកចិត្តដល់បណ្តាប្រទេសជាសមាជិកក៏ដូចជាប្រទេសដៃគូផ្សេងទៀតក្នុងការដោះស្រាយបញ្ហាវិវាទទាំងនេះដោយឆ្លងតាមរយៈយន្តការច្បាប់ និងពហុភាគី ដូចករណីអនុវត្តន៍តាមអនុសញ្ញាអន្តរជាតិស្តីពីច្បាប់សមុទ្ររបស់អង្គការសហប្រជាជាតិ ឬតុលាការយុត្តិធម៌អន្តរជាតិ ឬយន្តការយុត្តាធិការអន្តរជាតិផ្សេងទៀត។

**៦. សមាហរណកម្មសេដ្ឋកិច្ច:** អាស៊ានចាំបាច់ត្រូវសកម្មជាងនេះក្នុងការពង្រីកនូវទំនាក់ទំនងការផ្សារភ្ជាប់គ្នាលើវិនិយោគទុន និងការធ្វើពាណិជ្ជកម្មដោយរបៀបបង្កើនភាពសុខដុម និងការកំណត់ស្តង់ដារលើបណ្តាគោលការណ៍បណ្តាក់ទុន អនុវត្តន៍នូវវិធានការទាំងឡាយដែលមានចរិតជារូបភាពអភិវឌ្ឍន៍រួម ដែលការងារនេះទាមទារមានការពិគ្រោះជាមួយនឹងបណ្តាផ្នែកវិស័យឯកជន។ របៀបធ្វើនេះនឹងនាំមកនូវសុវត្ថិភាព និងការអភិវឌ្ឍន៍ដោយចីរភាព មកលើធនធានធម្មជាតិ ដែលមាននៅក្នុងសមុទ្រចិនខាងត្បូង ដែលជាប្រការមួយដ៏ល្អបំផុតក្នុងការចែករំលែក នាំមកនូវអត្ថប្រយោជន៍ដល់គ្រប់រដ្ឋ ដែលមានការពាក់ព័ន្ធទាំងអស់។

## ២. ប្រការសំខាន់ ៧ ចំណុចពាក់ពន្ធ័បញ្ហាគន្លឹះមិនអាចដំណោះស្រាយសមុទ្រចិនខាងត្បូង

ការដំណោះស្រាយបញ្ហា ជម្លោះសមុទ្រចិនខាងត្បូង ត្រូវគេទទួលស្គាល់ថាវាមិនមែនជារឿងងាយស្រួលនោះទេដើម្បីរកកិច្ចព្រមព្រៀងមួយពីគ្រប់ភាគីទាំងនោះ ដោយជៀសវាងពីការគិតតែប្រយោជន៍ផ្ទាល់ខ្លួន (Self-Interest)។ ពេលខ្លះគេឃើញថា វាមិនត្រូវបានកាត់បន្ថយនូវភាពស្មុគស្មាញនោះទេ ផ្ទុយទៅវិញវាបែរជាកាន់តែតឹងតែង ជាងមុនដោយហេតុផលមួយចំនួនដ៏ស្មុគ ស្មាញ។

[32]យោងទៅតាមលោកសាស្ត្រាចារ្យ Carl Thayer នៃវិទ្យាស្ថានការពារជាតិអូស្ត្រាលីបានលើកបញ្ហា ៧ចំណុចដែលនៅសេសសល់ក្នុងទំនាក់ទំនងសមុទ្រចិនខាងត្បូងសំរាប់ប្រទេសពាក់ ពន្ធ័ទាំងអស់។

១.នៅពុំទាន់មានទស្សនវិស័យណាមួយក្នុងការដោះស្រាយ មកលើទំនាស់វិវាទដំរសើប ចំពោះអធិបតេយ្យភាព និងអំណាចអធិបតេយ្យភាពលើផ្លូវច្បាប់អំពីកោះ និងតំបន់សមុទ្រទាំងឡាយលើសមុទ្រចិនខាងត្បូង ដែលក្នុងនោះមានប្រជុំកោះជាច្រើន ហើយពេលនោះប្រទេសវៀតណាម ហ្វីលីពីន និងចិន នឹងអាចទទួលជោគជ័យដោយអនុលោមទៅតាមការអះអាងរបស់ខ្លួន ដែលភាគីទាំងអស់នោះនឹងបន្តប្រឆាំងជំទាស់ ទោះបីសកម្មភាពណាមួយពីភាគីម្ខាងទៀតដោយចាត់ទុកថាអំពើនោះបានរំលោភបំពានមកលើ ដែនអធិបតេយ្យភាពរបស់ខ្លួន។

២.លទ្ធិជាតិនិយមនៅតែកំលាំងចិនមួយយ៉ាងខ្លាំងខ្លាដែលបានជិតជាប់ស្មារតីរបស់ជនជាតិនៃភាគីទាំងនោះ ដែលប្រការនេះជាបញ្ហាដ៏ស្មុគស្មាញបំផុតក្នុងការជម្រុញស្វែងរកឲ្យមានដំណោះស្រាយសំរាប់បញ្ហាដ៏រសើបនេះ។

៣.ពួកប្រទេសដែលមានការពាក់ពន្ធ័នៅលើសមុទ្រចិនខាងត្បូងសុទ្ធតែខិតខំក្នុងការជម្រុញផែនការសហាប្រតិបត្តិការជាមួយបណ្តាសហាក្រុមហ៊ុនបរទេស រួមទាំងការអំពាវនាវអូសទាញឲ្យក្រុមហ៊ុនទាំងនោះ ចូលមកធ្វើការរុករក និងធ្វើអាជីវកម្មប្រេងក្នុងតំបន់សមុទ្រ ដែលមានទំនាស់វិវាទមិនទាន់បានដោះស្រាយនៅឡើយ។

៤.នៅពេលដែល ប្រភពត្រីក្នុងតំបន់សមុទ្រចិន ក៏ដូចជានៅតំបន់ជុំវិញ និងជិតកោះ Hainam បានរីងស្ងួត ដែលមិនអាចនេសាទបានទៀតឡើយ ជាហេតុនាំឲ្យអ្នកនេសាទជនជាតិចិនទាំងនោះធ្វើដំណើរមកភាគខាងត្បូង ដែលសកម្មភាពនេសាទទាំងនេះត្រូវបានលើកទឹកចិត្តដោយអាជ្ញាធរចិនបានចាត់បញ្ជូន និងពង្រាយនៅកងនាវាល្បាតជាច្រើនគ្រឿងចុះមកតំបន់ខាងក្រោមសំដៅលើការការពារកប៉ាល់នេសាទរបស់ពលរដ្ឋចិនឲ្យបាន។

៥.ចិនកាន់តែមុះមត់ មានសកម្មភាពជាអន្តោម័ត ព្រមទាំងមានការប្រតិកម្ម និងថ្កោលទោសចំពោះរាល់សកម្មភាពណាដែលកើតមានឡើងនៅលើសមុទ្រចិនខាងត្បូង ដែលទោះបីជាសកម្មភាពនោះមានចរិតលក្ខណៈជាស៊ីវិលក៏ដោយ។ ចិនបន្តរក្សាជំហររឹងរូស ដោយបដិសេធរាល់ការចោទប្រកាន់ណាមួយពីពួកប្រទេសដែលពាក់ពន្ធ័មកលើខ្លួន សុទ្ធតែខុសទាំងអស់ ឬមួយចាត់ទុកសកម្មភាពរបស់ចិនលើសមុទ្រចិនខាងត្បូងគឺជាសកម្មភាពស្របច្បាប់ជាធម្មតារបស់ចិន។

[32] ដកស្រង់ចេញពីសៀវភៅសមុទ្រចិនខាងត្បូងក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ ទំព័រទី ៥១៧ និពន្ធដោយ ហើស សិរីធន បោះពុម្ពផ្សាយខែឧសភា ឆ្នាំ ២០១៣

**៦.**ពួកប្រទេសដែលពាក់ពន្ធ័សុទ្ធតែបានបន្ត និងពង្រឹងនូវសកម្មភាពអនុម័តច្បាប់ដែលមានលក្ខណៈចាប់បង្ខំចំពោះនាវាចរណ៍ ហើយសំខាន់ជាងនេះ គឺពួកប្រទេសដែលទាមទារ បានជំរុញការងារទំនើបកម្មទាំងកងទ័ពជើងគោក និងជើងអាកាសសំដៅប្តេជ្ញាការពារផលប្រយោជន៍ លើសមុទ្រចិនខាងត្បូងឲ្យបាន។

**៧.**អាស៊ាននៅមិនមានការឯកភាពលើរបៀបអនុម័តជាមួយចិនក្នុងបញ្ហាវិវាទលើសមុទ្រចិនខាងត្បូង ដែលនេះពុំមែនជាទស្សនវិស័យមួយដ៏ល្អសំរាប់ការឆ្ពោះទៅអនុម័តក្រមប្រតិបត្តិមួយដែលមានចរិតជាច្បាប់ដែលអាចបញ្ជាក់នូវរបៀបការពាររបស់ប្រទេសនីមួយៗ ដើម្បីសន្តិភាព និងស្ថេរភាពលើសមុទ្រចិនខាងត្បូងឡើយ។

ទិន្នាការធំខាងលើនេះ សុទ្ធតែជាប្រការដែលធ្វើឲ្យមានការបារម្ភទាំងនោះ ហើយតំបន់សមុទ្រអាស៊ីអាគ្នេយ៍នៅតែមានភាពចំរូងចម្រើសរហូតដែលមួយថ្ងៃ កាន់តែក្តៅឡើយ ហើយមួយថ្ងៃកាន់តែជ្រៅឡើងដែលងាយស្រួលបំផុតក្នុងការនាំឲ្យមានការប្រទូស្តរាយដោយកំលាំងប្រដាប់អាវុធនោះ។

## ៣. ដំណោះស្រាយសន្តិភាពក្នុងជម្លោះសមុទ្រចិនខាងត្បូង

បញ្ហាដែលកើតឡើងមាននៅសមុទ្រចិនខាងត្បូងនេះ មិនត្រូវដោះស្រាយតាមបែបហឹង្សាដោយការផ្ទុះអាវុធ ឬការប៉ះទង្គិចគ្នានោះទេ ពីព្រោះថាប្រទេសដែលជាសមាជិកនៃជម្លោះនោះមានសមត្ថភាពផ្នែកយោធាមិនដូចគ្នា ហើយប្រសិនបើបណ្តោយឲ្យកើតមានការប្រយុទ្ធគ្នាបែបនេះ វាមិនបានផ្តល់ផលប្រយោជន៍ដល់ភាគីណាមួយនោះដែរ ព្រោះថាវាប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់ និងការរៀបចំផែនការនយោបាយរបស់ប្រទេសនីមួយៗនោះ។ ដូចនេះ នៅក្នុងការដោះស្រាយជម្លោះដែលកើតមាននៅក្នុងសមុទ្រចិនខាងត្បូងនេះ យើងយល់ឃើញថាការដោះស្រាយជម្លោះនោះគួរតែធ្វើដោយសន្តិវិធីពោលគឺ គួរតែដោះស្រាយបញ្ហាដោយអនុលោមតាមវិធីសាស្រ្ត ដែលបានផ្តល់ដោយអនុសញ្ញា ១៩៨២ស្តីពីនីតិសមុទ្រ ក៏ដូចជាការអនុវត្តន៍នានាដែលប្រទេសនៅលើពិភពលោកបានប្រើប្រាស់រួមមកហើយ ដែលវិធីក្នុងការដោះស្រាយដោយសមស្របចំពោះជម្លោះមានដូចខាងក្រោម៖

- ការដោះស្រាយតាមរយៈការចូលរួមពីសំណាក់ភាគីទី ៣ ដើម្បីជួយផ្សះផ្សាដែលនៅក្នុងនោះជម្លោះគួរតែប្រគល់ឲ្យបុគ្គល ឬប្រទេសទី ៣ដែលជាប្រទេសមួយអព្យាក្រឹត្យក្នុងការដោះស្រាយ។ ប្រទេសដែលគួរចូលខ្លួនរួមចំណែកអាចជាប្រទេស សិង្ហបុរីដែលល្បីល្បាញខាងការដោះស្រាយជម្លោះក្រៅប្រពន្ធ័តុលាការ និងការផ្សះផ្សា ហើយមិនតែប៉ុណ្ណោះ

ប្រទេសនេះក៏ជាប្រទេសមួយដែលស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ហើយមានការយល់ដឹងច្រើនពីស្ថានភាពក្នុងតំបន់។ ក្រៅពីសិង្ហបុរី សហរដ្ឋអាមេរិកដែលមហាសេដ្ឋកិច្ចនឹងយោធាក៏គួរតែធ្វើខ្លួនជាអាជ្ញាធរក្នុងការដោះស្រាយជម្លោះនេះ។ ប៉ុន្តែនេះនឹងកើតមានឡើងប្រសិនបើអាមេរិកលូកដៃចូលមកដោះស្រាយនោះ ពីព្រោះសហរដ្ឋអាមេរិកជាសម្ពន្ធ័មិត្រជាមួយប្រទេសងហ្វីលីពីន ម្យ៉ាងវិញទៀតសហរដ្ឋអាមេរិកក៏ដូចជាមានទំនោរជួយប្រទេសវៀតណាមផងដែរ បើទោះបីជាធ្លាប់មានការល្អក់កករជាមួយគ្នា អស់ជាច្រើនឆ្នាំកន្លងមកហើយ។

- ការដោយស្រាយវិវាទតាមរយះតុលាការយុត្តិធម៌អន្តរជាតិ ដែលផ្តល់សិទ្ធិឲ្យតុលាការក្នុងការកាត់ក្តី ទៅលើបញ្ហាអធិបតេយ្យភាពរបស់រដ្ឋ នៅលើតំបន់ជម្លោះនោះ។ [33]ការដោះស្រាយបែបនេះគឺមានការអនុវត្តន៍រួចមកហើយដោយប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ព្រមទាំងសិង្ហបុរី ក្នុងជម្លោះព្រហ្មដែនសមុទ្ររបស់ខ្លួន។
- [34]ការដោះស្រាយដោយឲ្យប្រទេសទាំងអស់ព្រមព្រៀងគ្នា ក្នុងការចូលរួមអភិវឌ្ឍន៍តំបន់សមុទ្រចិនខាងត្បូងដោយមិនគិតពីបញ្ហាអធិបតេយ្យភាពរបស់ខ្លួន វិធីនេះត្រូវបានលោកនាយករដ្ឋមន្ត្រីក្រសួងការបរទេសអូស្រ្តាលីជឿជាក់ថា ជាវិធីមួយដែលមានប្រសិទ្ធភាពក្នុងការធ្វើឲ្យមានការធូរស្រាលក្នុងជម្លោះ។ [35]មិនតែប៉ុណ្ណោះ វិធីសាស្ត្របែបនេះត្រូវបានអនុវត្តដោយប្រទេសមួយចំនួនលើពិភពលោករួចទៅហើយដូចជា ប្រទេសចិន និងវៀតណាមក្នុងកិច្ចព្រមព្រៀងរួមគ្នាគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាននៅក្នុងឈូងសមុទ្រតុងកឹង និង[36]កិច្ចព្រមព្រៀងធ្វើការអភិវឌ្ឍន៍រួមនៅក្នុងឈូងសមុទ្រថៃ រវាងប្រទេសថៃ និងម៉ាឡេស៊ីនៅឆ្នាំ១៩៧៩។

ប្រទេសដែលជាប់ទាក់ទងនឹងជម្លោះទាំងអស់គួរតែប្រកាន់ខ្ជាប់នៅគោលការណ៍រួមមួយជាមុនសិនគឺការថែរក្សាការពារសុវត្ថិភាព និងសន្តិសុខ ស្ថេរភាពក្នុងតំបន់ព្រមទាំងថែរក្សា និងអភិរក្សធនធានធម្មជាតិក្នុងតំបន់ជម្លោះ បន្ទាប់ពីមានជម្លោះកើតឡើង ប្រទេសទាំងអស់គឺផ្តោតចំណាប់

[33] Resenberg, David. "The Paradox of the South China Sea Dispute." *The China Story*, 2013: 04.

[34] Loosley, Stephen. "South China Sea Dispute a Long Time Coming, but Solutions are in Hand." *The Australian*, 2013: 02.

[35] Resenberg, David. "The Paradox of the South China Sea Dispute." *The China Story*, 2013: 05.

[36] Ozdalga, Damla. "Managing Peace, Security and Prosperity in the South China Sea ." 2011: 06.

អារម្មណ៍ជាខ្លាំងទៅដល់ការទាមទារអធិបតេយ្យភាពរបស់ខ្លួនជាជាងការការពារតំបន់។ ដូច្នេះរដ្ឋទាំងអស់គួរតែទុកផលប្រយោជន៍សេដ្ឋកិច្ចរបស់ខ្លួនទៅម្ខាង ហើយផ្តោតការចាប់អារម្មណ៍ទៅលើបញ្ហា នេសាទហួសព្រំដែន សេដ្ឋកិច្ច និងការរស់នៅរបស់ប្រជាជនដែលប៉ះពាល់ទៅដល់បញ្ហាជម្លោះ ជាធំទើបល្អប្រសើរ និងធ្វើយ៉ាងណាថែរក្សាការពារតំបន់នោះក្នុងអំឡុងពេល ដំណើរការដោះស្រាយជម្លោះនោះ ព្រោះថាបើទោះបីជាការសម្រេចសេចក្តីថាតំបន់នោះជារបស់ប្រទេសណាមួយក៏ដោយក៏តំបន់នោះនៅតែផ្តល់ផលប្រយោជន៍ដល់ខ្លួនដដែល។

ភាពបរាជ័យរបស់សេចក្តីប្រកាសក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង (DOC) ក្នុងការរារាំងទប់ស្កាត់នូវភាពតានតឹងរវាង អាស៊ាន និងចិននៅលើតំបន់សមុទ្រចិនខាងត្បូងមិនបានសម្រេចកាន់តែធ្វើឲ្យឃើញនូវភាពចាំចាច់មួយរបស់អាស៊ាន ក្នុងការប្តេជ្ញាខ្ពស់ជាងនេះទៅទៀតក្នុងការប្រតិកម្មទៅនឹងអ្វីដែលបានកើតឡើង នៅលើសមុទ្រខាងត្បូងនេះ។ តែទោះបីជាស្ថិតនៅក្នុងកាលៈទេសៈណាមួយក៏ដោយក៏អាស៊ានមិនត្រូវបោះបង់ចោលនូវទំនាក់ទំនងដ៏ប្រពៃថ្លៃថ្លាមានស្រាប់ជាមួយចិនដែរ ប៉ុន្តែប្លុកអាស៊ានទាំងមូលក៏ត្រូវប្តេជ្ញាដាច់ខាតជាមួយចិនក្នុងបញ្ហាទាំងឡាយដែលពាក់ពន្ធ័ទៅនឹងវិវាទ និងអធិបតេយ្យភាពលើសមុទ្រចិនខាងត្បូងដែរ។ ហើយដើម្បីជំរុញទំនាក់ទំនងពាណិជ្ជកម្មក្នុង តំបន់សមុទ្រនេះ រដ្ឋទាំងអស់គួរមានសកម្មភាពដូចខាងក្រោម៖

- រួមគ្នាបង្កើតក្រុមប្រឹក្សាសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មសមុទ្រចិនខាងត្បូងមួយសំដៅជំរុញកិច្ចសហប្រតិបត្តិការនេះឲ្យកាន់តែខ្លាំងខ្លាក្នុងតំបន់។
- អភិវឌ្ឍន៍នូវបណ្តាយុទ្ធសាស្ត្ររួមដើម្បីបង្កើតលទ្ធភាព និងចរិតប្រកួតប្រជែងក្នុងតំបន់ដូចជាស្ពាន កំពង់ផែ កសាងនិងជុសជុលនាវា សំដៅបម្រើឲ្យពាណិជ្ជកម្មឆ្លើយតបទៅនឹងសំណូមពរសេវាកម្មផ្សេងៗទៀត ទាក់ទងដល់ពាណិជ្ជកម្មតាមសមុទ្រជាបង្គោលរឹងមាំនៅចំពោះមុខការប្រកួតប្រជែងគ្នាយ៉ាងផុសផុល ជាមួយនឹងតំបន់សេដ្ឋកិច្ចផ្សេងទៀតក្រៅពីតំបន់នេះ។
- ចែករំលែកដោយផ្តល់ជូនគ្នាទៅវិញទៅមកនៅការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធក្នុងការដឹកជញ្ជូនប្រកបដោយសុវត្ថិភាពព្រមទាំងផ្តល់ការធានាដល់នាវាទាំងអស់អាចធ្វើដំណើរទៅមកនៅលើតំបន់សមុទ្រនេះមានសុវត្ថិភាពបំផុត។
- ដាក់ចេញនូវវិធានការប្រឆាំងទៅនឹងការបំពុលបរិស្ថាន និងគ្រោះថ្នាក់គំរាមគំហែងដល់តំបន់សមុទ្រ។

- អនុវត្តនូវការស្រាវជ្រាវរុករករួមគ្នាផ្អែកតាមវិទ្យាសាស្ត្រនូវក្នុងតំបន់ដែលមានប្រយោជន៍រួម ជាពិសេសតំបន់ដែលសម្បូរទៅដោយធនធានធម្មជាតិ និងរុក្ខសាគរជីវចម្រុះ។
- អនុវត្តការរុករករួម ដើម្បីស្វែករកធនធានធម្មជាតិប្រេងឧស្ម័ន និងបង្កើតអាជ្ញាធរអភិវឌ្ឍន៍រួមមួយនៅតំបន់ដែលមានវិវាទ ដែលសម្បូរទៅដោយធនធានថាមពល ដើម្បីជាតំបន់ពាណិជ្ជកម្មឆ្លងតាមតាមរយៈការព្រមព្រៀងគ្នាដោយស្មើភាព សមហេតុផល និងយុត្តិធម៌។
- ឆ្ពោះទៅការព្រមព្រៀង ដើម្បីរួមគ្នាគ្រប់គ្រងមកលើប្រភពធនធានជលផល ដូចដែលចិន និងជប៉ុនធ្លាប់បានរួមគ្នាអនុវត្តន៍ ព្រមទាំងធានាថា តំបន់សមុទ្រដែលត្រូវបានធ្វើអាជីវកម្មត្រូវប្រកបដោយនិរន្តភាព និងសុខមាលភាពនៃបរិស្ថាន។
- គោរពនូវរាល់គោលការណ៍នីតិអន្តរជាតិ និងសន្ធិសញ្ញាអន្តរជាតិ ក៏ដូចជាគោលការណ៍ការទូតសំដៅចៀសមិនឲ្យមានការទំនាស់ប្រទូស្តរាយ និងស្វែងរកនូវដំណោះស្រាយដោយសន្តិវិធីសម្រាប់អធិករណ៍នេះ។
- ធ្វើការតាមរបៀបឧបតោភាគី ឬពហុភាគីក្នុងការរួមគ្នាយាមល្បាតលើតំបន់សមុទ្រសំដៅរារាំងទប់ស្កាត់ចោរសមុទ្រ ការរត់ពន្ធ និងអំពើភេរវកម្ម។
- ជំរុញការធ្វើអេកូទេសចរណ៍ និងគមនាគមន៍នាវាចរណ៍ នៅក្នុងតំបន់ដែលមានភាពសមស្រប។

# សេចក្តីសន្និដ្ឋាន

តាមរយៈការស្រាវជ្រាវលើប្រធានបទស្តីពី ជម្លោះសមុទ្រចិនខាងត្បូងនៅក្នុងទំនាក់ទំនងអន្តរជាតិ នេះមក យើងខ្ញុំយល់ឃើញថាជម្លោះអន្តរជាតិគឺជាជម្លោះមួយដែលមានភាពស្មុគស្មាញជាទីបំផុត ពីព្រោះចាំចាច់ជាខ្លាំងផ្អែកទៅលើឆន្ទះរបស់រដ្ឋនីមួយៗ ជាជាងគោលគ្រឹះរបស់ច្បាប់អន្តរជាតិ។ ជាក់ស្តែង នៅក្នុងខ្លឹមសារខាងលើយើងមានអនុសញ្ញាស្តីពីច្បាប់សមុទ្រ ប៉ុន្តែវាមិនមានលក្ខណៈចាប់បង្ខំដើម្បីឲ្យរដ្ឋនីមួយៗត្រូវតែអនុវត្តតាមជាដាច់ខាតនោះទេ។ ជាទូទៅ នៅក្នុងបណ្តារដ្ឋជម្លោះ នៅក្នុងសមុទ្រចិនខាងត្បូងទាំងអស់ សុទ្ធតែសំឡឹងឃើញផលប្រយោជន៍រៀងៗខ្លួននៅក្នុងការដណ្តើមដើម្បីទាញយកសម្បត្តិធនធានធម្មជាតិដូចជាប្រេង ឧស្ម័ន ការនេសាទត្រី និងការកាន់កាប់ ដើម្បីជាម្ចាស់នៅក្នុងសេដ្ឋកិច្ចផ្តាច់មុខ។ ជាការពិតណាស់ ទាំងអស់នេះហើយជារឿងដល់លំបាកបំផុតដើម្បីឲ្យរដ្ឋនីមួយៗបន្ទន់ឥរិយាបថ ដើម្បីចែករំលែកផលប្រយោជន៍ទាំងអស់នេះទៅទៀត រដ្ឋដដៃទៀត ជាពិសេសសាធារណៈរដ្ឋប្រជាមានិតចិន។ តាមរយៈការអង្កេតជាលក្ខណៈអន្តរជាតិ គេឃើញយ៉ាងច្បាស់ថា ប្រទេសចិនមិនបន្ទន់ឥរិយាបថទល់តែសោះទៅលើបញ្ហានេះមិនត្រឹមតែប៉ុណ្ណោះតែងតែប៉ុណ្ណោះថែមទាំងតម្លើងសាច់ដុំរបស់ខ្លួនជារឿងៗ តាមរយៈពាក្យសម្តីនិងការផ្ទុះអាវុធជាមួយប្រទេសវៀតណាម និងប្រទេសហ្វីលីពីនទៀតផង។ ជម្លោះរវាងចិន និងវៀតណាម ចិន និងហ្វីលីពីនតែងតែមានលក្ខណៈក្តៅខ្លាំងជាងប្រទេសព្រុយណេ និងម៉ាឡេស៊ីព្រោះការដណ្តើមគ្នាកាន់កាប់កោះស្ព្រាតលី និងផារ៉ាស៊ែលដែលមានធនធានធម្មជាតិជាច្រើននៅជុំវិញនោះ។ ជារឿងមួយមិនអាចប្រកែកបាន ចិនជាប្រទេសដែលត្រូវគេហៅថាមហាយក្សនៅក្នុងតំបន់អាស៊ីយើងនេះ មានមិនមែនជារឿងងាយស្រួលនោះទេ ដែលចង់ឲ្យចិនបន្ទន់ខ្លួនសំរបសំរួលជាមួយប្រទេសដទៃទៀតនៅក្នុងជម្លោះនេះ។ អ្វីសំខាន់ជាងនេះទៅទៀត សេដ្ឋកិច្ចរបស់ចិនចាប់ផ្តើមរីកដុះដាល មិនត្រឹមតែលេចធ្លោនៅក្នុងតំបន់ប៉ុណ្ណោះទេគឺសម្រាប់ពិភពលោកទាំងមូលតែម្តងដែលសូម្បីតែ សហរដ្ឋអាមេរិកក៏មានការញញើត។ ជាក់ស្តែង នៅក្នុងជម្លោះចិនខាងត្បូងនេះអាមេរិកតែងចូលខ្លួនជាញឹកញយក្នុងការពិភាក្សា វែកញែកដើម្បីស្វែងរកដំណោះស្រាយដោយសន្តិវិធី តែគេដឹងបាត់ទៅហើយថា អាមេរិកជាសម្ព័ន្ធមិត្រចាក់ទឹកមិនលេចរបស់ហ្វីលីពីន និងប្រទេសផ្សេងទៀតនៅក្នុងជម្លោះ តើអាចឲ្យចិនទុកចិតអាមេរិក ធ្វើជាអាជ្ញាកណ្តាលបានដោយរបៀបណា?

តាមពិតទៅអាមេរិកក៏គ្មានបំណងអ្វីណាស់ណាដែរទេ គឺមហាអំណាចមួយនេះក៏តែងតែប្រើគោលនយោបាយការបរទេសរបស់ខ្លួន ដើម្បីចំណេញសេដ្ឋកិច្ចផងដែរ។ ឧទាហរណ៍ ប្រសិនបើរដ្ឋណា

មួយ ដែលជាមិត្ររបស់អាមេរិកទទួលបានប្រយោជន៍ពីសមុទ្រចិនខាងត្បូង នោះអាមេរិកចាប់ចាក់ឫស ធ្វើពាណិជ្ជកម្មឲ្យកាន់តែរឹងមាំ ហើយបន្សាបឥទ្ធិពលរបស់មហាយក្សចិននៅក្នុងតំបន់អាស៊ីនេះ។ ប៉ុន្តែស្ថានភាពនៅពេលបច្ចុប្បន្ននេះ វាមិនឃើញដូចការគិតនោះទេព្រោះចិនក៏ចេះប្រើគោលនយោបាយទន់ភ្លន់ខ្លាំងណាស់ដែរ។ នៅក្នុងសវត្សទី ២១ យើងនេះបញ្ហាសមុទ្រចិនខាងត្បូងត្រូវបានចាត់ទុកថាជាបញ្ហាធំបំផុតព្រោះការប្រកួតប្រជែងរបស់មហាអំណាចទាំងចិន និងអាមេរិកនៅក្នុងកិច្ចប្រជុំកំពូលរបស់អាស៊ានកើតឡើងជាញឹកញយ។ លើសពីនេះទៀត គ្មាននរណាម្នាក់អាចដឹងទេថា នឹងមានអ្វីកើតឡើងប្រសិនបើចិនកាន់ខ្លាំងឡើងៗទាំងសេដ្ឋកិច្ច និងសញ្ញាវុធពីព្រោះការងើបឡើង របស់ចិនមកទល់នឹងថ្ងៃនេះ ក៏គ្មាននរណាម្នាក់បានទាយទុកដែលសូម្បីតែចិនខ្លួនឯងផ្ទាល់។ ចិនវាមែនមានតែបញ្ហាសមុទ្រខាងត្បូងតែមួយប៉ុណ្ណោះទេ សូម្បីតែជប៉ុន និងកូរ៉េក៏មានទំនាស់មិនតិចដែរ ជាមួយរដ្ឋមួយនេះ តើប្រទេសទាំងនោះនឹងដោះស្រាយយ៉ាងណាជាមួយចិន? ភាពស្មើរភាពគ្នារវាងរដ្ឋនីមួយៗទោះបីរដ្ឋនោះតូច ឬធំវាគ្រាន់តែជាទ្រឹស្តីប៉ុណ្ណោះ នៅក្នុងទំនាក់ទំនងអន្តរជាតិប្រហែលជាគ្មានទេ កត្តាទាំងអស់នេះហើយទើបបញ្ហាទំនាក់ទំនងសមុទ្រចិនខាងត្បូងមានការលំបាកដោះស្រាយ។

## អនុសាសន៍

នៅទីបញ្ចាប់នៃកិច្ចការស្រាវជ្រាវសារណាស្តីពី **ជម្លោះសមុទ្រចិនខាងត្បូងនៅក្នុងទំនាក់ទំនង អន្តរជាតិ**នេះឡើង មកយើងខ្ញុំមានអនុសាសន៍ថា ជម្លោះអន្តរជាតិមួយនេះត្រូវតែមានទស្សនវិស័យបន្ថែមទៀតដើម្បីកុំឲ្យវាមានភាពរីករាលដាលកាន់តែខ្លាំងឡើងៗ រហូតដល់ការផ្ទុះអាវុធក្នុងតំបន់ និងធានាឲ្យបានសុខសន្តិភាពនៅក្នុងតំបន់ ។ សំរាប់យើងខ្ញុំផ្ទាល់ ទស្សនវិស័យនោះគឺរដ្ឋទាំងអស់គួរតែមានវិធានការណ៍ដូចខាងក្រោម៖

- ស្វែងរកភាគីទី ៣ ដែលអព្យាក្រឹត្យមិនមែនជាអាមេរិក ឬរដ្ឋណាមួយក្នុងជម្លោះ។
- លើកប្រធានបទនេះឡើងរាល់កិច្ចប្រជុំកំពូលអាស៊ាន នៅពេលដែលមានចិនចូលរួម។
- រដ្ឋទាំងអស់គួរគោរពអនុសញ្ញាស្តីពីនីតិសមុទ្រ តាមគោលការណ៍ទាំងឡាយដែលបានចែងនៅក្នុងសន្ធិសញ្ញានោះ។
- រដ្ឋទាំងអស់គួរគោរពធម្មនុញ្ញអាស៊ាន ជាពិសេសធម្មនុញ្ញអង្គការសហប្រជាជាតិតាមគោលការណ៍សន្តិភាព និងសន្តិសុខក្នុងពិភពលោក។

- បើស្ថានភាពកាន់តែតឹងឡើងៗ រដ្ឋទាំងអស់គួរស្នើរឲ្យតុលាការអន្តរជាតិ បកស្រាយអនុសញ្ញាស្តីពីនីតិសមុទ្រឲ្យបានច្បាស់លាស់ អំពីដែនអធិបតេយ្យភាព និងតំបន់ត្រួតស៊ីគ្នាឲ្យបានច្បាស់លាស់ ហើយរដ្ឋទាំងអស់ត្រូវតែគោរពតាម។
- ត្រូវធ្វើការចចារម្តងហើយម្តងទៀត ជាទ្វេភាគីឬពហុភាគីដើម្បីជៀសវាងការផ្ទុះកម្លាំងប្រដាប់អាវុធ។

ចំពោះព្រះរាជាណាចក្រកម្ពុជាយើងវិញ យើងខ្ញុំគិតថាគួរតែជារដ្ឋមួយដែលអព្យាក្រឹត្យបំផុត ក្នុងនាមជាសមាជិកអាស៊ានដូច ហ្វីលីពីន វៀតណាម ព្រុយណេ និង ម៉ាឡេស៊ី ហើយជាមិត្រដ៏ជិតស្និទ្ធរបស់មហាយក្សចិន ព្រោះការរក្សាមិត្តភាពនេះនឹងជួយឲ្យកម្ពុជារក្សាបាននូវចំណងពាណិជ្ជកម្ម និងទំនាក់ទំនងការទូតដល់ល្អបំផុត ដែលមិនធ្វើឲ្យប្រទេសណាមួយអាក់អន់ចិត្តជាមួយនឹងកម្ពុជា។

# ឯកសារយោង

## ១.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រឆ្នាំ ១៩៨២

## ២.សៀវភៅ


- ហ្សង់ ហ្រ្វង់ស័រតាន់ ២០១៤ សៀវភៅ **ចម្បាំងត្រជាក់រវាងអាមេរិកនិងចិន**
- ហ្សង់ ហ្រ្វង់ស័រតាន់ ២០១២ សៀវភៅ **មហាយក្សចិន**
- ហើស សិរីធន ២០១៣ សៀវភៅសមុទ្រចិនខាងត្បូងក្នុងចក្ខុនយោបាយរបស់ពួកអ្នកវិភាគយុទ្ធសាស្ត្រអន្តរជាតិ
- Valero, M.C. 1994 "Spartly Archipelago Dispute: Is the Question of Soverignty Still Relevant?".


## ៣.អត្ថបទនានា


- AQUASTAT. "Irrigation in Southern and Eastern Asia in figures." Brunei Darussalam, 2011
- Beckman, Robert C. "The South China Sea Dispute: An International lawyer's View." *ASEAN AND THE SOUTH CHINA SEA DISPUTE*, 2011
- Castro, Renato Cruz De. "The Philippines in the South China dispute." In *The South China Sea and Australia's Regional Security Environment*, , 2013.
- Shoji, Tomotaka. "Vietnam, ASEAN, and the South China Sea: Unity or Diverseness?" *NIDS Journal of Defense and Security*, 2012.
- Finkbeiner, John M. "Malaysia's Great Power Balance and the South China Sea Disputes." *Strategy Research Project*, 2013.
- Gjetnes, Marius. "THE LEGAL REGIME OF ISLANDS IN THE SOUTH CHINA SEA ." *Master Thesis of Law*, 2000
- Loosley, Stephen. "South China Sea Dispute a Long Time Coming, but Solutions are in Hand." *The Australian*, 2013.
- Nguyen, Dong Manh. "Settlement of disputes under the 1982 United Nations Convention on the Law of the Sea The case of the South China Sea dispute, December 2005.
- Ozdalga, Damla. "Managing Peace, Security and Prosperity in the South China Sea ." 2011
- Resenberg, David. "The Paradox of the South China Sea Dispute." *The China Story*, 2013.
- Thayer, Carlyle A. "China's New Wave of Aggressive Assertiveness in the South China Sea." Washington DC, 2011.
- Yujuico, Dr Emmanuel. "The real story behind the South China Sea dispute." *Southeast Asia International Affairs*, n.d.


## ៤.សេចក្តីថ្លែងការណ៍

- សេចក្តីថ្លែងការណ៍លើកទី២ ក្នុងកិច្ចប្រជុំមេដឹកនាំរវាងអាមេរិក និងអាស៊ាន

## ៥.ការសែត

- http://www.bbc.com/news/world-asia/ (ការសែតអន្តរជាតិឈ្មោះ BBC)
- http://www.reuters.com/ (ការសែតអន្តរជាតិឈ្មោះ REUTERS)
- http://www.time.com/ (ការសែតអន្តរជាតិឈ្មោះ TIME)

## ៦.គេហទំព័រ

- http://www.mygola.com/south-china-sea-p99543
- http://www.ciis.org.cn (វិទ្យាស្ថានសិក្សាអន្តរជាតិនៃប្រទេសចិន)
- http://www.cfr.org (ក្រុមប្រឹក្សាទំនាក់ទំនងអន្តរជាតិ)
- www.un.org/ (អង្គការសហប្រជាជាតិ)
- www.asean.org (អាស៊ាន)

# តារាងសម្គាល់អក្សរកាត់

| | |
|---|---|
| ADMM+ | : ASEAN Defence Ministers Plus |
| APEC | : Asia-Pacific Economic Cooperation |
| ARF | : ASEAN Regional Forum |
| ASEAN | : Association of Southeast Asian Nations |
| COC | : Code of Conduct in the South China Sea |
| DOC | : Declaration on the Conduct of parties in the South China Sea |
| EAS | : East Asia Summit |
| EEZ | : Exclusive Economic Zone |
| TAC | : Treaty of Amity and Cooperation |
| UNCLOS | : United Nations Convention on the Law of the Sea |